របាយការណ៍ប្រចាំឆ្នាំ
២០១៨

អគ្គិសនីកម្ពុជា

អាគារលេខ២ ផ្លូវព្រះអង្គយុគន្ធរ(១៩) សង្កាត់វត្តភ្នំ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ : (+៨៥៥)២៣ ៧២៨ ៧៧១
អ៊ីម៉ែល : (+៨៥៥)២៣ ៤២៦ ០១៨
ទូរសារ : info@edc.com.kh
គេហទំព័រ : www.edc.com.kh

សារពី
ប្រធានក្រុមប្រឹក្សាភិបាល

តាំងនាមឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមសំដែងនូវការកោតសរសើរយ៉ាងស្មោះចំពោះអគ្គិសនីកម្ពុជា ដែលបានបញ្ចេញនូវរបាយការណ៍ប្រចាំឆ្នាំ២០១៨។ យើងមានមោទនភាព និងការកោតសរសើរចំពោះលទ្ធផល ដែលអគ្គិសនីកម្ពុជាសម្រេចបានក្នុងអំឡុងឆ្នាំ ២០១៨ និងជឿជាក់យ៉ាងមុតមាំថា អគ្គិសនីកម្ពុជានឹងឈានឆ្ពោះទៅកាន់ការសម្រេចបាននូវគោលដៅ និងចក្ខុវិស័យរបស់ខ្លួនក្នុងគោលបំណង ដើម្បីក្លាយជាក្រុមហ៊ុនឈានមុខគេលើវិស័យថាមពលនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយកសាងទំនាក់ទំនង និងសេវាកម្មល្អ ប្រកបដោយទំនុកចិត្ត ក្នុងការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងតម្លៃសមរម្យជូនអតិថិជនរបស់ខ្លួន។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្តីពេញចិត្តយ៉ាងខ្លាំង ចំពោះភាពជោគជ័យដ៏ធំធេង ដែលនិយោជិត និងថ្នាក់ដឹកនាំអគ្គិសនីកម្ពុជាសម្រេចបានក្នុងឆ្នាំកន្លងមក។ សមិទ្ធផលដែលកើតមានជាបន្តបន្ទាប់នាប៉ុន្មានឆ្នាំកន្លងមកនេះ គឺជាសមិទ្ធផលដែលមិនធ្លាប់មានពីមុនមក។

ក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវអំណរគុណអស់ពីដួងចិត្ត ចំពោះថ្នាក់ដឹកនាំ និងនិយោជិតអគ្គិសនីកម្ពុជាទាំងអស់ដែលបានបំពេញការងារអស់ពីកម្លាំងកាយនិងបញ្ញាស្មារតីដែលធ្វើឲ្យសម្រេចបាននូវសមិទ្ធិផលជាច្រើនកន្លងមក ដើម្បីឈានដល់ទិសដៅ និងចក្ខុវិស័យរបស់ខ្លួន។

ប្រធានក្រុមប្រឹក្សាភិបាល

ចិចឌ័រ ហ្សូនា

សារពីរដ្ឋមន្ត្រីប្រតិភូ អមនាយករដ្ឋមន្ត្រី អគ្គនាយកអគ្គិសនីកម្ពុជា

“ ទាំងនេះជាអ្វី ដែលពួកយើង កំពុងខិតខំប្រឹងប្រែង

ខ្ញុំមានមោទនភាព និងសូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០១៨ ដែលអគ្គិសនីកម្ពុជាទទួលបានដែលជាចំណុចរបត់ថ្មីមួយទៀត នៅក្នុងការអភិវឌ្ឍន៍វិស័យថាមពលក្នុងព្រះរាជាណាចក្រកម្ពុជា។ ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនីឈានមុខគេ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំងក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី និងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់។ នេះក៏ជាឆ្នាំនៃការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីពង្រឹងបន្ថែមផ្នែកសេវាកម្មរបស់យើងជូនអតិថិជន។

ក្នុងឆ្នាំ២០១៨ ការលក់ថាមពលអគ្គិសនីរបស់អគ្គិសនីកម្ពុជាបានកើនឡើងដល់ ៨.៦៧៥ ជីហ្គាវ៉ាត់ម៉ោង (GWh) ឬ ២៤% ច្រើនជាងឆ្នាំមុន។ ការបាត់បង់លើប្រព័ន្ធទាំងមូលក្នុងឆ្នាំ២០១៨ ស្ថិតក្នុងរង្វង់ប្រមាណ ៨%។ ចំណូលប្រចាំឆ្នាំមានការកើនឡើងដល់ ៥.៦៧០ ប៊ីលានរៀល ឬ ២១% ច្រើនជាងឆ្នាំមុន។ អគ្គិសនីកម្ពុជាមាននិយោជិតសរុបចំនួន ៥.៤៨២ នាក់ សម្រាប់បម្រើសេវាកម្មជូនអតិថិជនចំនួន ១.០៨៦.៨១២។

នៅចុងឆ្នាំ២០១៨ រោងចក្រផលិតថាមពលវារីអគ្គិសនីសេសានក្រោម២ ដែលជាវារីអគ្គិសនីធំជាងគេបង្អស់នៅកម្ពុជា ត្រូវបានដាក់ឲ្យដំណើរការម៉ាស៊ីនទាំង៨ ដែលមានអានុភាពសរុបប្រមាណ ៤០០ មេហ្គាវ៉ាត់ និងអាចផលិតថាមពលអគ្គិសនីអតិបរមាសរុបប្រមាណ ១.៥០០ ជីហ្គាវ៉ាត់ម៉ោងក្នុងមួយឆ្នាំ ដែលថាមពលមួយផ្នែកត្រូវបានយកទៅផ្គត់ផ្គង់ក្នុងផ្នែកខ្លះនៃខេត្តស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី តាមខ្សែបណ្តាញ ៣៥ គីឡូវ៉ុល ហើយដោយឡែកថាមពលមួយផ្នែកធំទៀត ត្រូវបានបញ្ជូនតាមខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល មកកាន់រាជធានីភ្នំពេញ ដែលជាទីតាំងសំខាន់នៃបណ្តុំពាណិជ្ជកម្ម ឧស្សាហកម្ម និងការអភិវឌ្ឍន៍នានា ដែលកំពុងត្រូវការថាមពលអគ្គិសនីដ៏ច្រើនលើសលប់នាពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអនាគតផងដែរ។

ដើម្បីបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីជូនដល់បណ្តារោងចក្រឧស្សាហកម្មធំៗ ជាមួយអត្រាថ្លៃលក់អគ្គិសនីសមរម្យ អគ្គិសនីកម្ពុជា បានសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល ប្រវែងប្រមាណ ៧ គីឡូម៉ែត្រ ភ្ជាប់ពីអនុស្ថានីយបន្ទាយមាស ទៅកាន់រោងចក្រផលិតស៊ីម៉ង់ CHIP MONG INSEE CEMENT CORPORATION

(CMIC) ស្ថិតក្នុងស្រុកបន្ទាយមាស ខេត្តកំពត ដើម្បីផ្គត់ផ្គង់ថាមពលអគ្គិសនីសម្រាប់បម្រើដល់ដំណើរការសម្អាក់ផលិតកម្ម នៅក្នុងរោងចក្រផ្ទាល់ ។ មិនត្រឹមតែប៉ុណ្ណោះ អគ្គិសនីកម្ពុជាក៏បានដាក់ឲ្យដំណើរការខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុលមួយខ្សែទៀត ប្រវែងប្រមាណ ១,៨ គីឡូម៉ែត្រ ភ្ជាប់ពីខ្សែបណ្តាញមានស្រាប់ ទៅអនុស្ថានីយអគ្គិសនីទី១០ ដែលមានទីតាំងស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PPSEZ) ។ ការដាក់ឲ្យដំណើរការគម្រោងទាំងពីរខាងលើនេះ ជាសូចនាករមួយ ដើម្បីឆ្លើយតបទៅនឹងការអនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម(IDP)ឆ្នាំ២០១៥-២០២៥ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងពង្រីងវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី ជូនដល់តំបន់ប៉ូលឧស្សាហកម្មធុនធំ ដើម្បីទាក់ទាញចំនួនអ្នកវិនិយោគលើវិស័យឧស្សាហកម្ម ដែលអាចបង្កើនឱកាសការងារជាច្រើនដល់ប្រជាពលរដ្ឋ រស់នៅជុំវិញតំបន់នោះផងដែរ។

ការចាប់ផ្តើមសិក្សាសមត្ថិលទ្ធភាពគម្រោងឧទ្យានផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យថ្មីមួយកន្លែងទៀតស្ថិតនៅតំបន់ភ្នាតពង ខេត្តកំពង់ស្ពឺ មានអានុភាព ៦០ មេហ្គាវ៉ាត់ លើផ្ទៃដីប្រមាណជាង ១២០ ហិកតា ដែលអាចផលិតថាមពលអគ្គិសនីក្នុងរង្វង់ប្រមាណ ៩៦ ជីហ្គាវ៉ាត់ម៉ោងក្នុងមួយឆ្នាំ។ ថាមពលកកើតឡើងវិញ បានក្លាយជាមុខព្រួញដ៏សំខាន់ក្នុងចំណោមប្រភពថាមពលអាទិភាពសំខាន់ៗមួយចំនួន ដែលមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។

ការចាប់ផ្តើមគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ជាកង ភាគខាងកើតនៃប្រទេសកម្ពុជា ជំហានទី២ ដែលមានប្រវែងសរុប ២៩៨ គីឡូម៉ែត្រ ក្នុងនោះខ្សែបញ្ជូន ២៣០ គីឡូវ៉ុល ពីវារីអគ្គិសនីសេសានក្រោម២ ទៅអនុស្ថានីយរតនគីរី មានប្រវែងប្រមាណ ១១៥ គីឡូម៉ែត្រ និងពីអនុស្ថានីយក្រចេះ ទៅអនុស្ថានីយមណ្ឌលគីរី មានប្រវែង ១៣៣ គីឡូម៉ែត្រ ។ ខ្សែបណ្តាញបញ្ជូននេះ គ្រោងនឹងបញ្ចប់ការសាងសង់នៅឆ្នាំ២០២០ ដោយទទួលបានហិរញ្ញប្បទានឥណទានពីធនាគារចិនអាហារ៍ណ-នីហារ៍ណ (China Exim Bank) ។ បន្ទាប់ពីគម្រោងនេះត្រូវបញ្ចប់ជាស្ថាពរ ខេត្តរតនគីរី និងមណ្ឌលគីរី នឹងមានលទ្ធភាព

គ្រប់គ្រាន់ក្នុងការស្រូបយកថាមពលដោយផ្ទាល់ពីបណ្តាញជាតិ ដែលអាចបង្កើនប្រសិទ្ធភាព និងស្ថិរភាពក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យកាន់តែប្រសើរជាងមុន ព្រមទាំងអាចជួយកាត់បន្ថយបរិមាណនៃការនាំចូលថាមពលអគ្គិសនី ពីប្រទេសវៀតណាមតាមរយៈខ្សែបណ្តាញតង់ស្យុងមធ្យម ៣៥ គីឡូវ៉ុល មានរយៈចម្ងាយឆ្ងាយ ដែលអាចប្រឈមនឹងបញ្ហារអាក់រអួលដោយយថាហេតុណាមួយ។

គម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយនៅរាជធានីភ្នំពេញជំហានទី០២ (JICA Phase II) ត្រូវបានចុះកិច្ចព្រមព្រៀងនៅខែឧសភា ឆ្នាំ២០១៨។ គម្រោងនេះ នឹងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពផ្គត់ផ្គង់ថាមពលអគ្គិសនី ឲ្យកាន់តែមានប្រសិទ្ធភាព និងស្ថិរភាពជាងមុន ដើម្បីកាត់បន្ថយហានិភ័យនៃការដាច់ចរន្តអគ្គិសនី នៅក្នុងក្របខណ្ឌរាជធានីភ្នំពេញទាំងមូល តាមរយៈការធ្វើទំនើបកម្ម និងសាងសង់ខ្សែបញ្ជូនប្រទាក់ក្រឡាគ្នា និងខ្សែបណ្តាញចែកចាយឆ្លាតវៃ (Smart Grid)។

ពិធីចុះហត្ថលេខាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងឯកឧត្តមនាយករដ្ឋមន្ត្រីចិនលើការទទួលគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ៥០០គីឡូវ៉ុល ពីប្រភពថាមពលវារីអគ្គិសនី នៅខេត្តដងសាហុង ប្រទេសឡាវ មកភ្ជាប់នឹងខ្សែបណ្តាញ ២៣០ គីឡូវ៉ុល មានស្រាប់ក្នុងខេត្តស្ទឹងត្រែង ត្រូវបានធ្វើឡើងនៅដើមឆ្នាំ២០១៨។ គម្រោងនេះទទួលបានការគាំទ្រ និងសហការពីភាគីឡាវ ក្នុងការពង្រីកទំបាំពាណិជ្ជកម្មថាមពល និងចំណងសាមគ្គីភាពរវាងប្រទេសទាំងពីរ ក៏ដូចជាបំពេញតម្រូវការថាមពលអគ្គិសនីនៅកម្ពុជា ព្រមទាំងបង្កើនប្រសិទ្ធភាព និងស្ថិរភាពបណ្តាញជាតិឲ្យកាន់តែប្រសើរជាងមុន។

បន្ថែមលើផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០២០ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងរ៉ែ និងថាមពល បានចេញសេចក្តីប្រកាស ស្តីពីការកែសម្រួល

អត្រាថ្លៃលក់អគ្គិសនីឡើងវិញក្នុងឆ្នាំ២០១៨ សម្រាប់ការអនុវត្តបន្តពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២០។ តាមរយៈការកែសម្រួល ផែនការបន្ថយអត្រាថ្លៃលក់អគ្គិសនីខាងលើនឹងរួមចំណែកក្នុងការកាត់បន្ថយថ្លៃប្រើប្រាស់អគ្គិសនីដល់អ្នកប្រើប្រាស់អគ្គិសនីមានកម្រិតជីវភាពមធ្យម និងទាបជាពិសេសមន្ត្រីរាជការ បងប្អូនកម្មករ-កម្មការនី ដែលប្រើប្រាស់ចាប់ពីអគ្គិសនីមិនលើសពី ២០០ គីឡូវ៉ាត់ម៉ោងក្នុងមួយខែ។ ឥទ្ធិពលនៃផែនការបន្ថយអត្រាថ្លៃលក់អគ្គិសនី និងអនុគ្រោះថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋាន បានផ្តល់ផ្លែផ្កាដល់លំនៅដ្ឋានប្រមាណ ៩០% តាមរយៈការឧបត្ថម្ភធនដោយនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជា។

ថវិកាសរុបចំនួន ៧៧,៦ លាន ដុល្លារអាមេរិក ត្រូវបានប្រើប្រាស់ សម្រាប់អនុវត្តកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ ដែលក្នុងនោះ អគ្គិសនីកម្ពុជាបានផ្តល់ថវិកាចំនួន ៧៤ លានដុល្លារអាមេរិក ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) ចំនួន ២,៦ លានដុល្លារអាមេរិក និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចំនួន ១ លានដុល្លារអាមេរិក។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមធ្វើការកត់សម្គាល់ពីការចូលរួមចំណែក និងការប្តេជ្ញាចិត្តដ៏មោះមុតរបស់និយោជិតយើងទាំងអស់គ្នា ដែលបានដើរតួនាទីដ៏សំខាន់ និងមិនអាចខ្វះបានក្នុងការសម្រេចបានជោគជ័យជូនអង្គភាពនេះ។ យើងខ្ញុំសូមសម្តែងនូវកត្តញ្ញូតាជ្រាលជ្រៅចំពោះការណែនាំដ៏មានសារៈសំខាន់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលសម្តេចតែងផ្តល់ការគាំទ្រជាគន្លឹះៗនៅគ្រប់វិបត្តិសំខាន់ៗទាំងអស់។

យើងខ្ញុំសូមសម្តែងនូវការដឹងគុណ ចំពោះក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានបន្តចង្អុលបង្ហាញទិសដៅ និងគាំទ្រយ៉ាងខ្លាំងក្លា។ យើងខ្ញុំសូមសំដែងនូវសេចក្តីសោមនស្សរីករាយជាពិសេសជូនដល់អាជ្ញាធរអគ្គិសនីកម្ពុជា និងចំពោះសមាជិកក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា សម្រាប់ការចូលរួមចំណែកការគាំទ្រ និងការណែនាំកន្លងមក។ យើងខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ផងដែរ ចំពោះការគាំទ្រពីសំណាក់អតិថិជនគ្រប់ប្រភេទរបស់អគ្គិសនីកម្ពុជា ជាងនេះទៅទៀត យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ ចំពោះដៃគូអភិវឌ្ឍន៍នានា ជាពិសេសធនាគារចិនអាហារ័ណានីហារ័ណរបស់សាធារណៈរដ្ឋប្រជាមានិតចិន និងដៃគូផលិតករថាមពលឯករាជ្យទាំងអស់។ ជាមួយការរីកចម្រើននេះ អគ្គិសនីកម្ពុជាកំពុងបោះជំហានទៅមុខ ប្រកបដោយសុទិដ្ឋិនិយម ក្នុងបេសកកម្មរបស់ខ្លួនដ៏ប្រសើរ ដើម្បីជួយអភិវឌ្ឍវិស័យថាមពលក្នុងព្រះរាជាណាចក្រកម្ពុជា។

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
អគ្គនាយកអគ្គិសនីកម្ពុជា

កែវ រតន:

មាតិកា

អំពីយើង

ការវិវឌ្ឍន៍របស់អគ្គិសនីកម្ពុជា ៨
ចក្ខុវិស័យ ១០
ទស្សនវិស័យ ១០
តួនាទី និងការទទួលខុសត្រូវ ១១
រចនាសម្ព័ន្ធគ្រប់គ្រង ១៣

ចំណុចសំខាន់ៗផ្នែកហិរញ្ញវត្ថុ

តារាងតុល្យការ និងលំហូរសាច់ប្រាក់ ១៦

ការអភិវឌ្ឍធនធានមនុស្ស

ការបណ្តុះបណ្តាលចំណេះដឹងក្នុងប្រទេស ២០
ការបណ្តុះបណ្តាលចំណេះដឹងក្រៅប្រទេស ២២

អាជីវកម្មស្នូល

ប្រភពផលិតកម្ម ២៦
តម្រូវការថាមពល និងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងបណ្តាញជាតិ ២៦
ខ្សែបណ្តាញជាតិបញ្ជូនអគ្គិសនី ៤៤
ខ្សែបណ្តាញចែកចាយអគ្គិសនី ៥២

មូលនិធិអគ្គិសនីតាក្រមបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា

ការបង្កើតស្ថាប័ន មូលនិធិអគ្គិសនីតាក្រមបនីយកម្មជនបទ(ម.អ.ជ) ៥៨
សកម្មភាពការងារដែល ម.អ.ជ សម្រេចបាន ៥៨

ផែនការអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រលើវិស័យថាមពលអគ្គិសនី

គោលនយោបាយអភិវឌ្ឍនវិស័យថាមពល ៦២
ការព្យាករណ៍តម្រូវការថាមពល ៦២
ផែនការមេនៃការផលិតថាមពល និងប្រព័ន្ធខ្សែបញ្ជូន ៦៣

កិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់

ការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសថៃឡង់ដ៍ ៧០
ការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសឡាវ ៧១
ការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសវៀតណាម ៧១
ការតភ្ជាប់បណ្តាញអនុតំបន់ ៧១

ទំនួលខុសត្រូវរបស់អគ្គិសនីកម្ពុជាចំពោះសង្គម

ការចុះជួយឧបត្ថម្ភកងទ័ព ៧២
ការងារមនុស្សធម៌ ៧៣

ការវិវឌ្ឍន៍ របស់អគ្គិសនីកម្ពុជា

ការប្រើប្រាស់ថាមពលអគ្គិសនីមានវត្តមាននៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩០៦។ មុនខែតុលា ឆ្នាំ១៩៥៨ ថាមពលអគ្គិសនី និងការប្រើប្រាស់សម្រាប់ចំភ្លឺផ្សេងៗនៅប្រទេសកម្ពុជា ត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុនឯកជនចំនួន ០៣៖

- ក្រុមហ៊ុនទឹក និងអគ្គិសនី ហៅកាត់ថា CEE
- សហព័ន្ធអគ្គិសនីឥណ្ឌូចិន ហៅកាត់ថា UNEDI
- ក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ ហៅកាត់ថា CFKE

ក្រុមហ៊ុនទឹក និងអគ្គិសនី CEE បានបម្រើសេវាអគ្គិសនីយ៉ាងធំនៅតំបន់ទីក្រុងភ្នំពេញ។ សហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) ទទួលខុសត្រូវគ្រប់បណ្តាខេត្តផ្សេងៗទាំងអស់លើកលែងតែខេត្តបាត់ដំបង ដែលត្រូវបានផ្គត់ផ្គង់អគ្គិសនីដោយក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ(CFKE)។

យោងតាមព្រះរាជក្រឹត្យលេខ ៦៥៥ - NS ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៥៨ ក្រុមហ៊ុនចំនួនពីរ គឺក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) និងសហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) បានដាក់បញ្ចូលគ្នា ដោយដាក់ថា " **អគ្គិសនីកម្ពុជា** " ។

អំឡុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩ វិស័យថាមពលអគ្គិសនីនៅក្នុងប្រទេសបានឆ្លងកាត់ព្រឹត្តិការណ៍ចំនួនពីរ ដែលទទួលរងគ្រោះថ្នាក់ដោយសារ៖ សង្គ្រាមស៊ីវិល (ពីឆ្នាំ១៩៧០ - ១៩៧៥) និងមានភាពចលាចលជាប្រវត្តិសាស្ត្រអំឡុង

របបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ - ១៩៧៩)។ អំឡុងពេលនោះ មធ្យោបាយនៃការផលិត ការបញ្ជូន និងការចែកចាយគ្រប់ប្រភេទទាំងអស់ត្រូវបានបំផ្លាញ មិនត្រឹមតែនៅរាជធានីភ្នំពេញទេ ប៉ុន្តែថែមទាំងនៅតំបន់ជនទៀតទូទាំងប្រទេសផងដែរ។

នៅឆ្នាំ១៩៧៩ អគ្គិសនីកម្ពុជាត្រូវបានបង្កើតឡើងវិញ ដោយរចនាសម្ព័ន្ធរដ្ឋបាល ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម។ នៅឆ្នាំ ១៩៩១ អគ្គិសនីកម្ពុជា ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញ ដោយដាក់ថា "**អគ្គិសនីភ្នំពេញ**" ហើយមានភារកិច្ចផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញ ទន្ទឹមនឹងនោះការផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្តាខេត្តទាំងអស់ ត្រូវបានគ្រប់គ្រងដោយមន្ទីរឧស្សាហកម្មខេត្ត។



នៅឆ្នាំ ១៩៩២ អគ្គិសនីភ្នំពេញ ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម ដោយប្តូរនាមជាថ្មីទៅជា "**អគ្គិសនីកម្ពុជា**" វិញ ។ ក្រោយការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ អគ្គិសនីកម្ពុជា ត្រូវបានធ្វើកំណែទម្រង់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល(១) ហើយទទួលខុសត្រូវសម្រាប់ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅរាជធានីភ្នំពេញ។ ចំណែកឯអង្គភាពបម្រើសេវាកម្មថាមពលអគ្គិសនីនៅតាមបណ្តាខេត្តមួយចំនួននៅតែស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរខេត្ត ប៉ុន្តែទទួលការឧបត្ថម្ភថវិកាតាមរយៈក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

នៅខែមីនា ឆ្នាំ១៩៩៦ តាមព្រះរាជក្រឹត្យលេខ ០៣៩៦ / ១០ អគ្គិសនីកម្ពុជាបានក្លាយជាក្រុមហ៊ុនស្វយ័តទទួលខុសត្រូវមានកំណត់មួយ ជាកម្មសិទ្ធិរបស់រដ្ឋទាំងស្រុង ដែលមានកាតព្វកិច្ចក្នុងការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ។ អគ្គិសនីកម្ពុជាជាស្ថាប័នមួយស្របច្បាប់ ដោយមានស្វ័យភាពនៃការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ។ អគ្គិសនីកម្ពុជាទទួលខុសត្រូវចំពោះប្រាក់ចំណេញប្រាក់ខាតបង់ និងទទួលសងបំណុលទៅតាមទំហំនៃតម្លៃទ្រព្យសម្បត្តិរបស់ខ្លួន។

ចក្ខុវិស័យ

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនីនាំមុខគេ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំង ក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនីនឹងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីជូនអតិថិជន។

ទស្សន:វិស័យ

ផ្តល់ការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ប្រកបដោយស្ថិរភាព គុណភាព ប្រសិទ្ធភាព ជូនអតិថិជននៅក្នុងតំបន់ ដែលមានអាជ្ញាបណ្ណរបស់ខ្លួន ដោយតម្លៃប្រកួតប្រជែង បង្កើនប្រតិបត្តិការអាជីវកម្មឲ្យបានប្រសើរបំផុត និងប្រកបដោយប្រសិទ្ធភាព និងឧត្តមភាពនឹងចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិ។

តួនាទី និងការទទួលខុសត្រូវ

អគ្គិសនីកម្ពុជាមានសិទ្ធិ និងការទទួលខុសត្រូវចំពោះការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមកាតព្វកិច្ចនៃការធ្វើពាណិជ្ជកម្មរបស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់ លក្ខន្តិក: អាជ្ញាបណ្ណ និងបទបញ្ញត្តិដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។

អគ្គិសនីកម្ពុជា ប្រតិបត្តិជាសហគ្រាសពាណិជ្ជកម្មមួយ មានឯករាជ្យភាពក្នុងការរៀបចំអាជីវកម្មរបស់ខ្លួនលើការផលិតបញ្ជូន និងចែកចាយថាមពលអគ្គិសនី ព្រមទាំងបង្កើតទុនវិនិយោគ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងមានការទទួលខុសត្រូវលើចំណូលចំណាយ។

អគ្គិសនីកម្ពុជា ត្រូវអនុវត្តតាមលក្ខខណ្ឌរបស់អាជ្ញាបណ្ណចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីផ្តល់សេវាកម្មអគ្គិសនី។ អគ្គិសនីកម្ពុជា ត្រូវអនុវត្តន៍ នឹងធ្វើឲ្យសម្រេចនូវ ផែនការអាជីវកម្មរបស់ខ្លួន ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា និងអនុលោមតាមគោលនយោបាយថាមពលអគ្គិសនីជាតិ និងផែនការអភិវឌ្ឍន៍ជាតិ ។

អគ្គិសនីកម្ពុជា ត្រូវកំណត់សកម្មភាពអាជីវកម្មដែលមានចែងនៅក្នុងលក្ខន្តិក: និងអាជ្ញាបណ្ណ ដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

អគ្គិសនីកម្ពុជា ត្រូវបានអនុញ្ញាតលើការទទួលខុសត្រូវចំពោះ ៖

១-ការផលិត ការបញ្ជូន និងការចែងចែកថាមពលអគ្គិសនីក្នុងគោលបំណង ដើម្បីឆ្លើយតបតាមតម្រូវការថាមពលរបស់អ្នកជាវគ្រប់ប្រភេទ។

២-នាំចូល និងនាំចេញថាមពលអគ្គិសនីជាមួយប្រទេសជិតខាង។

៣-ការសាងសង់ និងដាក់ឲ្យដំណើរការបណ្តាញជាតិបញ្ជូនអគ្គិសនី ដើម្បីធានានូវការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងមានគុណភាព។

៤-ការសាងសង់ និងដាក់ឲ្យដំណើរការបណ្តាញបញ្ជូនរងក្នុងគោលបំណង ចែកចាយអគ្គិសនី និងផ្គត់ផ្គង់ដល់តំបន់គ្រប់គ្រងដោយអគ្គិសនីកម្ពុជា និងតំបន់ដទៃទៀត។

៥-លក់ថាមពលអគ្គិសនី និងការបម្រើសេវាកម្ម ដែលពាក់ព័ន្ធ។

៦-ទិញថាមពល ការបញ្ជូនថាមពល និងការទិញលក់ថាមពលរវាងអគ្គិសនីកម្ពុជា និងដៃគូរអ្នកផលិត ថាមពលឯករាជ្យផ្សេងៗ។

អគ្គិសនីកម្ពុជា បានប្រភពទុនមកពី ៖

១-ការផ្តល់ជំនួយពីរាជរដ្ឋាភិបាលកម្ពុជា។

២-អចលនទ្រព្យ និងដីធ្លីទាំងឡាយ ដែលត្រូវបានផ្ទេរជូនអគ្គិសនីកម្ពុជា ដោយរាជរដ្ឋាភិបាលកម្ពុជា ដូចមាននៅក្នុងមាត្រា ៧ នៃអនុក្រឹត្យលេខ ២៣។

៣-ប្រាក់ចំណូល ដោយយោងតាមគោលការណ៍គណនេយ្យរបស់អគ្គិសនីកម្ពុជា ។

៤-ការផ្តល់ហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានឥណទានផ្សេងៗ ដែលអគ្គិសនីកម្ពុជាទទួលបាន ដោយមានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា។

៥-ការផ្តល់ឥណទានដល់អគ្គិសនីកម្ពុជាពីប្រភពហិរញ្ញវត្ថុផ្សេងៗ ដែលត្រូវអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា។

អគ្គិសនីកម្ពុជា

អង្គការលេខ និងរចនាសម្ព័ន្ធគ្រប់គ្រង អគ្គិសនីកម្ពុជា



ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាម្ចាស់សហកម្មសិទ្ធិលើក្រុមហ៊ុនអគ្គិសនីកម្ពុជា។ អគ្គិសនីកម្ពុជា ត្រូវបានដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកអគ្គិសនីកម្ពុជា ដែលជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលរបាយការណ៍ត្រឡប់មកវិញ ដើម្បីរាយការណ៍ជូនទៅរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលទាំងពីរ ។ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកអគ្គិសនីកម្ពុជា ត្រូវបានជួយការងារដោយអគ្គនាយករងចំនួន ០៤ រូប និងនាយក ចំនួន ១២ រូប ។ ឆ្នាំ២០១៨ ថ្នាក់គ្រប់គ្រងរបស់អគ្គិសនីកម្ពុជា រួមមាន៖

១ ក្រុមប្រឹក្សាភិបាល

ឯកឧត្តម ហេម ក្រាញ់ត្ងនី
សមាជិក
តំណាង ទីស្តីការ
គណៈរដ្ឋមន្ត្រី

ឯកឧត្តម ចាន់ សុធី
សមាជិក
តំណាង ក្រសួងសេដ្ឋកិច្ច
និងហិរញ្ញវត្ថុ

ឯកឧត្តម កែវ រតនៈ
សមាជិក
រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
អគ្គនាយកអគ្គិសនីកម្ពុជា

២ រចនាសម្ព័ន្ធរបស់អគ្គិសនីកម្ពុជា



បណ្ឌិត ប្រាំង ជលសា
អគ្គនាយករង
ផែនការ និងបច្ចេកទេស

លោក ង៉ែត សុខន
អគ្គនាយករង
ហិរញ្ញកិច្ច-អាជីវកម្ម

លោក កែវ ឌីរៈ
អគ្គនាយករង
មូលនិធិអគ្គិសនីភាវូប-
នីយកម្មជនបទ

លោក ជុន ពិសិដ្ឋ
នាយក ផែនការយុទ្ធសាស្ត្រ
និងគម្រោងការ

លោក អូន ហេមរិទ្ធ
នាយក ផលិតកម្ម

លោក គង់ ពុទ្ធី
នាយក បញ្ជូនអគ្គិសនី

លោក ឌីវ រ៉ាវុឌ្ឍ
នាយក អាជីវកម្មចែកចាយនាយិកា

កញ្ញា សុិន សុវណ្ណនី
ហិរញ្ញកិច្ច-គណនេយ្យ

លោក លឿង កែវសិលា
នាយក មូលនិធិអគ្គិសនី
ភាវូបនីយកម្មជនបទ

ឯកឧត្តម ទិចឧ៉រ ហ្យូនា
ប្រធាន
តំណាង ក្រសួងជ៉ែ និងថាមពល

លោក ហង់ ឡូច
សមាជិក
តំណាងនិយោជិតកម្មករ
អគ្គិសនីកម្ពុជា

លោក គី ខេមលីន
សមាជិក
តំណាង ក្រសួងយុត្តិធម៍

លោកស្រី សុខ សុធាទី
សមាជិក
តំណាង សភាពាណិជ្ជកម្មកម្ពុជា

ឯកឧត្តម អេង គន្ធា
អគ្គនាយករង
រដ្ឋបាល

លោក លី ឡីយា
នាយក រដ្ឋបាល

លោក អ៊ុំ ពិសិដ្ឋ
នាយក វិទ្យាស្ថាន
វិទ្យាសាស្ត្រអគ្គិសនី

លោក ឈឹម ម៉ាន
នាយក លទ្ធកម្ម

លោក សារុន សក្ការានុជ
នាយក បច្ចេកវិទ្យាព័ត៌មាន

លោក អៀម ទណ្ឌថា
នាយក សវនកម្មផ្ទៃក្នុង

លោក ជួង ហេង
នាយក អធិការកិច្ច

ចំណុចសំខាន់ៗ ផ្នែកហិរញ្ញវត្ថុ

១- តារាងតុល្យការហិរញ្ញវត្ថុ របស់ អគ្គសនីកម្ពុជា សម្រាប់ចុងឆ្នាំ២០១៨

២- របាយការណ៍លទ្ធផល របស់ អគ្គសនីកម្ពុជាសម្រាប់ចុងឆ្នាំ២០១៨

៣- របាយការណ៍លំហូរសាច់ប្រាក់ របស់ អគ្គសនីកម្ពុជា សម្រាប់ចុងឆ្នាំ២០១៨

ចំណូល

៥.៦៧២ ពាន់ លានរៀល

ប្រាក់ចំណេញសុទ្ធ

៦១០ ពាន់ លានរៀល

ទ្រព្យសកម្មសរុប

៩.០៤២ ពាន់ លានរៀល

បំណុលសរុប

៥.១៥៧ ពាន់ លានរៀល

មូលធនសរុប

៣.៨៨៥ ពាន់ លានរៀល

តារាងតុល្យការហិរញ្ញវត្ថុ របស់អគ្គិសនីកម្ពុជា សម្រាប់ចុងឆ្នាំ២០១៨

	២០១៨ ពាន់រៀល	២០១៧ ពាន់រៀល
ទ្រព្យសកម្ម		
ទ្រព្យសកម្មរយៈពេលវែង		
ទ្រព្យ រោងចក្រ និងបរិក្ខារ	៦.៣៥១.៨៤៦.៧២៦	៥.៣០៣.២២០.៩៩០
ទ្រព្យសកម្មអរូបិយ	៣.២៧០.០៣៥	១.៦១៩.៣៤៥
ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ	-	-
	៦.៣៥៥.១១៦.៧៦១	**៥.៣០៤.៨៤០.៣៣៥**
ទ្រព្យសកម្មចរន្ត		
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	១.៣៦៣.៥៣៧.៩៨១	១.២៦២.៥០៩.៨៨១
គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ	៨៧១.៥៤៦.៥០៩	៦៦៥.៥៧៥.៨៩៨
សន្និធិ	៤៥២.០៣៣.៨១៧	៣៩៨.៨១១.៧៨៣
	២.៦៨៧.១១៨.៣០៧	២.៣២៦.៨៩៧.១៦២
ទ្រព្យសកម្មសរុប	**៩.០៤២.២៣៥.០៦៨**	**៧.៦៣១.៧៣៧.៤៩៧**
មូលធន		
ដើមទុន	៩៣០.១១៩.០៦៧	៨៣៣.៦៩១.៨៦១
ប្រាក់ចំណេញរក្សាទុក	២.៩៥៤.៧៣៤.២០៣	២.៣៦៨.២៧៤.៧៩០
	៣.៨៨៤.៨៥៣.២៧០	**៣.២០១.៩៦៦.២៥១**
ទ្រព្យអកម្ម		
បំណុលរយៈពេលវែង		
ប្រាក់កម្ចី	៣.៦២០.៩៣៦.៩៥៦	៣.០៨៤.០១៧.៥៣៣
ប្រាក់កក់របស់អតិថិជន	២៨៥.៧០៩.១៦២	២៩៦.១០៧.២៥២
សំវិធានធនសម្រាប់សោធននិវត្តន៍	៤.៥២៦.២៦៥	៣.៨៧០.៣១០
បំណុលពន្ធពន្យារ, សុទ្ធ	៤៥.២៩៥.១៩២	៤០.៣៥០.៩៥២
	៣.៩៥៦.៤៦៧.៥៧៥	**៣.៣៣៤.៣៤៦.០៤៧**
បំណុលចរន្ត		
គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ	៩៧៥.៦៤៣.៦៦១	៨៦២.៨៩៣.៤៣៧
ប្រាក់កម្ចី	១៣២.៧៦៨.៣៦០	១៧២.១៣៨.៣៦០
ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវទូទាត់	៩២.៥០២.២០២	៦០.៣៩៣.៤០២
	១.២០០.៩១៤.២២៣	**១.០៩៥.៤២៥.១៩៩**
បំណុល និងមូលធនសរុប	**៩.០៤២.២៣៥.០៦៨**	**៧.៦៣១.៧៣៧.៤៩៧**

របាយការណ៍លទ្ធផល របស់អគ្គិសនីកម្ពុជា សម្រាប់ចុងឆ្នាំ២០១៨

	២០១៨ ពាន់រៀល	២០១៧ ពាន់រៀល
ចំណូល		
ចំណូលពីការលក់ថាមពលអគ្គិសនី	៥.៥៣២.៤២៨.៤៨២	៤.៦២១.៤១៧.៣២២
ចំណូលពីការតភ្ជាប់បណ្តាញអគ្គិសនី	៣៨.៥៩៥.៦១៤	៣៥.២៨៤.១៩៩
ចំណូលផ្សេងៗ	៩៩.៨០៤.៦០២	២៣.១១៥.៥៣១
	៥.៦៧០.៨២៨.៦៩៤	**៤.៦៧៩.៨១៧.០៥២**
ចំណាយប្រតិបត្តិការ		
ការទិញថាមពល	(៣.៩៨៣.១៨១.២៤០)	(៣.៣១៤.០៦៣.៩១០)
ចំណាយថ្លៃប្រេង	(១៤.៦៩៩.០១០)	(៥.២៧៧.៣៨៣)
ចំណាយលើពន្ធនាំចូល	(១៧.៦៥៤.៦៥៣)	(២៥.៥០០.៣៨៧)
ចំណាយលើប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេងៗ	(២៨២.២៥៧.៦៧២)	(២២៧.២៦៨.៤៧១)
ចំណាយប្រតិបត្តិការផ្សេងៗ	(៣៥៦.៩១៣.៩៦៩)	(៣២៧.៦៧១.៧៩១)
រំលស់លើទ្រព្យរោងចក្រ និងបរិក្ខារ	(១៧២.៣៤៨.៨៨២)	(១៣៧.៤០៩.៨៧៧)
រំលស់លើទ្រព្យសកម្មអរូបិយ	(៧៦៤.៥៦៤)	(៣៧៩.២០៧)
ចំណេញប្រតិបត្តិការ	៨៤៣.០០៨.៧០៨	៦៥២.២៤៦.៤២៦
ចំណាយបរិញ្ញាវត្ថុ-សុទ្ធ	(៨០.៩០២.០៥៤)	(៧៦.៣៩២.៥៦៨)
ប្រាក់ចំណេញមុនដកពន្ធ	៧៦២.១០៦.៦៥៤	៥៦៥.៨៥៣.៨៥៨
ពន្ធលើប្រាក់ចំណេញ	(១៥២.៤២១.៣៣១)	(១០១.៣៣៥.៦៦២)
ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ/ចំណូលរួមសរុប	**៦០៩.៦៨៥.៣២៣**	**៤៦៤.៥១៨.១៩៦**

របាយការណ៍លំហូរសាច់ប្រាក់ របស់អគ្គិសនីកម្ពុជា សម្រាប់ចុងឆ្នាំ២០១៨

	២០១៨ ពាន់រៀល	២០១៧ ពាន់រៀល
លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ		
ប្រាក់ចំណេញប្រចាំឆ្នាំ	**៦០៩.៦៨៥.៣២៣**	**៤៦៤.៥១៨.១៩៦**
និយ័តកម្មលើ:		
ចំណាយរំលស់	១៧៣.១១៣.៨៨៦	១៣៧.៧៨៨.៦៨៨
ចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណបរទេស	(១១.៨៧៣.២១០)	៣២.៦១៧.៣៦៥
ខាតលើការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ	៥៩០.៩២៩	២៥.២៥៦
ចំណាយការប្រាក់	១០២.០១៨.៦៥៧	៩២.០៧៣.១៦៥
ចំណាយលើពន្ធប្រាក់ចំណេញ	១៥២.៤២១.៣៣១	១០១.៣៣៥.៦៦២
សំវិធានធនសម្រាប់		
បន្ថែមលើគណនីអាក្រក់ និងជាប់សង្ស័យ	៥០៣.៩៧០	(២.១៧៣.៣៥៧)
អត្ថប្រយោជន៍ចូលនិវត្តន៍	៦៥៥.៩៥៥	៥២០.៣៦៣
សន្និធិខូច	១០.០៧៦.៧៩១	៦.០៨១.៦៧៣
	១.០៣៧.១៩៣.១៩២	**៨៣២.៧៨៧.០០៧**

របាយការណ៍លំហូរសាច់ប្រាក់ របស់អគ្គិសនីកម្ពុជា សម្រាប់ចុងឆ្នាំ២០១៨(ត)

	២០១៨ ពាន់រៀល	២០១៧ ពាន់រៀល
ប្រែប្រួលនៃ:		
គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ	(១៨៩.០៤០.២៩៧)	(៦៥.០២៥.៧៤៣)
សន្និធិ	(១៩៩.១៧៧.១៧១)	(១៩២.៣៧៥.៣៩៣)
គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ	១១៩.២៧១.៩៨៩	២០៨.៩៤៨.២៩៦
ប្រាក់កក់របស់អតិថិជន	៣៩.៦០១.៩១០	៣១.១៩៤.០៨០
សាច់ប្រាក់សន្ធទទួលបានពីប្រតិបត្តិការ	៨០២.៨៤៩.៦២៣	៨១៥.៥២៨.២៨៧
ការប្រាក់បានបង់	(១០៣.៥៤០.៤២២)	(៧២.១៥៥.៦៧៦)
ពន្ធបានបង់	(១១៥.៣៦៨.២៩១)	(១១៦.៧៣៦.៨៥៤)
សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ	**៥៨៣.៤៤០.៩១០**	**៦២៦.៦៣៦.១១៧**
លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ		
ការទិញ ទ្រព្យ រោងចក្រ និងបរិក្ខារ	(៨២៨.២៧៣.៨១១)	(៨០៩.៥១៤.៦៧១)
ការទិញ ទ្រព្យអរូបី	(២.០១២.១៥៤)	(៥៤៩.៨៨៥)
សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ	៣៤៨.៨៩២	៣៧.១៥៦
ប្រាក់បញ្ញើរមានការកំណត់	(២១.៤៧៣.១២០)	១៤.៩១២.០៦២
ដើមទុនរក្សាទុក	(១១.៨៩៨.៤២៤)	(៩.០០៨.៨៨៩)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ	**(៤៦៣.៣០៨.២១៧)**	**៤០៤.១២៣.៤២៧**
លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន		
សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី	៨៦.៦២៣.៨០៨	៩.២៤៩.៣១២
ការទូទាត់សងប្រាក់កម្ចី	(១៥៥.២៩០.៩៦០)	(១០៩.៦៦២.១១៩)
ជំនួយដែលទទួលបាន	៦៧.៥៨០.៤៣៩	៣៥.៧៥៨.៩៨៥
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន	**(៤១.០៧៧.៧១៣)**	**(៦៤.៦៥៧.៨២២)**
ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល	**៧៩.៥៥៤.៩៨០**	**១៥៧.៨៥៤.៨៦៨**
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ	**១.១៥០.៧៩១.៦៨៣**	**៩៩២.៩៣៦.៨១៥**
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ	**១.២៣០.៣៤៦.៦៦៣**	**១.១៥០.៧៩១.៦៨៣**

ការអភិវឌ្ឍន៍ ធនធានមនុស្សរបស់អគ្គិសនីកម្ពុជា

១- ការបណ្តុះបណ្តាលក្នុងប្រទេស

២- ការបណ្តុះបណ្តាលចំណេះដឹងក្រៅប្រទេស

ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អាទិភាពយ៉ាងសំខាន់ទៅលើការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា ហើយត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។ ជាការចូលរួមចំណែក និងយកចិត្តទុកដាក់ក្នុងការគាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល អគ្គិសនីកម្ពុជា ក្រៅពីខិតខំជំនះរាល់ឧបសគ្គនានា ដើម្បីធានានូវនិរន្តភាព នៃការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅកម្ពុជា ការពង្រឹង និងលើកកំពស់ចំណេះដឹង សមត្ថភាពជំនាញការងាររបស់និយោជិត ត្រូវបានចាត់ទុកជាអាទិភាពមួយយ៉ាងសំខាន់សម្រាប់គាំទ្រដល់ការចូលរួមអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យថាមពលឲ្យកាន់តែមានភាពរីកចម្រើន ក្នុងនោះអគ្គិសនីកម្ពុជា បានផ្តល់ឱកាសដល់និយោជិតខ្លួនតាមរយៈការផ្តល់អាហារូបករណ៍ទាំងផ្នែកភាសាបរទេស ជំនាញបច្ចេកទេស និងជំនាញដឹកនាំ គួបផ្សំនឹងអាហារូបករណ៍ដែលដៃគូរពាក់ព័ន្ធផ្តល់ជូនតាមរយៈរាជរដ្ឋាភិបាល ដើម្បីធានាបាននូវធនធានសម្រាប់បន្តវេនទៅអនាគតដែលប្រកបដោយសក្តានុពល។



ការអភិវឌ្ឍន៍ធនធានមនុស្ស

អគ្គិសនីកម្ពុជាបានយកចិត្តទុកដាក់ជាចំបងលើការអភិវឌ្ឍន៍ធនធានមនុស្សដើម្បីជំរុញដល់ការសម្រេចឲ្យបាននូវទស្សនៈវិស័យ និងបេសកកម្មរបស់អគ្គិសនីកម្ពុជានៅពេលបច្ចុប្បន្ន និងនាពេលអនាគត។ ធនធានមនុស្សរបស់អគ្គិសនីកម្ពុជា បាននឹងកំពុងតែអភិវឌ្ឍខ្លួនតាមរយៈវគ្គបណ្តុះបណ្តាលរបស់អគ្គិសនីកម្ពុជាផ្ទាល់ និងតាមរយៈ ដៃគូរអភិវឌ្ឍន៍របស់អគ្គិសនីកម្ពុជា។ អគ្គិសនីកម្ពុជាបានត្រៀមរួចជាស្រេចក្នុងការបញ្ជូននិយោជិតរបស់ខ្លួនដើម្បីទទួលចំណេះដឹងទូទៅ និងអភិវឌ្ឍន៍ជំនាញចាំបាច់ទាំងក្នុងប្រទេស និងក្រៅប្រទេស។

ការបណ្តុះបណ្តាលក្នុងប្រទេស

១_វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី

វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី ជាថ្នាលបណ្តុះបណ្តាលដ៏សំខាន់សម្រាប់និយោជិតអគ្គិសនីកម្ពុជា នៅរាជធានីភ្នំពេញ ក៏ដូចជានៅតាមបណ្តាអង្គភាពអគ្គិសនីខេត្តចំណុះឲ្យអគ្គិសនីកម្ពុជា។ ដើម្បីជំរុញ និងលើកកម្ពស់ចំណេះដឹង និយោជិតគ្រប់រូបអាចធ្វើការស្នើសុំសិក្សាបន្ថែមលើជំនាញ ដើម្បីបន្ថែមលើចំណេះដឹង ដែលខ្លួនមានទៅវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី ដែលបានលើកឡើងជារៀងរាល់ឆ្នាំ។ គោលបំណងចំបងគឺដើម្បីអភិវឌ្ឍន៍ និងស្រូបយកចំណេះដឹងថ្មីក្នុងការបង្កើនប្រសិទ្ធភាពការងាររបស់ខ្លួនឲ្យអស់លទ្ធភាព។ នៅឆ្នាំ២០១៨ វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី បានបណ្តុះបណ្តាលដល់សិក្ខាកាមជានិយោជិតមកពីគ្រប់នាយកដ្ឋាន និងអង្គភាព អគ្គិសនីខេត្ត-ក្រុងចំនួន ១.៥៧៤នាក់ លើវគ្គជំនាញចំនួន ២០៦ វគ្គ និង ៨៥ មុខវិជ្ជា។ សិក្ខាកាមទាំងនោះត្រូវបានបណ្តុះបណ្តាលលើជំនាញផ្សេងៗគ្នា ក្នុងនោះរួមមានៈ សិក្ខាកាម ៨២២ នាក់ ខាងផ្នែកបណ្តាញចែកចាយអគ្គិសនី សិក្ខាកាម ៣១៨ នាក់ ខាងផ្នែកបរិធានការពារ សិក្ខាកាម ២១៨ នាក់ ខាងផ្នែកសុវត្ថិភាពលក្ខ សិក្ខាកាម ៨២ នាក់ ខាងផ្នែកផលិតថាមពល សិក្ខាកាម ៣៥៩ នាក់ ខាងផ្នែកបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ សិក្ខាកាម ៦២ នាក់ ខាងផ្នែកកម្មវិធីកុំព្យូទ័រ និងសិក្ខាកាម ៨៥ នាក់ ខាងផ្នែកភាសាអង់គ្លេសបច្ចេកទេស។

២_មជ្ឈមណ្ឌលអូស្ត្រាលី សម្រាប់ការបណ្តុះបណ្តាល

នៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ អគ្គិសនីកម្ពុជា ក៏បានផ្តល់នូវវគ្គភាសាអង់គ្លេសរយៈពេលខ្លី ដោយសហការជាមួយមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការបណ្តុះបណ្តាលហៅកាត់ ACE ដើម្បីផ្តល់ឲ្យនិយោជិតនូវវគ្គសិក្សាបន្ថែមលើភាសាអង់គ្លេសក្រៅម៉ោងការងារបស់ខ្លួន ដោយមកទល់ពេលនេះ និយោជិតចំនួន ៧៥៤ រូប បានសិក្សាវគ្គភាសាអង់គ្លេសនេះ។ ក្រៅពីវគ្គសិក្សាភាសាអង់គ្លេស អគ្គិសនីកម្ពុជា ក៏លើកទឹកចិត្តឲ្យនិយោជិត ដែលមានចំណាងចង់បន្ថែមចំណេះដឹងលើផ្នែកកម្មវិធីកុំព្យូទ័រផ្សេងៗ សម្រាប់ប្រើប្រាស់ក្នុងការងារឲ្យកាន់តែមានប្រសិទ្ធភាព។

ការបណ្តុះបណ្តាលក្រៅប្រទេស

អគ្គិសនីកម្ពុជា ក៏បានបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិដទៃទៀត ដើម្បីកៀរគរយក អាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនានាលើជំនាញអគ្គិសនី ជំនាញកុំព្យូទ័រ និងភាសាបរទេស ដើម្បីបង្កើនចំណេះដឹងឲ្យទូលំទូលាយ និងស្វែងយល់បន្ថែមពីបច្ចេកវិទ្យាថ្មីៗ ដល់និយោជិតរបស់ខ្លួន។ គិតត្រឹមឆ្នាំ២០១៨ អគ្គិសនីកម្ពុជាបានបង្កើតនូវឱកាសសិក្សាក្រៅប្រទេសដល់និយោជិតគ្រប់លំដាប់ថ្នាក់ក្នុងការស្វែងរក ចំណេះដឹងបន្ថែមតាមរយៈអាហារូបករណ៍ នានាដូចជា៖

- អាហារូបករណ៍ <**អ្នកឯកទេសវ័យក្មេងអគ្គិសនីកម្ពុជា**> ជាអាហារូបករណ៍ ដែលអគ្គិសនីកម្ពុជា ជាអ្នកវ៉ាប់រងលើរាល់ការចំណាយថ្លៃ សម្រាប់សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដោយឲ្យនិយោជិតធ្វើការសិក្សានៅបណ្តាប្រទេសជាសមាជិកអាស៊ាន។ អាហារូបករណ៍ <**អ្នកឯកទេសវ័យក្មេងអគ្គិសនីកម្ពុជា**> បានបង្កើតឡើងនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៥ ក្នុងគោលបំណង ដើម្បីជំរុញ និងលើកទឹកចិត្តដល់និយោជិត ដែលមានចំណាងចង់បង្កើនចំណេះដឹងខ្លួន ហើយយកចំណេះដឹងនេះ មកអភិវឌ្ឍប្រទេសកម្ពុជា។ មកត្រឹមពេលនេះ អគ្គិសនីកម្ពុជា បានបញ្ជូននិយោជិតចំនួន ០៧ រូប ទៅសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសថៃឡង់ដ៏ និងប្រទេសសឹង្ហបុរី។

- តាមរយៈរាជរដ្ឋាភិបាលកម្ពុជា ជំនួយឥតសំណងរបស់ប្រទេសជប៉ុនសម្រាប់អាហារូបករណ៍នៃការអភិវឌ្ឍន៍ធនធានមនុស្ស ហៅកាត់ (JDS) ដែលប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសទាំង ១២ ក្នុងតំបន់ ដែលទទួលបានផ្តែផ្តាំពីអាហារូបករណ៍នេះ។ អគ្គិសនីកម្ពុជា បានបញ្ជូននិយោជិតខ្លួនចំនួន ២០រូប ទៅសិក្សានៅប្រទេសជប៉ុន ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញជាច្រើន។

តារាងទី ១ : ការិតវប្បធម៌របស់និយោជិត-កម្មករ អគ្គិសនីកម្ពុជាពីឆ្នាំ ២០១៣ - ២០១៨

ប្រភេទ	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
បណ្ឌិត	៤	៤	៤	៥	៦	៦
អនុបណ្ឌិត	១៤១	១៥១	១៦៥	១៧៩	១៩២	១៨៨
វិស្វករ និងបរិញ្ញាប័ត្រផ្សេងៗ	៩៣៤	១.០៧៨	១.២៤០	១.៣៨៣	១.៦៥២	១.៧៧៥
បច្ចេកទេសជំនាញ	៥៧០	៧៣៦	៩១៧	១.១៧៥	១.៣៧២	១.៥៨៥
កម្មករជំនាញ	១៨០	១៧៨	១៧៣	១៦៨	១៥៩	១៥៨
មធ្យមសិក្សាទុតិយភូមិ និង គ្មានជំនាញ	១.៣៩៨	១.៤៣៨	១.៥២៧	១.៦៨៧	១.៧០២	១.៧៣០
សរុប	**៣.២២៧**	**៣.៥៨៥**	**៤.០២៦**	**៤.៥៩៧**	**៥.០៨៣**	**៥.៤៤២**

- អគ្គិសនីកម្ពុជា បានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រុមហ៊ុន CHMC (China National Heavy Machinery Corporation) ដែលជាក្រុមហ៊ុនដៃគូអភិវឌ្ឍន៍ ដើម្បីផ្តល់អាហារូបករណ៍ទៅសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសចិន រហូតមកដល់ពេលនេះ អគ្គិសនីកម្ពុជា បានបញ្ជូននិយោជិតចំនួន ៦ រូប ទៅសិក្សានៅប្រទេសចិន លើថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកបច្ចេកទេសអគ្គិសនី។

- ក្រសួង វ៉ែ និងថាមពល បានចុះអនុស្សរណៈយោគយល់ជាមួយក្រុមហ៊ុន China Southern Power Grid Co., Ltd (CSG) ដើម្បីផ្តល់អាហារូបករណ៍ដល់មន្ត្រី និងនិយោជិតអគ្គិសនីកម្ពុជា ក្នុងការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសចិន ដោយបានផ្តល់អាហារូបករណ៍ចំនួន ១៥ កន្លែងមកអគ្គិសនីកម្ពុជា។

ក្រៅពីអាហារូបករណ៍ទាំងនេះ និយោជិតអគ្គិសនីកម្ពុជា ក៏អាចស្វែងរកអាហារូបករណ៍ដោយខ្លួនឯង ដើម្បីទៅបន្តការសិក្សាទាំងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត នៅតាមសកលវិទ្យាល័យនានានៅក្រៅប្រទេស ។ រហូតមកដល់ពេលនេះ មាននិយោជិត ដែលកំពុងសិក្សា និងបញ្ចប់ការសិក្សាចំនួន ០៨ រូប នៅប្រទេសថៃឡង់ដ៏ និងប្រទេសចិន ។

បន្ថែមពីនេះ អគ្គិសនីកម្ពុជាបានរៀបចំកម្មវិធីចែករំលែកបទពិសោធន៍ជំនាញទន់ (Soft Skill) ក្រោមប្រធានបទ “ឥទ្ធិពលនៃការទំនាក់ទំនងក្នុងភាពជាអ្នកដឹកនាំ”កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨។ ក្រោមការដឹកនាំរបស់ ឯកឧត្តម កែវ រតន: រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គិសនីកម្ពុជា បានធ្វើជាវាគ្មិនផ្ទាល់ដោយមានការចូលរួមពីនិយោជិតអគ្គិសនីកម្ពុជាចំនួន១៣៣៥ នាក់។ ការចែករំលែកបទពិសោធន៍នេះពិតជាបានផ្តល់ចំណេះដឹងយ៉ាងទូលំទូលាយលើជំនាញទន់ (Soft Skill) ដើម្បីអនុវត្តការងារប្រចាំថ្ងៃកាន់តែមានប្រសិទ្ធភាព និងទំនាក់ទំនាក់ល្អប្រសើររវាងថ្នាក់ដឹកនាំ និងនិយោជិតអគ្គិសនីកម្ពុជា។

អាជីវកម្មស្នូល

១- មធ្យោបាយផលិតថាមពល
និងការផ្គត់ផ្គង់ថាមពលអគ្គិសនី

២- ខ្សែបណ្តាញបញ្ជូន

៣- ខ្សែបណ្តាញចែកចាយ

“ បង្ហោះបាយផលិតថាមពលនិងការផ្គត់ផ្គង់ថាមពលអគ្គិសនី

១- ប្រភពផលិតកម្ម

២- តម្រូវការថាមពល និងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងបណ្តាញជាតិ

១- ប្រភពផលិតកម្ម

ក្នុងឆ្នាំ ២០១៨ អានុភាពតម្លើងសរុបប្រមាណ ២.៥៦២ មេហ្គាវ៉ាត់ ដែលក្នុងនោះរួមមាន ៖ វារីអគ្គិសនី ប្រមាណ ១.៣៣០ មេហ្គាវ៉ាត់ ធ្យូងថ្មប្រមាណ ៥៣៥ មេហ្គាវ៉ាត់ ប្រេងឥន្ធនៈប្រមាណ ២៥១ មេហ្គាវ៉ាត់ ជីវម៉ាសប្រមាណ ៣១ មេហ្គាវ៉ាត់ ពន្លឺព្រះអាទិត្យ ១០ មេហ្គាវ៉ាត់ និងនាំចូលពីប្រទេសជិតខាង ដូចជាប្រទេសថៃឡង់ដ៏ ប្រទេសវៀតណាម និងប្រទេសឡាវ សរុបប្រមាណ ៨០៩ មេហ្គាវ៉ាត់។ ថាមពលផលិតសរុបប្រមាណ ៩.៤២៧ ជីហ្គាវ៉ាត់ម៉ោង ក្នុងនោះប្រភពពីវារីអគ្គិសនីមាន ៥០,២% ប្រភពធ្យូងថ្ម ៣២,៣% ប្រភពប្រេងឥន្ធនៈ ៣,៣% ប្រភពជីវម៉ាស់ ០,៥% ថាមពលពន្លឺព្រះអាទិត្យ ០,២% និង ការនាំចូលពីប្រទេសជិតខាង ១៣,៦% ។ជាលទ្ធផលនៃការអភិវឌ្ឍន៍ប្រភពអគ្គិសនីក្នុងស្រុក បានធ្វើឲ្យការនាំចូលថាមពលពីប្រទេសជិតខាង ថយចុះគួរកត់សំគាល់ពី ៦២% នៅឆ្នាំ២០១០ មកត្រឹម ១៣,៦% នៅឆ្នាំ២០១៨ និងការប្រើប្រាស់ប្រេងឥន្ធនៈថយចុះយ៉ាងគំហុកពី ៣៥% មកត្រឹម ៣,៣% និងមានកំណើនផលិតកម្មសរុបប្រចាំឆ្នាំប្រមាណ២៣% បើធៀបនឹងឆ្នាំ២០១៧។

២- តម្រូវការថាមពល និងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងបណ្តាញជាតិ

នៅចុងឆ្នាំ២០១៨ នេះ “បណ្តាញជាតិ” កម្ពុជាក្រោយពីបានភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីតង់ស្យុងខ្ពស់ប្រទេសវៀតណាម ភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីតង់ស្យុងខ្ពស់ប្រទេសថៃឡង់ដ៏ និងភ្ជាប់ជាមួយប្រភពវារីអគ្គិសនីនៅខេត្តកំពង់ស្ពឺ កោះកុង ស្ទឹងត្រែង និងពោធិ៍សាត់ ប្រភពវារីអគ្គិសនីនៅតំបន់ជួរភ្នំគិរីរម្យ និងជួរភ្នំកំចាយ ព្រមទាំងភ្ជាប់ជាមួយប្រភពអគ្គិសនីផលិត ដោយធ្យូងថ្មនាំចូលនៅខេត្តព្រះសីហនុ ការផ្គត់ផ្គង់អគ្គិសនីរបស់ “បណ្តាញជាតិ” នេះ បានគ្របដណ្តប់ផ្ទៃលើរាជធានី / ខេត្តចំនួន ១៨ គឺ ៖ ភ្នំពេញ កណ្តាល កំពង់ស្ពឺ តាកែវ កំពត កែប ព្រះសីហនុ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម និងកោះកុង រួចហើយ និងបានបញ្ជូនទៅផ្គត់ផ្គង់ខេត្តចំនួន ៤ ទៀតគឺ៖ ត្បូងឃ្មុំ ព្រៃវែង កំពង់ធំ និងប៉ៃលិន ដែលមានអានុភាពតម្រូវការអតិបរមាប្រមាណ ១.៥៣៧ មេហ្គាវ៉ាត់ និងថាមពល

ផលិត ៩.៤២៧ ជីហ្គាវ៉ាត់ម៉ោង ហើយតំបន់គ្របដណ្តប់ទាំងនោះមានដូចខាងក្រោម៖

អគ្គិសនីភ្នំពេញ (ប្រព័ន្ធភ្នំពេញ) ភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ ប្រព័ន្ធអគ្គិសនីភ្នំពេញផ្គត់ផ្គង់ពីបណ្តាញជាតិ តាមរយៈអនុស្ថានីយតង់ស្យុង ២៣០ គីឡូវ៉ុលដូចជា៖ អនុស្ថានីយទី៤ អនុស្ថានីយទី៦ និង អនុស្ថានីយទី៧ ជាមួយនឹងអានុភាពសរុបប្រមាណ ៩០០ មេហ្គាវ៉ាត់ ព្រមទាំងផលិតកម្មដោយប្រេងមានប្រមាណ ១៩៤ មេហ្គាវ៉ាត់ ដោយបញ្ចុះមកក្នុងប្រព័ន្ធភ្នំពេញ តាមអនុស្ថានីយតង់ស្យុង ១១៥ គីឡូវ៉ុល ដែលរួមមាន៖ អនុស្ថានីយទី១ អនុស្ថានីយទី២ អនុស្ថានីយទី៣ អនុស្ថានីយទី៤ អនុស្ថានីយទី៥ អនុស្ថានីយទី៦ អនុស្ថានីយទី៧ អនុស្ថានីយទី៨និងអនុស្ថានីយទី១០។ តំបន់ស្ថិតក្នុងការគ្រប់គ្រងរបស់អគ្គិសនីភ្នំពេញរួមមាន ៖ រាជធានីភ្នំពេញ តំបន់ជាយក្រុងជុំវិញក្រុងភ្នំពេញ និងទីប្រជុំជនក្រុងតាខ្មៅ ខេត្តកណ្តាល។

នៅឆ្នាំ២០១៨ តម្រូវការអានុភាពអតិបរមារបស់ប្រព័ន្ធភ្នំពេញប្រមាណ ៨៨៧ មេហ្គាវ៉ាត់ផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ៦៩៥.៧៥៦ ។ ប្រព័ន្ធភ្នំពេញបានទាញថាមពលពីប្រភពបណ្តាញជាតិប្រមាណ ៩.០៦៤ ជីហ្គាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០១៨ និងមានត្រឹម ៧.៣៩៦ ជីហ្គាវ៉ាត់ម៉ោង ក្នុងឆ្នាំ ២០១៧ ។

អគ្គិសនីសៀមរាប សៀមរាប គឺជាតំបន់ទាក់ទាញភ្ញៀវទេសចរណ៍ និងមានទីតាំងស្ថិតនៅ ភាគពាយ័ព្យនៃប្រទេសកម្ពុជា។ អគ្គិសនីសៀមរាប ត្រូវបានផ្ទេរមកនៅក្រោម ការគ្រប់-គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ១៩៩៥។ ការផ្គត់ផ្គង់អគ្គិសនី នៅខេត្តសៀមរាប បានមកពីការផលិតដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ខ្លួន និងពីអនុស្ថានីយអគ្គិសនីស្រុកពួក ដែលបាននាំចូលថាមពលពីប្រទេសថៃឡង់ដ៏តាមខ្សែបញ្ជូន ១១៥ គីឡូវ៉ុល តាំងពីឆ្នាំ ២០០៧។ ប្រព័ន្ធអគ្គិសនីសៀមរាប បានភ្ជាប់ជាមួយបណ្តាញជាតិនៅឆ្នាំ ២០១៣។

ចំណុចសំខាន់ៗនៃប្រតិបត្តិការរបស់ប្រព័ន្ធអគ្គិសនីសៀមរាបសម្រាប់ឆ្នាំ២០១៨មានដូចជា ៖ សមត្ថភាព

ផ្គត់ផ្គង់ប្រមាណ ១១០ មេហ្គាវ៉ាត់ បានមកពីបណ្តាញជាតិ និង ១១ មេហ្គាវ៉ាត់ បានមកពីផលិតកម្មដោយរោងចក្រផ្ទាល់ខ្លួន។ តម្រូវការប្រើប្រាស់ អានុភាពជាអតិបរមា ១១២ មេហ្គាវ៉ាត់ ។ ប្រភពថាមពលផលិតនៅក្នុងប្រព័ន្ធទាំងអស់ សរុបប្រមាណ ៧៧៧ ជីហ្គាវ៉ាត់ម៉ោង ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ២.៦៦១ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ៧៦.០២៣។

អគ្គិសនីខេត្តព្រះសីហនុ ខេត្តព្រះសីហនុ គឺជាតំបន់ទេសចរណ៍ ដែលមានឆ្នេរសមុទ្រស្អាតជាប់ចំណាត់ថ្នាក់លេខ១ ស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា។ អគ្គិសនីខេត្តព្រះសីហនុ ត្រូវបានផ្ទេរមកនៅ ក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៦ ។ កន្លងមកប្រព័ន្ធអគ្គិសនីក្រុងព្រះសីហនុ ជាប្រព័ន្ធដាច់ដោយឡែកពីគេ និងទទួលការផ្គត់ផ្គង់ពីរោងចក្រផលិតអគ្គិសនីក្នុងខេត្ត ដែលមានអានុភាពតម្លើងសរុប ២០ មេហ្គាវ៉ាត់។ នៅចុងឆ្នាំ ២០១១ ប្រព័ន្ធនេះ បានតភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីកំពត ដែលទទួលថាមពលពីបណ្តាញជាតិ ព្រមទាំងថាមពលនាំចូលពីប្រទេសវៀតណាម។ ចុងឆ្នាំ ២០១២ និងដើមឆ្នាំ ២០១៣ ប្រព័ន្ធអគ្គិសនីខេត្តព្រះសីហនុ ត្រូវបានផ្គត់ផ្គង់ដោយផ្ទាល់ពីបណ្តាញជាតិ តាមរយៈខ្សែបញ្ជូន ២៣០ គីឡូវ៉ុល ពីអនុស្ថានីយកំពត ទៅអនុស្ថានីយស្ទឹងហាវ និងខ្សែបញ្ជូន ១១៥ គីឡូវ៉ុល ពីអនុស្ថានីយស្ទឹងហាវទៅអនុស្ថានីយក្រុងព្រះសីហនុ។ ក្នុងឆ្នាំ២០១៨ អគ្គិសនីខេត្តព្រះសីហនុ បានទទួលការផ្គត់ផ្គង់ពីបណ្តាញជាតិប្រមាណ ៩០ មេហ្គាវ៉ាត់ និងពីផលិតកម្មដោយ រោងចក្រផលិតអគ្គិសនីក្នុងខេត្ត ២០ មេហ្គាវ៉ាត់ ដែលនាំឲ្យមានការកើនឡើងនូវលទ្ធភាពផ្គត់ផ្គង់របស់ប្រព័ន្ធទៅតំបន់ផ្សេងទៀតនិងសេវាកម្មជាច្រើននៅក្នុងខេត្តព្រះសីហនុ ។ ចំណុចសំខាន់ៗនៃប្រតិបត្តិការរបស់ប្រព័ន្ធអគ្គិសនីខេត្តព្រះសីហនុ សម្រាប់ឆ្នាំ២០១៨ មានដូចតទៅ ៖ ផលិតកម្មថាមពលប្រចាំឆ្នាំមាន ៥១៥ ជីហ្គាវ៉ាត់ម៉ោង។ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១២១ មេហ្គាវ៉ាត់ ជាមួយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ១.០១១ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ២៥.២៧៧។

អគ្គិសនីកំពង់ចាម កំពង់ចាម ជាខេត្តដែលប្រកបដោយដីមានជីវជាតិសម្រាប់ចម្ការកៅស៊ូ មានទីតាំងស្ថិតនៅភាគខាងកើតនៃប្រទេសកម្ពុជា។ អគ្គិសនីកំពង់ចាម ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨។ ក្នុងឆ្នាំ ១៩៩៦ ប្រព័ន្ធអគ្គិសនីកំពង់ចាម ត្រូវបានផ្គត់ផ្គង់ ដោយរោងចក្រផលិតអគ្គិសនីក្នុងខេត្ត។ លុះដល់ឆ្នាំ ២០១១ ផ្នែកមួយចំនួននៃប្រព័ន្ធនេះ បានទទួលថាមពល ដែលនាំចូលពីប្រទេសវៀតណាម ។ អគ្គិសនីកំពង់ចាម បានភ្ជាប់មកបណ្តាញជាតិបញ្ជូននៅឆ្នាំ២០១៣។ ចំណុចសំខាន់ៗ

នៃប្រតិបត្តិការរបស់ប្រព័ន្ធអគ្គិសនីកំពង់ចាមសម្រាប់ឆ្នាំ២០១៧ មានដូចតទៅ ៖ សមត្ថភាពផ្គត់ផ្គង់ប្រមាណ ៩០ មេហ្គាវ៉ាត់ បានមកពីបណ្តាញជាតិ និង ៨ មេហ្គាវ៉ាត់ បានមកពីផលិតកម្ម ដោយរោងចក្រផលិតអគ្គិសនីក្នុងខេត្ត។ ផលិតកម្មថាមពលប្រចាំឆ្នាំសរុបប្រមាណ ១០៣ ជីហ្គាវ៉ាត់ម៉ោង និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៣៥ មេហ្គាវ៉ាត់ ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ៨៧២ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២២.៥៦៦។

សាខាមេមត់ និងពញ្ញាក្រែក ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីសម្រាប់ស្រុកមេមត់ និងពញ្ញាក្រែក មានទីតាំងស្ថិតនៅខេត្តកំពង់ចាម និងប្រើប្រាស់ប្រព័ន្ធបណ្តាញតង់ស្យុងមធ្យម ២២ គីឡូវ៉ុល ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនី នៅតំបន់ទាំងពីរនេះត្រូវបាននាំចូលពីប្រទេសវៀតណាម ចាប់ពីឆ្នាំ២០០២ ដែលមានអានុភាពផ្គត់ផ្គង់តាមកិច្ចសន្យា ១០ មេហ្គាវ៉ាត់។ ក្នុងឆ្នាំ ២០១៨ ថាមពលនាំចូលមានចំនួន ៥៨ ជីហ្គាវ៉ាត់ម៉ោង ព្រមទាំងប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុលមានប្រវែងសរុបចំនួន ៥៦៥ គីឡូម៉ែត្រ ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៣ មេហ្គាវ៉ាត់ និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២០.២៥៦ ។

អគ្គិសនីបាត់ដំបង បាត់ដំបង ជាខេត្តដែលឈានមុខគេនិងមានសក្តានុពលសេដ្ឋកិច្ចផ្នែកកសិកម្ម ជាពិសេសគឺផលិតកម្មស្រូវអង្ករ។ ខេត្តនេះមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ អគ្គិសនីបាត់ដំបង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០០។ អគ្គិសនីបាត់ដំបង បានគ្របដណ្តប់លើខ្សែបញ្ជូនរងក្នុងខេត្តពោធិ៍សាត់។ ខ្សែបញ្ជូន ១១៥ គីឡូវ៉ុល សម្រាប់នាំចូលថាម-ពលអគ្គិសនីពីប្រទេសថៃឡង់ដ៏ ត្រូវបានភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនអគ្គិសនីសៀមរាប និងបន្ទាយមានជ័យក្នុងឆ្នាំ ២០០៧ ព្រមទាំងភ្ជាប់បន្តទៅបណ្តាញជាតិបញ្ជូនក្នុងឆ្នាំ២០១២ ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តបាត់ដំបង បានពីបណ្តាញជាតិ តាមរយៈអនុស្ថានីយបាត់ដំបង (CPG) និងអនុស្ថានីយបាត់ដំបង (CPTL) ដោយមានសមត្ថភាពសរុប ១៨៥ មេហ្គាវ៉ាត់ ពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ប្រហែលជិត ២ មេហ្គាវ៉ាត់ ។ ក្នុងឆ្នាំ ២០១៨ ប្រព័ន្ធអគ្គិសនីបាត់ដំបងមានថាមពលផលិតសរុបប្រមាណ ៣៩៥ ជីហ្គាវ៉ាត់ម៉ោង ព្រមទាំងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៧៤ មេហ្គាវ៉ាត់ ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ២.៥៣៩ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៥២.៣៨៧ ។

អគ្គិសនីបន្ទាយមានជ័យនិងសាខាមង្គលបុរី បន្ទាយមានជ័យ មានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ អគ្គិសនីបន្ទាយមានជ័យ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តបន្ទាយមានជ័យ បានពីការនាំចូលពីប្រទេសថៃឡង់ដ៏ និងការផលិតថាមពលពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ក្នុងឆ្នាំ២០០៧ ។ បន្ទាប់មកប្រព័ន្ធអគ្គិសនីរបស់ខេត្តនេះ បានតភ្ជាប់ថាមពលពីបណ្តាញជាតិបញ្ជូននៅឆ្នាំ២០១៣ ។ នៅឆ្នាំ ២០១៨ ការផ្គត់ផ្គង់ ៩០ មេហ្គាវ៉ាត់ បានមកពីបណ្តាញជាតិបញ្ជូន (ពីអនុស្ថានីយបន្ទាយមានជ័យ និងអនុស្ថានីយ IE) និង ៣ មេហ្គាវ៉ាត់ ទៀតបានពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់។ ថាមពលនាំចូលសរុបគឺ ១៣៩ ជីហ្គាវ៉ាត់ម៉ោង ដែលតម្រូវការប្រើប្រាស់អានុភាពអតិបរមា ៣៣ មេហ្គាវ៉ាត់។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុលមានប្រវែងសរុបចំនួន ៥២០ គីឡូម៉ែត្រ និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២៩.១៣១។

អគ្គិសនីស្ទឹងត្រែង ស្ទឹងត្រែង គឺជាខេត្តដាច់ស្រយាលមួយនិងមានប្រជាជនរស់នៅរអ៊ើលៗឃ្លាតៗពីគ្នាដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា។ អគ្គិសនីស្ទឹងត្រែង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា នៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០០៣។ ប្រព័ន្ធអគ្គិសនីក្រុងស្ទឹងត្រែង បានតភ្ជាប់ទៅប្រព័ន្ធ អគ្គិសនីប្រទេសឡាវ តាមរយៈតង់ស្យុង ២២ គីឡូវ៉ុល តាំងពីឆ្នាំ ២០១០។ ក្នុងឆ្នាំ២០១៨ សមត្ថភាពផ្គត់ផ្គង់សរុបគឺ ៨៥ មេហ្គាវ៉ាត់ (ដែលប្រហែលជិត ២ មេហ្គាវ៉ាត់ ផ្គត់ផ្គង់

ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និង ៤ មេហ្គាវ៉ាត់ នាំចូលពីប្រទេសឡាវ)។ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២៧ មេហ្គាវ៉ាត់ និងថាមពលផលិតសរុប ៩៤ ជីហ្គាវ៉ាត់ម៉ោង។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ៧៩៩ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១០.៧៨២។

អគ្គិសនីរតនគិរី រតនគិរី ស្ថិតនៅជាប់ព្រំដែនខ្ពង់រាបកណ្តាល នៃប្រទេសវៀតណាម និងប្រទេសឡាវ។ អគ្គិសនីរតនគិរីត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣ ។ ក្នុងឆ្នាំ ២០១៨ ប្រព័ន្ធអគ្គិសនីរតនគិរី មានអានុភាពតម្លើង ៤ មេហ្គាវ៉ាត់ ពីរោងចក្រវារីអគ្គិសនីរបស់អគ្គិសនីកម្ពុជាផ្ទាល់និងរោងចក្រផលិតថាមពលក្នុងខេត្តប្រមាណ ៨ មេហ្គាវ៉ាត់ បាននាំចូលពីប្រទេសវៀតណាម តាមរយៈខ្សែបញ្ជូនរងតង់ស្យុង ៣៥ គីឡូវ៉ុល ។ នៅឆ្នាំ ២០១៨ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៨ មេហ្គាវ៉ាត់ថាមពលផលិត និងនាំចូលសរុបប្រចាំឆ្នាំប្រមាណ ៦៤ ជីហ្គាវ៉ាត់ម៉ោង ។ ប្រវែងខ្សែបណ្តាញចែកចាយ ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ៨០៣ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៩.៦៦៥។

អគ្គិសនីតាកែវ និងសាខាអន្លង់សោម តាកែវ មានទីតាំងស្ថិតនៅតំបន់វាលរាបភាគខាងត្បូងនៃប្រទេសកម្ពុជា។ អគ្គិសនីតាកែវ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០០។ ខ្សែបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល ចេញពីប្រទេសវៀតណាម និងអនុស្ថានីយតាកែវ ត្រូវបានដាក់ឲ្យដំណើរការនៅថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០០៩ ដើម្បីនាំចូលថាមពលពីប្រទេសវៀតណាម។ នៅឆ្នាំ២០១៨ ការផ្គត់ផ្គង់ពីបណ្តាញជាតិមានប្រមាណ ៤៥ មេហ្គាវ៉ាត់ ហើយពីរោងចក្រផលិតអគ្គិសនីប្រើប្រេងប្រមាណជិត ២ មេហ្គាវ៉ាត់ ។ នៅឆ្នាំ២០១៨ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២៨មេហ្គាវ៉ាត់ ដែលប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ៩០៩ គីឡូម៉ែត្រ ថាមពលផលិតដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ការនាំចូល និងទិញពីបណ្តាញជាតិបញ្ជូនសរុបប្រចាំឆ្នាំ ១០៧ ជីហ្គាវ៉ាត់ម៉ោង ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២៥.៧៥៨។

អគ្គិសនីកំពត កំពត មានទីតាំងស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា។ អគ្គិសនីកំពត ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣។ ផលិតកម្មពីរោងចក្រប្រើប្រេងរបស់អគ្គិសនីកំពត និងការនាំចូលថាមពលពីប្រទេសវៀតណាម តាមរយៈខ្សែបណ្តាញតង់ស្យុង ២២ គីឡូវ៉ុល ឆ្លងកាត់ស្រុកកំពង់ត្រាច ត្រូវបានប្រើសម្រាប់ផ្គត់ផ្គង់ឲ្យក្រុងកំពត។ ក្នុងឆ្នាំ ២០១១ ការផ្គត់ផ្គង់ពីបណ្តាញជាតិមានប្រមាណ ៤៥ មេហ្គាវ៉ាត់។ នៅឆ្នាំ ២០១៨ ថាមពលផលិត ដែលផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ការនាំចូល និងការទិញពីបណ្តាញជាតិបញ្ជូនមានសរុប ១០៩ ជីហ្គាវ៉ាត់ម៉ោង ហើយតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២១ មេហ្គាវ៉ាត់ ប្រវែងខ្សែបណ្តាញចែកចាយតង់-ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ៦៧៣ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៥.៤៧៨។

សាខាកំពង់ត្រាច ប្រព័ន្ធអគ្គិសនីកំពង់ត្រាច ស្ថិតនៅក្នុងខេត្តកំពត និងនាំចូលអគ្គិសនីពីប្រទេសវៀតណាម តាំងពីឆ្នាំ ២០០២ ។ ក្នុងឆ្នាំ២០១៤ ប្រព័ន្ធអគ្គិសនីកំពង់ត្រាច ត្រូវបានភ្ជាប់ជាមួយបណ្តាញជាតិបញ្ជូន។ នៅឆ្នាំ២០១៨ អានុភាពជាវតាមកិច្ចសន្យាគឺ ១០ មេហ្គាវ៉ាត់ ហើយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ១៥៦ គីឡូម៉ែត្រ មានថាមពលផលិតសរុប ១៩ ជីហ្គាវ៉ាត់ម៉ោង និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៤ មេហ្គាវ៉ាត់ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៧.៣៤៤។

អគ្គិសនីព្រៃវែង ព្រៃវែង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា ។ អគ្គិសនីព្រៃវែង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣ ។ ប្រព័ន្ធអគ្គិសនីព្រៃវែង មានប្រភពពីរោងចក្រអគ្គិសនីផ្ទាល់ខ្លួន ដែលមានអានុភាពតម្លើងប្រមាណជិត១ មេហ្គាវ៉ាត់ (ក្នុងឆ្នាំ ២០០៣) និងអានុភាពនាំចូលពីវៀតណាម (ក្នុងឆ្នាំ ២០០៩)។ ក្រោយពីដាក់ឲ្យដំណើរការបណ្តាញអគ្គិសនីក្នុងគម្រោងជនបទ ខេត្តព្រៃវែងទទួលបានការផ្គត់ផ្គង់ពីប្រព័ន្ធអគ្គិសនីកំពង់ចាម (ក្នុងឆ្នាំ ២០១៣) ប្រព័ន្ធអគ្គិសនីភ្នំពេញ សម្រាប់ផ្គត់ផ្គង់តំបន់តាមបណ្តោយផ្លូវជាតិលេខ ៨ (ក្នុងឆ្នាំ ២០១៤) និងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម សុវណ្ណភូមិ (ក្នុងឆ្នាំ ២០១៥) ។ ក្នុងឆ្នាំ២០១៨ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុង

ទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ៨៦៩ គីឡូម៉ែត្រ និងតម្រូវការអានុភាពអតិបរមា ២៧ មេហ្គាវ៉ាត់ ព្រមទាំងថាម-ពលផលិត និងនាំចូលប្រមាណ ១៣៨ ជីហ្គាវ៉ាត់ម៉ោង ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៧.៣៩២ ។

អគ្គិសនីក្រចេះ អគ្គិសនីក្រចេះ ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី២០ ខែមេសា ឆ្នាំ ២០១១។ ប្រព័ន្ធអគ្គិសនីក្រចេះ ជាប្រព័ន្ធនៅដាច់ដោយឡែក ដែលផ្គត់ផ្គង់ដោយរោងចក្រផលិតថាមពលអគ្គិសនីផ្ទាល់ខ្លួន ដែលមានអានុភាពតម្លើងជិត ១ មេហ្គាវ៉ាត់ (ក្នុងឆ្នាំ ២០១១) និងពីប្រព័ន្ធអគ្គិសនីកំពង់ចាម (ក្នុងឆ្នាំ ២០១៥)។ ក្រោមការគ្រប់គ្រងដោយអគ្គិសនីកម្ពុជា នៅឆ្នាំ២០១៨ ថាមពលទិញ និងនាំចូលប្រចាំឆ្នាំប្រមាណ ៦១ ជីហ្គាវ៉ាត់ម៉ោង និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ប្រហែល ១៣ មេហ្គាវ៉ាត់ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ៨២៣ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១១.៨៩៥។

សាខាស្ទឹងសែន ប្រព័ន្ធអគ្គិសនីស្ទឹងសែន ស្ថិតនៅស្រុកស្ទឹងសែន ខេត្តក្រចេះ។ ប្រព័ន្ធនេះ បានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាមប្រមាណ ៥ មេហ្គាវ៉ាត់ ដោយមានថាមពលផលិតប្រចាំឆ្នាំ ១៦ ជីហ្គាវ៉ាត់ម៉ោង និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៣ មេហ្គាវ៉ាត់ ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ២១៨ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣.៧២២។

អគ្គិសនីស្វាយរៀង ស្វាយរៀង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា។ អគ្គិសនីស្វាយរៀង ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០០៣ ។ អគ្គិសនីស្វាយរៀង ត្រូវបានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាម (ក្នុងឆ្នាំ២០០៣) ពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់អានុភាពផលិតសរុបប្រមាណ ៨ មេហ្គាវ៉ាត់ (ក្នុងឆ្នាំ ២០០៦) និងពីរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មសុវណ្ណភូមិ (ក្នុងឆ្នាំ ២០១៥) ។ នៅឆ្នាំ ២០១៨ ថាមពលនាំចូល និងផលិតដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ គឺ ២៧៧ ជីហ្គាវ៉ាត់ម៉ោង ដែលមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២២ មេហ្គាវ៉ាត់ ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ៦៩៥ គីឡូម៉ែត្រ ព្រមទាំងបានផ្គត់ផ្គង់ដល់អតិថិជន គ្រប់ប្រភេទចំនួន ៤៩.៦៣២។

សាខាបាវិត ប្រព័ន្ធអគ្គិសនីបាវិត ស្ថិតនៅខេត្តស្វាយរៀង

និងទទួលការផ្គត់ផ្គង់ថាមពលតាមរយៈ: ការនាំចូលពីប្រទេសវៀតណាម។ នៅឆ្នាំ២០១៨ អានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ១៦ មេហ្គាវ៉ាត់ និងមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២៩ មេហ្គាវ៉ាត់ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៦.០៣៤ ។

អគ្គិសនីមណ្ឌលគិរី អគ្គិសនីមណ្ឌលគិរី ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១០។ អានុភាពតម្លើង ៣៧០ គីឡូវ៉ាត់ ផលិតដោយរោងចក្រវារីអគ្គិសនីអានុភាពផលិតដោយម៉ាស៊ីនឌីយ៉ែសែល ៣០០ គីឡូវ៉ាត់ និង អានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ១ មេហ្គាវ៉ាត់ ។ ក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅឆ្នាំ២០១៨ ថាមពលផលិត និងនាំចូលសរុប ៧ ជីហ្គាវ៉ាត់ម៉ោង និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមាជាង ៦ មេហ្គាវ៉ាត់។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុល មានប្រវែងសរុបចំនួន ៣៣៩ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៤.៥៤៦។

សាខាកែវសីមា អគ្គិសនីកែវសីមា ជាសាខាអគ្គិសនីស្ថិតនៅក្នុងស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ ការផ្គត់ផ្គង់ថាមពលគឺតាមរយៈ: ការនាំចូលពីប្រទេសវៀតណាម ដែលអានុភាពបញ្ជូញតាមកិច្ចសន្យា ០,៤ មេហ្គាវ៉ាត់ ។ ថាមពលនាំចូលគឺ ១១ ជីហ្គាវ៉ាត់ម៉ោង និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមាជិត ១ មេហ្គាវ៉ាត់ ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុលមានប្រវែងសរុបចំនួន ១៣១ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៤.៣៨៩។

អគ្គិសនីកំពង់ស្ពឺ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ សាខាកំពង់ស្ពឺត្រូវបានបង្កើតជាអង្គភាពខេត្តខណៈដែលសាខានេះកាលពីពេលកន្លងមក ស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងអគ្គិសនីភ្នំពេញ។ អង្គភាពនេះទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធអគ្គិសនីក្នុងខេត្តកំពង់ស្ពឺ និងតំបន់តាមបណ្តោយផ្លូវជាតិលេខ៤ ដែលចែកចាយថាមពលដល់អនុស្ថានីយកំពង់ស្ពឺ។ ក្នុងឆ្នាំ២០១៨ សមត្ថភាពផ្គត់ផ្គង់ប្រមាណ ៤៥ មេហ្គាវ៉ាត់ បានមកពីបណ្តាញជាតិ ដែលថាមពលផលិតប្រចាំឆ្នាំគឺ ១៥៥ ជីហ្គាវ៉ាត់ម៉ោង និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៦៤ មេហ្គាវ៉ាត់ ជាមួយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ គីឡូវ៉ុល និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ គីឡូវ៉ុលមានប្រវែងសរុបចំនួន ៨០២ គីឡូម៉ែត្រ ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៨.៧៥៦។

តារាងទី ២ : អនុភាពតម្លើង និងអនុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)

ឆ្នាំ / ទីតាំង			អនុភាព	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
បណ្តាញជាតិ			**តម្លើង**	**១.៤១៤**	**១.៤៥៨**	**១.៤៦២**	**២.០៤៧**	**២.៥១៥**	**២.៥៦៥**
			បញ្ចេញ	**១.១៥៣**	**១.៧៥៤**	**១.៨៤២**	**២.០១៨**	**២.០៨៦**	**២.៤៨៥**
ភ្នំពេញ			តម្លើង	១.២១៩	១.៧២៧	១.៨៤១	១.៩៧៦	២.៣៨៦	២.៤១៦
			បញ្ចេញ	៩៦៨	១.៥៣១	១.៧៧៩	១.៩០៥	១.៩៦៥	២.៣៨៥
អគ្គិសនីកម្ពុជា	ឯកជន	ប្រេង	តម្លើង	៨៨	៨៨	៨១	៨១	៨១	៨១
			បញ្ចេញ	៨១	៨១	៧៥	៧៥	៧៥	៧៥
CUPL	ឯកជន	ប្រេង	តម្លើង	៣៧	៣៧	-	-	-	-
			បញ្ចេញ	៣២	៣២	-	-	-	-
KEP	ឯកជន	ប្រេង	តម្លើង	៨៩	៨៩	៨៩	៨៩	៨៩	៨៩
			បញ្ចេញ	៨៣	៨៣	៨៣	៨៣	៨៣	៨៣
CITY Power	ឯកជន	ប្រេង	តម្លើង	៨	-	-	-	-	-
			បញ្ចេញ	៧	-	-	-	-	-
CEP	ឯកជន	ប្រេង	តម្លើង	៨៩	៨៩	៨៩	៨៩	៨៩	៨៩
			បញ្ចេញ	៨៥	៨៥	៨៥	៨៥	៨៥	៨៥
COLBEN	ឯកជន	ប្រេង	តម្លើង	២០	២០	១៨	១៨	១៨	១៨
			បញ្ចេញ	១០	១០	១០	១០	១០	១០
គិរីរម្យ ១	ឯកជន	វារី	តម្លើង	១២	១២	១២	១២	១២	១២
			បញ្ចេញ	១១	១១	១១	១១	១១	១១
គិរីរម្យ ៣	ឯកជន	វារី	តម្លើង	១៨	១៨	១៨	១៨	១៨	១៨
			បញ្ចេញ	១៨	១៨	១៨	១៨	១៨	១៨
កំចាយ	ឯកជន	វារី	តម្លើង	១៩៨	១៩៨	១៩៨	១៩៨	១៩៨	១៩៨
			បញ្ចេញ	១៩៨	១៩៨	១៩៨	១៩៨	១៩៨	១៩៨
អាតៃ	ឯកជន	វារី	តម្លើង	១២០	១២០	១២០	១២០	១២០	១២០
			បញ្ចេញ	១២០	១២០	១២០	១២០	១២០	១២០
ឫស្សីជ្រុំក្រោម	ឯកជន	វារី	តម្លើង	៣៣៨	៣៣៨	៣៣៨	៣៣៨	៣៣៨	៣៣៨
			បញ្ចេញ	១៦៩	៣៣៨	៣៣៨	៣៣៨	៣៣៨	៣៣៨
តាតៃ	ឯកជន	វារី	តម្លើង	-	២៨៦	២៨៦	២៨៦	២៨៦	២៨៦
			បញ្ចេញ	-	២៨៦	២៨៦	២៨៦	២៨៦	២៨៦
សេសាន២	ឯកជន	វារី	តម្លើង	-	-	-	-	៤០០	៤០០
			បញ្ចេញ	-	-	-	-	៥០	៤០០
CEL	ឯកជន	ធ្យូងថ្ម	តម្លើង	១២០	១២០	១២០	១២០	១២០	១២០
			បញ្ចេញ	១០០	១០០	១០០	១០០	១០០	១០០
CIIDG	ឯកជន	ធ្យូងថ្ម	តម្លើង	-	២៧០	២៧០	៤០៥	៤០៥	៤០៥
			បញ្ចេញ	-	១២៥	២៥១	៣៧៧	៣៧៧	៣៧៧
សុវណ្ណភូមិ	ឯកជន	ធ្យូងថ្ម	តម្លើង	១០	១០	១០	១០	១០	១០
			បញ្ចេញ	៨	៨	៨	៨	៨	៨
Sunseap	ឯកជន	ព្រះអាទិត្យ	តម្លើង	-	-	-	-	១០	១០
			បញ្ចេញ	-	-	-	-	១០	១០

តារាងទី ២ : អនុភាពតម្លើង និងអនុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)(ត)

ឆ្នាំ / ទីតាំង			អនុភាព	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
ថៃឡង់ដ៏	នាំចូល		ព្រមព្រៀង	-	-	១២០	១២០	១២០	១២០
			បញ្ចេញ	-	-	១២០	១២០	១២០	១២០
វៀតណាម	នាំចូល		ព្រមព្រៀង	២០០	២០០	២០០	២០០	២០០	២០០
			បញ្ចេញ	១៧០	២០០	២០០	២០០	២០០	២០០
ឡាវ	នាំចូល		ព្រមព្រៀង	-	-	-	-	-	៣០
			បញ្ចេញ	-	-	-	-	-	៣០
អគ្គិសនី ខេត្ត-ក្រុង			**តម្លើង**	**១៩៥**	**២៣១**	**១២១**	**១២១**	**១២៩**	**១៩៩**
			បញ្ចេញ	**១៨៥**	**២២៣**	**១១៣**	**១១៣**	**១២១**	**១៩០**
អគ្គិសនីសៀមរាប	អ.ក	ប្រេង	តម្លើង	១១	១១	១១	១១	១១	១១
			បញ្ចេញ	១១	១១	១១	១១	១១	១១
	នាំចូល		ព្រមព្រៀង	៨០	៨០	-	-	-	-
			បញ្ចេញ	៨០	៨០	-	-	-	-
អគ្គិសនីកំពង់ចាម	ឯកជន	ប្រេង	តម្លើង	៨	៨	៨	៨	៨	៨
			បញ្ចេញ	៥	៥	៥	៥	៥	៥
	នាំចូល		ព្រមព្រៀង	២	២	២	២	២	-
			បញ្ចេញ	២	២	២	២	២	-
អគ្គិសនីខេត្តព្រះសីហនុ	អ.ក	ប្រេង	តម្លើង	៦	៦	៦	៦	៦	៦
			បញ្ចេញ	៥	៥	៥	៥	៥	៥
	ឯកជន	ប្រេង	តម្លើង	១៨	១៨	១៨	១៨	១៨	១៨
			បញ្ចេញ	១០	១០	១០	១០	១០	១០
	ឯកជន	ជីវម៉ាស់	តម្លើង	-	-	-	-	២	២
			បញ្ចេញ	-	-	-	-	២	២
អគ្គិសនីតាកែវ	អ.ក	ប្រេង	អ.ក	២	២	២	២	២	២
			បញ្ចេញ	២	២	២	២	២	២
អគ្គិសនីបាត់ដំបង	អ.ក	ប្រេង	តម្លើង	២	២	២	២	២	៣
			បញ្ចេញ	២	២	២	២	២	៣
	នាំចូល		ព្រមព្រៀង	២០	២០	-	-	-	-
			បញ្ចេញ	២០	២០	-	-	-	-
អគ្គិសនីបន្ទាយមានជ័យ	អ.ក	ប្រេង	តម្លើង	៣	៣	៣	៣	៣	៣
			បញ្ចេញ	៣	៣	៣	៣	៣	៣
	នាំចូល		ព្រមព្រៀង	២០	២០	-	-	-	-
			បញ្ចេញ	២០	២០	-	-	-	-
អគ្គិសនីកំពត	អ.ក	ប្រេង	តម្លើង	៣	៣	៣	៣	៣	៣
			បញ្ចេញ	៣	៣	៣	៣	៣	៣
សាខាកំពង់ត្រាច	នាំចូល		ព្រមព្រៀង	១០	១០	១០	១០	១០	១០
			បញ្ចេញ	១០	១០	១០	១០	១០	១០

តារាងទី ២ : អនុភាពតម្លើង និងអនុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)(ត)

ឆ្នាំ / ទីតាំង			អនុភាព	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
អគ្គិសនីកំពង់ស្ពឺ	ឯកជន	ជីវម៉ាស់	តម្លើង	-	-	៦	៦	៦	២៣
			បញ្ចេញ	-	-	៦	៦	៦	២២
សាខាពញាក្រែក	នាំចូល		ព្រមព្រៀង	៥	៥	៥	៥	៥	១០
			បញ្ចេញ	៥	៥	៥	៥	៥	១០
សាខាមេមត់	នាំចូល		ព្រមព្រៀង	៥	៥	៥	៥	៥	៥
			បញ្ចេញ	៥	៥	៥	៥	៥	៥
អគ្គិសនីព្រៃវែង	អ.ក	ប្រេង	តម្លើង	២	២	២	២	២	២
			បញ្ចេញ	២	២	២	២	២	២
	នាំចូល		ព្រមព្រៀង	៣	៣	៣	៣	៣	៣
			បញ្ចេញ	៣	៣	៣	៣	៣	៣
អគ្គិសនីស្ទឹងត្រែង	អ.ក	ប្រេង	តម្លើង	២	២	២	២	២	២
			បញ្ចេញ	២	២	២	២	២	២
	ឯកជន	ជីវម៉ាស់	តម្លើង	-	-	-	-	៨	៨
			បញ្ចេញ	-	-	-	-	៨	៨
	ឯកជន	ជីវម៉ាស់	តម្លើង	-	-	-	-	២	២
			បញ្ចេញ	-	-	-	-	២	២
	នាំចូល		ព្រមព្រៀង	៨	៨	៦	៦	៦	៦
			បញ្ចេញ	៨	៨	៦	៦	៦	៦
អគ្គិសនីស្វាយរៀង	អ.ក	ប្រេង	តម្លើង	១	១	១	១	១	១
			បញ្ចេញ	១	១	១	១	១	១
	នាំចូល		ព្រមព្រៀង	៨	៧	៨	៨	៨	៧
			បញ្ចេញ	៨	៧	៨	៨	៨	៧
សាខាបាវិត	នាំចូល		ព្រមព្រៀង	១៦	១៦	១៦	១៦	១៦	១៦
			បញ្ចេញ	១៦	១៦	១៦	១៦	១៦	១៦
អគ្គិសនីក្រចេះ	អ.ក	ប្រេង	តម្លើង	១	១	១	១	១	១
			បញ្ចេញ	១	១	១	១	១	១
	ឯកជន	ប្រេង	តម្លើង	៣	-	-	-	-	-
			បញ្ចេញ	១	-	-	-	-	-
សាខាស្នួល	នាំចូល		ព្រមព្រៀង	៨	៨	៥	៥	៥	៥
			បញ្ចេញ	៨	៨	៥	៥	៥	៥

តារាងទី ២ : អនុភាពតម្លើង និងអនុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)(ត)

ឆ្នាំ / ទីតាំង			អនុភាព	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
ក្រៅបណ្តាញជាតិ			តម្លើង	១១	១៤	១៤	១៤	១៤	២២
			បញ្ចេញ	១១	១២	១២	១២	១២	២០
អគ្គិសនីរតនគិរី	ឯកជន	ប្រេង	តម្លើង	-	៣	៣	៣	៣	៣
			បញ្ចេញ	-	១	១	១	១	១
	អ.ក	វារី	តម្លើង	១	១	១	១	១	១
			បញ្ចេញ	១	១	១	១	១	១
	នាំចូល		ព្រមព្រៀង	៨	៨	៨	៨	៨	១៣
			បញ្ចេញ	៨	៨	៨	៨	៨	១៣
អគ្គិសនីមណ្ឌលគិរី	អ.ក	ប្រេង	តម្លើង	០,៣	០,៣	០,៣	០,៣	០,៣	០,៣
			បញ្ចេញ	០,៣	០,៣	០,៣	០,៣	០,៣	០,៣
	អ.ក		តម្លើង	០,៤	០,៤	០,៤	០,៤	០,៤	០,៤
			បញ្ចេញ	០,៤	០,៤	០,៤	០,៤	០,៤	០,៤
	នាំចូល		ព្រមព្រៀង	១	១	១	១	១	២
			បញ្ចេញ	១	១	១	១	១	២
សាខាកែវសីមា	នាំចូល		ព្រមព្រៀង	០,៤	០,៤	០,៤	០,៤	០,៤	២
			បញ្ចេញ	០,៤	០,៤	០,៤	០,៤	០,៤	២
សរុប			**តម្លើង**	**១.៤២៥**	**១.៤៧២**	**១.៤៧៦**	**២.១១១**	**២.៥២៤**	**២.៥៨៧**
			បញ្ចេញ	**១.១៦៤**	**១.៧៦៦**	**១.៤០៤**	**២.០៣០**	**២.០៤៨**	**២.៥០៥**
ជាភាគរយ(%)				**៨២%**	**៥0%**	**៥៦%**	**៥៦%**	**៨៣%**	**៥៧%**



រូបភាពទី១ : អនុភាពតម្លើងតាមប្រភេទពីឆ្នាំ២០១៣-២០១៨

តារាងទី ៣ : ថាមពលផលិតពីប្រភពរោងចក្រ និងការនាំចូល (GWh)

ឆ្នាំ / ទីតាំង	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
បណ្តាញជាតិ	**៣.៦៦០**	**៤.៤៧៧**	**៥.៦៥៨**	**៦.៥៦៦**	**៧.៦០៣**	**៩.៣៧៣**
អគ្គិសនីកម្ពុជា	៣៦	២៦	៩	៧២	៣៥	៥៦
CUPL	៧៣	៣៥	៥	-	-	-
គិរីរម្យ ១	៤៥	៣៩	៣៥	៤២	៤៣	៤៣
កំចាយ	៤៦៣	៤២៨	៣៦៣	៤៣៨	៤០៦	៥៣៣
គិរីរម្យ ៣	៩០	៨០	៧៩	៨២	៨៧	៩០
អារតៃ	២៦៧	៣២៧	១០៦	២១៩	២៩៣	៤២៧
ឫស្សីជ្រុំក្រោម	១៣៨	៨៦៦	៨៣១	៩២៣	៩៩៨	១.៤៨៩
តាតៃ	-	១០៩	៧៣៦	៨៥៩	៨៩៩	១.១៥២
សេសានក្រោម២	-	-	-	-	-	១.០៣២
KEP	១៩០	៨០	៥១	១១៥	១១៨	១០៣
CITY POWER	១៣	-	-	-	-	-
CEP	១៤៨	៩៦	៦៦	១៦០	១០៣	១១៨
COLBEN	១៩	១១	៨	១៦	៨	៥
S.L Garment	៦	១	៨	៧	៥	១
Sunseap	-	-	-	-	៥	១៦
សុវណ្ណភូមិ	៣០	៨៣	៣៨	៥២	៣៨	១៨
CEL	១៣៩	៦៥៨	៦២០	៥៧៨	៦៥៥	៥០៣
CIIDG	-	១៦៧	១.៨៧៨	១.៧៦៦	២.៨៧៧	២.៥៣៩
ថៃឡង់ដ៏	៨១៧	៣៥០	១៣៩	១៨៧	៨៧	២១២
វៀតណាម	១.៣២៩	៨៧៩	៨០៨	៧៣៧	៧១០	៧២៨
PP Sugar	១	១០	២៣	២៣	៣៨	៤៨
សៀមរាប	៤	៥	៨	៨	២	៦
ព្រះសីហនុ	២៥	៩	៣	១១	០	៦
កំពង់ចាម	៣២	៨	០,២	២	០	៨
តាកែវ	០,០៣	០,០២	០,០២	០,០១	០,០១	០,០២
បាត់ដំបង	០,០១	០,០១	០,០១	០,០១	០,០១	០,០២
កំពត	១២	១៥	១២	២៣	០,០៨	១៩
បន្ទាយមានជ័យ	០,១៦	០,០៨	០,០៨	០,១	០,០៨	០,១២
ពញាក្រែក	៣៩	៣០	២២	២៣	២៦	២៧
មេមត់	១៦	១៦	១៩	២២	២៥	២៣
កំពង់ត្រាច	១៧	១៣	៧	១៨	១៧	១៧
ព្រៃវែង	១៥	១៣	៩	៥	២	០,០១
ស្ទឹងត្រែង	១១	១៨	១៨	៣៥	៥៨	៦៦
ស្វាយរៀង	៣៣	១៣៧	១៥៥	១៦៨	១១០	០,០២
បាវិត	៨៧	-	-	-	០	១២៩
ក្រចេះ	១០	១៥	១៥	២០	១៣,៨	០,៣៩
ស្ទឹងល	៩	១០	១១	១២	៧	១១
ក្រៅបណ្តាញជាតិ	**២៨**	**៣៥**	**៤២**	**៤៧**	**៦២**	**៥៣**
មណ្ឌលគិរី	៣	៨	៥	៦	៧	១៣
កែវសីមា	២	៣	៨	៨	៨,២	៨
រតនគិរី	២៣	២៨	៣៣	៣៧	៥១	៣៦
សរុប	**៣.៦៨៨**	**៤.៥១២**	**៥.៧០០**	**៦.៦១៣**	**៧.៦៦៥**	**៩.៤២៧**

តារាងទី ៤ : ការផលិតថាមពលតាមប្រភេទក្នុងឆ្នាំ ២០១៨ (GWh)

ទីតាំង		ប្រេងឥន្ធនៈ	វារីអគ្គិសនី	ជីវម៉ាស់	ធ្យូងថ្ម	ពន្លឺព្រះអាទិត្យ	នាំចូល	សរុប
បណ្តាញជាតិ		**៣០៧,៥៥**	**៤៧២៥,៨៦**	**៥០,៣០**	**១៥,៧៥**	**៣.០៤២,៤០**	**១.២៣១,៣១**	**៩.៣៧៣,១៧**
ភ្នំពេញ	អ.ក	៥៥,៥០	-	-	-	-	-	៥៥,៥០
	ផ.ដ	២៣៦,៤៩	៤.៧២៥,៨៦	៤៨,៧៣	១៥,៧៥	៣.០៤២,៤០	៩៣៩.៤៩	៩.០០៨,៧២
កំពង់ស្ពឺ		-	-	-	-	-	-	-
សៀមរាប		៦,២៥	-	-	-	-	-	៦,២៥
ព្រះសីហនុ		៥,២៦	-	១,១៩	-	-	-	៦,៤៥
កំពង់ចាម		៣,៧៦	-	-	-	-	-	៣,៧៦
តាកែវ		០,០២	-	-	-	-	-	០,០២
បាត់ដំបង		០,០២	-	-	-	-	-	០,០២
កំពត		០,០៨	-	-	-	-	១៨,៩២	១៩,០០
បន្ទាយមានជ័យ		០,១២	-	-	-	-	-	០,១២
ពញាក្រែក		-	-	-	-	-	២៧,៤៨	២៧,៤៨
មេមត់		-	-	-	-	-	២៣,១០	២៣,១០
កំពង់ត្រាច		-	-	-	-	-	១៦,៨៥	១៦,៨៥
ព្រៃវែង		០,០១	-	-	-	-	-	០,០១
ស្វាយរៀង		-	-	-	-	-	៦៥,៥៥	៦៥,៥៦
ស្វាយរៀង		០,០២	-	-	-	-	-	០,០២
បាវិត		-	-	-	-	-	១២៨,៦៦	១២៨,៦៦
ក្រចេះ		០,០១	-	០,៣៨	-	-	០,០១	០,៣៩
ស្ទឹងត្រែង		-	-	-	-	-	១១.២៩	១១,២៩
ក្រៅបណ្តាញ		**-**	**៥,៤៧**	**-**	**-**	**-**	**៤៧,៩៨**	**៥៣,៤៥**
មណ្ឌលគិរី		-	១,៨៣	-	-	-	១១,០៨	១២,៩១
កែវសីមា		-	-	-	-	-	៤,២៤	៤,២៤
រតនគិរី		-	៣,៦៣	-	-	-	៣២,៦៧	៣៦,៣០
សរុប		**៣០៧,៥៦**	**៤.៧៣១,៣៣**	**៥០,៣០**	**១៥,៧៥**	**៣.០៤២,៤០**	**១.២៧៩,២៩**	**៩.៤២៦,៦២**



រូបតាងទី២ : ការផលិតថាមពលតាមប្រភេទ នៅឆ្នាំ២០១៨

តារាងទី ៦ : ថាមពលលក់តាមខេត្ត-ក្រុង (GWh)

ទីតាំង	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
ភ្នំពេញ	២.៥៣១	២.៩៥៦	៣.៧៤៨	៤.២៨៩	៤.៨០៧	៥.៩៨៥
សៀមរាប	២៧០	៣១៩	៣៧៦	៤៤៧	៥១១	៥៧៣
ព្រះសីហនុ	៩៦	១៤១	១៨៦	២៣២	៣០៩	៤៨៨
កំពង់ចាម	៨៤	៨៣	៦៨	៧៥	៩៤	១២៦
តូរង្គឃ្មុំ	-	-	-	-	-	៨
ពញាក្រែក	៣៧	២៩	២៣	២៣	២៦	១៥
មេមត់	១៥	១៥	១៩	២៣	២៣	១៣
ជាំក្រវៀន	-	-	-	-	-	១
តាកែវ	៣៧	៥៤	៩០	៩៤	៨៨	១០២
បាត់ដំបង	១២៧	១៦១	២២២	២៧៨	៣៤៦	៣៧៧
កំពត	២៩	៨៤	៨១	៩៧	១១០	១២២
កំពង់ត្រាច	១៦	១៣	-	-	-	-
ត្បែរវែង	១៨	២០	៨២	៨៥	៧៨	៩៦
បន្ទាយមានជ័យ	៨៧	៧១	១០៦	១១០	១១៨	១២២
ស្ទឹងត្រែង	១០	១២	១៦	៣៥	២៨	៨១
កំពង់ស្រឡៅ	-	-	-	-	២០	៨២
រតនគិរី	២១	២៦	៣១	៣៥	៨៥	៦០
ស្វាយរៀង	២៦	១២៩	១៥៩	១៨៦	២២៩	២៦៧
បាវិត	៨៧	-	-	-	-	-
មណ្ឌលគិរី	៣	៨	៥	៦	៨	១២
កែវសីមា	២	៨	៨	៨	៨	៨
ក្រចេះ	១០	១៥	១៨	២៨	៣៥	៥៩
ស្ទឹងល	៨	១១	១០	៩	១១	១៥
កំពង់ស្ពឺ	៥២	៨៨	១៣៧	៩៨	១១១	១៨៥
សរុប	**៣.៤៨៤**	**៤.១៥២**	**៥.៣៤១**	**៦.១១០**	**៦.៩៩៤**	**៨.៦៧៥**



រូបភាពទី៣ : ថាមពលលក់តាមប្រភេទអតិថិជនសម្រាប់ប្រព័ន្ធអគ្គិសនីកម្ពុជានៅឆ្នាំ ២០១៨

តារាងទី ៥ : អនុភាពអតិបរមាតាមខេត្ត-ក្រុង (MW)

ទីតាំង	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
បណ្តាញជាតិ	៦២៥	៧៨៤	៩៥១	១.០៦៨	១.២៦៩	១.៥៣៧
ភ្នំពេញ	៨៩៣	៥៦៣	៦៧៤	៧៥៧	៧៧៧	៨៨៧
សៀមរាប	៥៧	៥៩	៦៨	៨៣	៨៩	១១២
ព្រះសីហនុ	២៥	៣០	៤០	៤៦	៦៨	១២១
កំពង់ចាម	១៧	១៨	២២	៣២	៣៦	៣៥
ពញាក្រែក	៧	៦	៨	៨	៧	៧
មេមត់	៥	៨	៧	៧	៦	៦
តាកែវ	៩	១៨	២០	២៣	២១	២៨
បាត់ដំបង	២៣	២៦	៤៧	៦៥	៧១	៧៤
កំពត	៦	១៣	១៨	១៦	១៥	២១
កំពង់ត្រាច	៣	៣	៥	៣	៣	៤
ព្រៃវែង	៣	៨	១៨	១៥	២១	២៧
បន្ទាយមានជ័យ	១១	១៩	២៣	២៨	២៦	៣៣
ស្ទឹងត្រែង	៨	៥	៣	៨	១២	២៧
រតនគិរី	៨	៥	៦	៧	១៣	១៨
ស្វាយរៀង	៧	៨	១២	៣០	១៩	២២
ប៉ៃលិន	១៦	១៧	១៧	១៦	២៧	២៩
មណ្ឌលគិរី	១	១	១	២	៤	៦
កែវសីមា	០,៥	១	១	១	១	១
ក្រចេះ	២	៣	៣	៨	៩	១៣
ស្ទឹងល	១	២	២	៣	២	៣
កំពង់ស្ពឺ	-	-	៣៨	៤២	៤៦	៦៤



រូបភាពទី៤ : ខ្សែកោងបន្ទុកប្រើប្រាស់អតិបរមាពីឆ្នាំ ២០១៣-២០១៨ ក្នុងបណ្តាញជាតិ

តារាងទី ៧ : ចំនួនអតិថិជនតាមខេត្ត-ក្រុងពីឆ្នាំ ២០១៣ - ២០១៨

ទីតាំង	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
ភ្នំពេញ	២៩៩.៧៧៤	៣១៩.៤២៣	៥២២.៥១៧	៦១០.៥៨២	៦៥២.៨៥៨	៦៩៥.៧៥៦
សៀមរាប	៣២.៧២៥	៣៦.៦៩៤	៤០.៩៤៩	៤៨.៤៨២	៦១.៧៤៥	៧៦.០២៣
ព្រះសីហនុ	១៣.១៨៦	១៨.២៣៨	១៥.៩៧៥	១៧.៩៣០	២០.១៥៧	២៥.២៧៧
កំពង់ចាម	១៣.០០៣	១៨.៨៧៦	១៦.៩៩៩	១៩.៤៣៦	២១.៣៤១	២២.៥៦៦
ពញាក្រែក	២.៨៤៩	២.៩៩៦	៣.៩៥៨	៦.៦៤៤	៧.៤០១	៨.០៥៨
មេមត់	៥.៣២១	៥.៥៩១	៧.៦០៨	៨.៦៥២	១១.៣២៩	១២.១៩៨
តាកែវ	១៣.០៨១	១៥.៦៣៦	២០.២០៣	២១.៨៩៩	២៣.៧៣២	២៥.៧៥៨
បាត់ដំបង	៤០.៧៣៥	៤២.៣៣៦	៤៥.២១៦	៤៧.៨៩៩	៥០.០៩៣	៥២.៣៨៧
កំពត	១០.៥៥៩	១១.២៣៨	១១.៩៨៩	១៣.១២៨	១៤.២៨៩	១៥.៨៧៨
កំពង់ត្រាច	៣.៨៩៩	៣.៦៧០	៨.១៧៦	៥.៧៥៩	៦.៦៥១	៧.៣៨៤
ព្រៃវែង	៥.៧៩០	៦.១១០	៦.៨៩៧	៦.៧៨២	៧.១២៩	៧.៣៩២
បន្ទាយមានជ័យ	១៨.០២២	១៩.២១៧	២១.១៨៦	២២.៣៨៨	២៣.៥៦៨	២៤.១៣១
ស្ទឹងត្រែង	៨.៦៦៨	៥.៧៨២	៦.២៨០	៧.៨៨៨	៩.៥០៣	១០.៧៨២
រតនគិរី	៨.២៣៣	៨.៧២២	៥.២៣៥	៦.៥០៣	៨.០៧៥	៩.៦៦៥
ស្វាយរៀង	១២.៨៧៤	១៣.៨៩២	១៣.៩៦៨	១៩.៩៦២	២៧.៨១១	៨៤.៦៣២
បាវិត	៣.១៧៤	៣.៨០២	៦.៧៨២	៨.៨៦៥	៥.០៨៣	៦.០៣៤
មណ្ឌលគិរី	២.០៧០	២.១៩៥	២.៣៨៨	២.៦៩២	៣.៧៣៥	៤.៥៤៦
កែវសីមា	១.៣៣៧	១.៥៥៤	១.៧៥៣	១.៩២៦	៣.៨២៥	៤.៣៨៩
ក្រចេះ	៨.៨០៨	៨.៧៧៦	៦.៧០៧	៨.៨៩២	១០.១១៥	១១.៨៩៥
ស្ទឹងលេ	១.១៦៧	១.២៣៨	១.៣១១	១.៨២៧	២.៥៧៦	៣.៧២២
កំពង់ស្ពឺ	១០.៨២៨	១១.១៥៩	១២.៩៩៦	១៨.៤០៩	១៦.៤១០	១៨.៧៥៦
តូរងឃ្មុំ	-	-	-	-	-	៨២៣
សរុប	**៥០២.៨៥៩**	**៥៤១.១៤១**	**៧៧៤.៦១៣**	**៨៩៧.១៧៥**	**៩៨៧.៣៤៦**	**១.០៨៦.៨១២**



រូបភាពទី៥ : ចាមពលចាត់បង់លើប្រព័ន្ធបណ្តាញចែកចាយពីឆ្នាំ ២០១៣-២០១៨



រូបភាពទី ៦ : ប្រភេទអតិថិជនដែលឆ្នាំ ២០១៨

ខ្សែបណ្តាញជាតិបញ្ជូនអគ្គិសនី

ខ្សែបញ្ជូន ១១៥ គីឡូវ៉ុល លើកទីមួយមានប្រវែង ២៣ គីឡូម៉ែត្រ ដែលតភ្ជាប់ពីអនុស្ថានីយចំនួនបី (អនុស្ថានីយទី១ អនុស្ថានីយទី២ និងអនុស្ថានីយទី៣) នៅក្នុងប្រព័ន្ធបណ្តាញរាជធានីភ្នំពេញ បានផ្គត់ផ្គង់ថាមពលក្នុងឆ្នាំ១៩៩៩។ នៅឆ្នាំ២០០២ មានខ្សែបញ្ជូន ១១៥ គីឡូវ៉ុល បន្ថែមមួយទៀត ដែលមានប្រវែង ១១១ គីឡូម៉ែត្រ ត្រូវបានសាងសង់ដើម្បីតភ្ជាប់ពីរោងចក្រវារីអគ្គិសនីគិរីរម្យ ១ មកកាន់អនុស្ថានីយទី១។ គោលបំណងដ៏ចម្បងនៃខ្សែបញ្ជូន ដែលមានតង់ស្យុង ១១៥ គីឡូវ៉ុល ព័ទ្ធជុំវិញរាជធានីភ្នំពេញ គឺដើម្បីផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់រាជធានីភ្នំពេញ និងបង្កើនស្ថិរភាពលើប្រព័ន្ធផ្គត់ផ្គង់ថាមពលក្នុងរាជធានីភ្នំពេញនេះ ដោយតភ្ជាប់ទៅវិញទៅមករវាងអនុស្ថានីយចំនួនបី។

ខេត្តចំនួនបី ស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា មានខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប បានផ្គត់ផ្គង់ថាមពលដោយខ្សែបញ្ជូន ១១៥ គីឡូវ៉ុល មានប្រវែង ១៨៥ គីឡូម៉ែត្រ ដោយនាំចូលថាមពលពីប្រទេសថៃឡង់ដ៏ បើយបានដាក់ឲ្យដំណើរការនៅចុងឆ្នាំ២០០៧។

នៅឆ្នាំ ២០០៩ ខ្សែបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល ជាលើកដំបូងក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលមានប្រវែង ៩៧ គីឡូម៉ែត្រ សម្រាប់នាំថាមពលពីប្រទេសវៀតណាម ដើម្បីយកថាមពលមកផ្គត់ផ្គង់នៅអនុស្ថានីយតាកែវ និងអនុស្ថានីយខាងលិចភ្នំពេញ (អនុស្ថានីយទី៤)។ ប្រព័ន្ធខ្សែបញ្ជូន ១១៥ គីឡូវ៉ុល ដែលតភ្ជាប់អនុស្ថានីយខាងលិចភ្នំពេញ (អនុស្ថានីយទី៤) ទៅភ្ជាប់អនុស្ថានីយទី១ និងអនុស្ថានីយទី២ នៅរាជធានីភ្នំពេញ ត្រូវបានសាងសង់រួច និងដាក់ឲ្យដំណើរការក្នុងឆ្នាំ២០០៩។

នៅឆ្នាំ២០១១ ខ្សែបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល ដែលមានប្រវែង ៧៣ គីឡូម៉ែត្រ ត្រូវបានភ្ជាប់ចេញពីអនុស្ថានីយតាកែវ ទៅអនុស្ថានីយកំពត និងតភ្ជាប់ទៅរោងចក្រវារីអគ្គិសនីកំចាយ តាមខ្សែបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល មួយទៀត ដែលមានប្រវែង ១១ គីឡូម៉ែត្រ ក៏ត្រូវបានដាក់ឲ្យដំណើរការព្រមគ្នាផងដែរ។

> ## ខ្សែបណ្តាញជាតិបញ្ជូនអគ្គិសនី
>
> ១- ខ្សែបញ្ជូនតង់ស្យុង ១១៥ គីឡូវ៉ុល
>
> ២- ខ្សែបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល
>
> ៣- អនុស្ថានីយតង់ស្យុង ១១៥ គីឡូវ៉ុល
>
> ៤- អនុស្ថានីយតង់ស្យុង ២៣០ គីឡូវ៉ុល

ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅខេត្តបាត់ដំបង ត្រូវបានចាប់ផ្តើមដាក់ឲ្យដំណើរការក្នុងខែមេសា ឆ្នាំ ២០១២ ដែលមានប្រវែង ៣០០ គីឡូម៉ែត្រ និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល មួយខ្សែទៀតពីអនុស្ថានីយអូរសោម (ខេត្តកោះកុង) ទៅអនុស្ថានីយខេត្តពោធិ៍សាត់ ស្ថិតក្រោមគម្រោងសាងសង់ដំណើរការ និងផ្ទេរ (BOT) ដែលមានប្រវែង ១៣០ គីឡូម៉ែត្រ កំពុងសាងសង់ ។ ការសាងសង់ខ្សែបណ្តាញ ១១៥ គីឡូវ៉ុល ចេញពីអនុស្ថានីយ ២៣០/១១៥/២២ គីឡូវ៉ុល របស់ក្រុមហ៊ុន CPG ទៅភ្ជាប់ជាមួយអនុស្ថានីយ ១១៥ គីឡូវ៉ុល របស់ក្រុមហ៊ុន CPTL បានដាក់ឲ្យប្រើប្រាស់នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២ ដែលផ្តល់លទ្ធភាពឲ្យបណ្តាញជាតិបញ្ជូនមានសមត្ថភាពពង្រីកវិសាលភាព គ្របដណ្តប់ពីផ្នែកមួយនៃបណ្តាញភាគខាងត្បូង (រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប) ទៅកាន់បណ្តាញភាគខាងជើងឆៀងខាងលិច (ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប) កាត់តាមខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។

នៅឆ្នាំ២០១៣ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុលពីខេត្តកំពត ទៅខេត្តព្រះសីហនុ ស្ថិតក្រោមប្រាក់កម្ចីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) មានប្រវែង ៨៨គីឡូម៉ែត្រ និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល មួយខ្សែទៀតពីភ្នំពេញទៅខេត្តកំពង់ចាម ដែលមានប្រវែង ១១០ គីឡូម៉ែត្រ ត្រូវបានដាក់ឲ្យដំណើរការ។ គម្រោងទាំងនេះ បានធ្វើឲ្យបណ្តាញជាតិគ្របដណ្តប់លើខេត្តចំនួន ២ បន្ថែមទៀតរួមមាន ខេត្តព្រះសីហនុ និងខេត្តកំពង់ចាម។

នៅឆ្នាំ២០១៤ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល ពីអនុស្ថានីយស្ទឹងហាវទៅអនុស្ថានីយខេត្តព្រះសីហនុ ស្ថិតក្រោមប្រាក់កម្ចីរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) មានប្រវែង ១១ គីឡូម៉ែត្រ និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល ពីអនុស្ថានីយឈូក ទៅអនុស្ថានីយបន្ទាយមាស ក្រោមថវិការបស់អគ្គិសនីកម្ពុជា ដែលមានប្រវែង ១២ គីឡូម៉ែត្រ ព្រមទាំងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល ក្នុងគម្រោងខ្សែបញ្ជូនជាកងជុំវិញរាជធានីភ្នំពេញ ដែលភ្ជាប់ពីអនុស្ថានីយទី៦ ទៅអនុស្ថានីយទី៥ ដែលមានប្រវែង ៤៨ គីឡូម៉ែត្រ ស្ថិតក្រោមប្រាក់កម្ចីរបស់ធនាគារចិនអាហារវណ-នីហារវណ ត្រូវបានដាក់ឲ្យដំណើរការជាស្ថាពរ។

នៅឆ្នាំ២០១៥ ខ្សែបញ្ជូន ១១៥ គីឡូវ៉ុល ពីអនុស្ថានីយទី៧ មកអនុស្ថានីយទី២ ក្នុងគម្រោងខ្សែបញ្ជូនកងតង់-ស្យុងខ្ពស់ជុំវិញរាជធានីភ្នំពេញស្ថិតក្រោមប្រាក់កម្ចីធនាគារ

ចិនអាហារ័ណនីហារ័ណ ត្រូវបានបញ្ចប់ការសាងសង់ និងដាក់ឲ្យដំណើរការ ដើម្បីធានាឲ្យបាននូវការបង្កើនភាពជឿជាក់ខ្ពស់លើប្រភពថាមពលនៅតំបន់ភាគខាងត្បូងនៃរាជធានីភ្នំពេញ ។ ខ្សែបញ្ជូនតភ្ជាប់ថ្មីពី អនុស្ថានីយបានហាត ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ ទៅស្រុកកំពង់ស្រឡៅ ខេត្តព្រះវិហារ ប្រទេសកម្ពុជា ត្រូវបានរៀបចំ និងសាងសង់សម្រាប់ខ្សែបញ្ជូនតង់ស្យុង ១១៥ គីឡូវ៉ុល ប៉ុន្តែបញ្ជូនថាមពលអគ្គិសនីនៅកម្រិតតង់ស្យុង ២២ គីឡូវ៉ុល សម្រាប់ដំណាក់កាលដំបូង រហូតដល់ខ្សែបញ្ជូនពីព្រំប្រទល់ឡាវ ទៅអនុស្ថានីយជ័យសែន សាងសង់រួចរាល់។

នៅឆ្នាំ២០១៦ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ពីរាជធានីភ្នំពេញ ទៅក្រុងបាវិតខេត្តស្វាយរៀង និងពីខេត្តកំពង់ចាម ទៅខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងភ្ជាប់បន្តទៅរោងចក្រវារីអគ្គិសនីសេសានក្រោម២ ដែលមានប្រវែងសរុបប្រមាណ ៤២៦ គីឡូម៉ែត្រ បាននឹងកំពុងស្ថិតក្រោមការសាងសង់។ គម្រោងទាំងនោះ ត្រូវបានសាងសង់រួចរាល់ជាស្ថាពរនៅចុងឆ្នាំ២០១៧។

គម្រោងខ្សែបញ្ជូនជុំវិញបឹងទន្លេសាបដែលតភ្ជាប់ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ចាម និងគម្រោងខ្សែបញ្ជូនកងជុំវិញរាជធានីភ្នំពេញជំហានទី២ (ខាងជើងភ្នំពេញ-ជ្រោយចង្វារ-ខាងកើតភ្នំពេញ-ខាងត្បូងភ្នំពេញ) និងគម្រោងខ្សែបញ្ជូនមួយទៀត ដែលតភ្ជាប់ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងព្រំប្រទល់ប្រទេសឡាវ កំពុងស្ថិតក្រោមការសាងសង់។គម្រោងទាំងនេះ ទទួលបាន មូលនិធិពីធនាគារ ចិនអាហារ័ណនីហារ័ណ។

នៅឆ្នាំ២០១៧ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល ដែលភ្ជាប់ពីរោងចក្រផលិតអគ្គិសនីសេសានក្រោម២ មកអនុស្ថានីយស្ទឹងត្រែង និងភ្ជាប់បន្តទៅអនុស្ថានីយក្រចេះ និងអនុស្ថានីយកំពង់ចាម ត្រូវបានដាក់ឲ្យដំណើរការដើម្បីបញ្ជូនថាមពលឲ្យអស់ពីលទ្ធភាព ទៅកាន់ប្រព័ន្ធបណ្តាញជាតិ ដែលអនុញ្ញាតឲ្យខេត្តក្រចេះ និងស្ទឹងត្រែងមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការស្រូបយកថាមពលដោយផ្ទាល់ពីប្រព័ន្ធបណ្តាញជាតិ ជាពិសេសតាមរយៈខ្សែបញ្ជូននេះ ក៏បានបញ្ជូនថាមពលមួយភាគធំមកកាន់រាជធានីភ្នំពេញ ដែលជាទីតាំងសំខាន់នៃបណ្តុំពាណិជ្ជកម្ម ឧស្សាហកម្ម និងការអភិវឌ្ឍន៍ ដែលកំពុងត្រូវការថាមពលអគ្គិសនីដ៏ច្រើនលើសលប់នាពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអនាគត។

នៅឆ្នាំ២០១៧ ការដាក់ឲ្យដំណើរការខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល ប្រវែង ១៤១ គីឡូម៉ែត្រដែលភ្ជាប់ពីអនុស្ថានីយទី៧ ទៅអនុស្ថានីយកំពង់សឹង្ហ រួចបន្តភ្ជាប់ទៅអនុស្ថានីយច្រកម្ទេស បានធ្វើឲ្យខេត្តព្រៃវែង និងខេត្តស្វាយរៀង អាចស្រូបយកថាមពលដោយផ្ទាល់ពីប្រព័ន្ធបណ្តាញជាតិ ដែលធ្វើឲ្យខេត្តទាំងពីរមានឯករាជ្យភាពក្នុងការផ្គត់ផ្គង់អគ្គិសនី ព្រមទាំងអាចកាត់បន្ថយការនាំចូលប្រភពថាមពលពីប្រទេសវៀតណាមបានមួយភាគធំផងដែរ ។

ខ្សែបញ្ជូនអគ្គិសនីតង់ស្យុង ១១៥ គីឡូវ៉ុល ដែលមានប្រវែងប្រមាណ ៥៤ គីឡូម៉ែត្រ តភ្ជាប់ពីព្រំដែនឡាវមកខេត្តព្រះវិហារ ត្រូវបានដាក់ឲ្យដំណើរការនៅឆ្នាំ២០១៧ ។ បន្ទាប់មកអនុស្ថានីយព្រះវិហារទី១ ក៏ត្រូវបានដាក់ឲ្យដំណើរការនៅដើមឆ្នាំ២០១៨ ដើម្បីនាំយកថាមពលអគ្គិសនីពីប្រទេស

ឡាវ តាមរយៈតង់ស្យុងខ្ពស់ មកផ្គត់ផ្គង់នៅខេត្តព្រះវិហារ ព្រមទាំងផ្នែកមួយចំនួននៃខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង។ នេះគឺជាការបើកទំព័រប្រវត្តិសាស្ត្រថ្មីនៃការធ្វើពាណិជ្ជកម្មថាមពលរវាងប្រទេសទាំងពីរ ក្នុងការនាំថាមពលអគ្គិសនីក្នុងកម្រិតតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល ជាលើកដំបូង។

លើសពីនេះទៅទៀត ការសាងសង់ខ្សែបញ្ជូនអគ្គិសនី ១១៥ គីឡូវ៉ុល បន្ថែមតភ្ជាប់ពីអនុស្ថានីយបន្ទាយមាសទៅរោងចក្រស៊ីម៉ងត៍ (ជីបម៉ុងអ៊ីនស៊ី) ក្នុងខេត្តកំពត និងអនុស្ថានីយទី ១០ ដែលបានសាងសង់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ត្រូវបានដាក់ឲ្យដំណើរការនៅក្នុងឆ្នាំ២០១៨ នេះផងដែរ។ សមិទ្ធិផលទាំងនេះ នឹងអាចផ្តល់នូវប្រសិទ្ធិភាព និងស្ថិរភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់សកម្មភាពឧស្សាហកម្មធុនធ្ងន់ ដែលស្របតាមគោលនយោបាយនៃការអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។ ព្រមជាមួយគ្នានេះដែរ ចក្ខុវិស័យ នៃគម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយមួយចំនួននៅរាជធានីភ្នំពេញ កំពង់ចាម ក្រចេះ និងខេត្តកោះកុង ក្រោមហិរញ្ញប្បទានឥណទានរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង(AFD) និងអគ្គិសនីកម្ពុជា បាននឹងកំពុងចាប់ផ្តើមសាងសង់ ហើយគ្រោងនឹងបញ្ចប់ការសាងសង់នៅឆ្នាំ ២០២០ និង ២០២១ ហើយនឹងអាចធ្វើឲ្យប្រព័ន្ធនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅរាជធានីភ្នំពេញក្លាយជាប្រព័ន្ធដ៏មានភាពរឹងមាំ ដែលមានសមត្ថភាពអាចដើម្បីឆ្លើយតបទៅនឹងកំណើនតម្រូវការនៅក្នុងតំបន់នេះ។

តារាងទី ៨ : ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល

I	ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ kV	ចំនួនសៀគ្វី	មុខកាត់ខ្សែ (mm2)	ប្រវែងខ្សែ (km)	ឆ្នាំដំណើរការ	ប្រភពទុន
១	ការភ្ជាប់គ្នារវាង អនុស្ថានីយអគ្គិសនីទី ២, ទី៣, ទី៤, ទី៨, ទី១០ KEP និង CEP (LOOP LINE PHNOM PENH)	២	២ x ២៤០ ២ x ២៥០	៣៨	១៩៩៩ & ២០១៨	WB
២	អនុស្ថានីយកំពង់ស្ពឺ - វារីអគ្គិសនីគីរីរម្យ ១	១	១៥០	៦៥	២០០២	BOT
៣	អនុស្ថានីយកំពង់ស្ពឺ - អនុស្ថានីយទី ៥	១	១៥០	៣៨	២០០២	BOT
៤	ព្រំប្រទល់ថៃ (ARG) - អនុស្ថានីយ IE	២	៤០០	៥	២០០៧	BOT
៥	អនុស្ថានីយ IE - អនុស្ថានីយបន្ទាយមានជ័យ	២	៤០០	៤៩	២០០៧	BOT
៦	អនុស្ថានីយបន្ទាយមានជ័យ-អនុស្ថានីយសៀមរាប	១	៤០០	៨៨	២០០៧	BOT
៧	អនុស្ថានីយបន្ទាយមានជ័យ-អនុស្ថានីយបាត់ដំបង	២	៤០០	៥៧	២០០៧	BOT
៨	វារីអគ្គិសនីគីរីរម្យ ១ - វារីអគ្គិសនីគីរីរម្យ ៣	១	១៥០	៣២	២០១២	BOT
៩	អនុស្ថានីយអគ្គិសនីបាត់ដំបង (CPG - CPTL)	២	២ x ២៥០	១	២០១២	BOT
១០	វារីអគ្គិសនីស្ទឹងអាតៃក្រោម - អនុស្ថានីយអូរសោម	២	៤០០	១៤	២០១៣	BOT
១១	វារីអគ្គិសនីស្ទឹងអាតៃលើ - អនុស្ថានីយអូរសោម	១	៤០០	៤	២០១៣	BOT
១២	អនុស្ថានីយស្ទឹងហារ - អនុស្ថានីយខេត្តព្រះសីហនុ	២	៤០០	១១	២០១៤	JICA
១៣	អនុស្ថានីយឈូក - អនុស្ថានីយបន្ទាយមាស	១	៤០០	១២	២០១៤	EDC
១៤	អនុស្ថានីយទី ១ - អនុស្ថានីយទី ៥	២	២ x ២៤០ ២ x ២៥០	៩	២០១៤	CEIB
១៥	អនុស្ថានីយទី ៥ - អនុស្ថានីយទី ៦	២	២ x ២៤០	២៥	២០១៤	CEIB
១៦	អនុស្ថានីយសៀមរាប(ពួក) - អនុស្ថានីយសៀមរាប(ចុងកៅស៊ូ)	១	៤០០	២៦	២០១៦	BOT
១៧	អនុស្ថានីយអគ្គិសនីទី ២ - អនុស្ថានីយអគ្គិសនីទី ៧	២	២ x ២៤០	១៧	២០១៦	CEIB
១៨	ព្រំប្រទល់ឡារ - អនុស្ថានីយព្រះវិហារទី១	១	២៤០	៥៤	២០១៧	CEIB
១៩	អនុស្ថានីយទី ៧ - អនុស្ថានីយកំពង់ចិនា	១	២ x ២៤០	៦០	២០១៧	CEIB
២០	អនុស្ថានីយកំពង់ចិនា - អនុស្ថានីយច្រកម្ទេស	១	២ x ២៤០	៨១	២០១៧	CEIB
២១	អនុស្ថានីយបាត់ដំបង (CPG) - អនុស្ថានីយរតនមណ្ឌល	២	៤០០	៣៨	២០១៨	EDC
២២	អនុស្ថានីយរតនមណ្ឌល - អនុស្ថានីយ៉ប៉ែន	២	៤០០	៤៦	២០១៨	EDC
២៣	អនុស្ថានីយបន្ទាយមាស - អនុស្ថានីយជីបម៉ុង	១	៤០០	៧	២០១៨	EDC
២៤	អនុស្ថានីយអគ្គិសនីទី ៣ - NCC - អនុស្ថានីយអគ្គិសនីទួលគោក	២	៨០០ & ១០០០	៦	២០១៨	JICA
ប្រវែងខ្សែសរុប				៧៧៩ គីឡូម៉ែត្រ		

តារាងទី ៩ : ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល

ll	ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣0kV	ចំនួនសៀគ្វី	មុខកាត់ខ្សែ (mm2)	ប្រវែងខ្សែ (km)	ឆ្នាំដំណើរការ	ប្រភពទុន
១	ព្រែងនវៀតណាម - អនុស្ថានីយតាកែវ	២	៨០០	៥០	២០០៩	ADB - NDF
២	អនុស្ថានីយតាកែវ - អនុស្ថានីយទី៨	២	៦៣0	៨៦	២០០៩	ADB - NDF
៣	អនុស្ថានីយតាកែវ - អនុស្ថានីយឈូក - អនុស្ថានីយកំពត	២	៨០០	៧៣	២០១១	KFW
៤	អនុស្ថានីយកំពត - រោងចក្រវារីអគ្គិសនីកំចាយ	២	៦៣0	១១	២០១២	BOT
៥	អនុស្ថានីយទី ៨ - អនុស្ថានីយទី ៦	២	២ x ៦៣0	៨0	២០១២	BOT
៦	អនុស្ថានីយទី ៦ - អនុស្ថានីយកំពង់ឆ្នាំង	២	២ x ៦៣0	៨៩	២០១២	BOT
៧	អនុស្ថានីយកំពង់ឆ្នាំង - អនុស្ថានីយពោធិ៍សាត់	២	២ x ៦៣0	៨៣	២០១២	BOT
៨	អនុស្ថានីយពោធិ៍សាត់ - អនុស្ថានីយបាត់ដំបង (CPG)	២	២ x ៦៣0	១២៣	២០១២	BOT
៩	អនុស្ថានីយពោធិ៍សាត់ - អនុស្ថានីយអូរសោម	២	២ x ៦៣0	១៤២	២០១២	BOT
១0	អនុស្ថានីយកំពត - អនុស្ថានីយស្ទឹងហាវ	២	៦៣0	៨២	២០១៣	ADB - JICA
១១	អនុស្ថានីយទី៦(ខាងជើងភ្នំពេញ) - អនុស្ថានីយកំពង់ចាម	២	២ x ៨០០	៩៧	២០១៣	BOT
១២	អនុស្ថានីយអគ្គិសនីអូរសោម - វារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម - វារីអគ្គិសនីស្ទឹងតាតៃ	២	២ x ៨០០	៧៥	២០១៣	BOT
១៣	អនុស្ថានីយអគ្គិសនីស្ទឹងហាវ - រោងចក្រធ្យូងថ្ម CEL	២	២ x ៨០០	២	២០១៣	BOT
១៤	អនុស្ថានីយអគ្គិសនីស្ទឹងហាវ - រោងចក្រធ្យូងថ្ម CIIDG	២	២ x ៦៣0	១	២០១៤	BOT
១៥	អនុស្ថានីយអគ្គិសនីទី ៨ - អនុស្ថានីយអគ្គិសនីទី ៧	២	២ x ៦៣0	២៤	២០១៤	CEIB
១៦	អនុស្ថានីយកំពង់ចាម - អនុស្ថានីយក្រចេះ	២	២ x ៦៣0	១២៣	២០១៧	BOT
១៧	អនុស្ថានីយក្រចេះ - អនុស្ថានីយស្ទឹងត្រែង	១	២ x ៦៣0	១១៧	២០១៧	IEIB
១៨	អនុស្ថានីយស្ទឹងត្រែង - រោងចក្រវារីអគ្គិសនីសេសានក្រោម២	២	២ x ៦៣0	២៥	២០១៧	BOT
ប្រវែងខ្សែសរុប				១.១៦៣ គីឡូម៉ែត្រ		

តារាងទី ១០ : អនុស្ថានីយអគ្គិសនីតង់ស្យុងខ្ពស់

ល.រ	អនុស្ថានីយ	តង់ស្យុង(kV)	ចំនួនត្រង់ស្វូម៉ាទ័រ	អានុភាពសរុប (MVA)	ឆ្នាំដំណើរការ
១	អនុស្ថានីយទី១	១១៥/៦២	២ x ៧៥	១៥០	១៩៩៩ ប្តូរត្រង់ស្វូរ ៥០ ទៅ ៧៥ MVA ២០១៣
២	អនុស្ថានីយទី២	១១៥/៦២	៣ x ៥០	១៥០	១៩៩៩ (បន្ថែម ១គ្រឿងឆ្នាំ ២០១៣)
៣	អនុស្ថានីយទី៣	១១៥/៦២	២ x ៥០	១០០	១៩៩៩
		១១៥/៦២/១៥	១ x ៥០	៥០	(បន្ថែម ១គ្រឿងឆ្នាំ ២០១៣)
៤	អនុស្ថានីយកំពង់ស្តី	១១៥/៦២	១ x ៥០	៥០	២០០២
៥	អនុស្ថានីយបាត់ដំបង(CPTL)	១១៥/៦២	១ x ២៥	២៥	២០០៧
៦	អនុស្ថានីយបន្ទាយមានជ័យ	១១៥/៦២	១ x ៥០	៥០	២០០៧
៧	អនុស្ថានីយសៀមរាបទី១	១១៥/៦២	១ x ៥០ ១ x ២៥	៧៥	២០០៧ (បន្ថែម ១គ្រឿងឆ្នាំ ២០១៨)
៨	អនុស្ថានីយទី៨ (ខាងលិចភ្នំពេញ)	២៣០/១១៥	២ x ២០០	៨០០	២០០៩
		១១៥/៦២	២ x ៥០	១០០	
៩	អនុស្ថានីយតាកែវ	២៣០/៦២	១ x ១៦ ១ x ៥០	៦៦	២០០៩ បន្ថែម ១គ្រឿងឆ្នាំ ២០១៥
១០	អនុស្ថានីយកំពត	២៣០/៦២	១ x ៥០	៥០	២០១២
១១	អនុស្ថានីយកំពង់ឆ្នាំង	២៣០/៦២	១ x ៥០	៥០	២០១២ ប្តូរត្រង់ស្វូរ 50MVA ឆ្នាំ២០១៧
១២	អនុស្ថានីយពោធិ៍សាត់	២៣០/៦២	១ x ២៥	២៥	២០១២
១៣	អនុស្ថានីយបាត់ដំបង(CPG)	២៣០/១១៥/៦២	២ x ៩០ ១ x ៧៥	២៥៥	២០១២ (បន្ថែម ១គ្រឿងឆ្នាំ ២០១៥) (បន្ថែម ១គ្រឿងឆ្នាំ ២០១៨)
១៤	អនុស្ថានីយទី៥	១១៥/៦២	៣ x ៥០	១៥០	២០១៣ (បន្ថែម ១គ្រឿងឆ្នាំ ២០១៥) (បន្ថែម ១គ្រឿងឆ្នាំ ២០១៧)
១៥	អនុស្ថានីយស្ទឹងហាវ	២៣០/៦២	១ x ៥០	៥០	២០១៣
		២៣០/១១៥	១ x ១០០	១០០	(បន្ថែម ១គ្រឿងឆ្នាំ ២០១៨)
១៦	អនុស្ថានីយទី៦ (ខាងជើងភ្នំពេញ)	១១៥/៦២	២ x ៥០	១០០	២០១៣
		២៣០/១១៥	២ x ២០០	៨០០	
១៧	អនុស្ថានីយអូរសោម	២៣០/១១៥/៦២	១ x ១៥០	១៥០	២០១៣
១៨	អនុស្ថានីយកំពង់ចាម	១១៥/៦២	២ x ៥០	១០០	២០១៣ (បន្ថែម ១គ្រឿងឆ្នាំ ២០១៥)
		២៣០/១១៥	១ x ២០០	២០០	(បន្ថែម ១គ្រឿងឆ្នាំ ២០១៧)
១៩	អនុស្ថានីយឈូក	២៣០/១១៥/៦២	១ x ១០០	១០០	២០១៤
២០	អនុស្ថានីយក្រុងព្រះសីហនុ	១១៥/៦២	១ x ៥០	៥០	២០១៤
២១	អនុស្ថានីយបន្ទាយមាស (SWS)	១១៥/៦២	៦,៣	៦,៣	២០១៤
២២	អនុស្ថានីយទី៧ (ខាងត្បូងភ្នំពេញ)	២៣០/១១៥	២ x ២០០	៨០០	២០១៥
		២៣០/៦២	១ x ៧៥	៧៥	(បន្ថែម ២គ្រឿងឆ្នាំ ២០១៧)
២៣	អនុស្ថានីយតាតៃ	២៣០/៣៥/៦២	១ x ៦០	៦០/៦០/៤០	២០១៥
២៤	អនុស្ថានីយ IE	១១៥/៦២	១ x ៥០	៥០	២០១៥
២៥	អនុស្ថានីយសៀមរាបទី២	១១៥/៦២	១ x ៥០	៥០	២០១៦
២៦	អនុស្ថានីយកំពង់សីផ្អូ	១១៥/៦២	១ x ៥០	៥០	២០១៧

តារាងទី ១០ : អនុស្ថានីយអគ្គិសនីតង់ស្យុងខ្ពស់(ត)

ល.រ	អនុស្ថានីយ	តង់ស្យុង(kV)	ចំនួនត្រង់ស្វូម៉ាទ័រ	អានុភាពសរុប (MVA)	ឆ្នាំដំណើរការ
២៧	អនុស្ថានីយទី៨	១១៥/២២	១ x ៧៥	៧៥	២០១៧
២៨	អនុស្ថានីយច្រកមូស	១១៥/២២	១ x ៥០	៥០	២០១៧
២៩	អនុស្ថានីយក្រចេះ	២៣០/២២	១ x ៥០	៥០	២០១៧
៣០	អនុស្ថានីយព្រះវិហារទី១	១១៥/២២	១ x ៥០	៥០	២០១៨
៣១	អនុស្ថានីយអនុស្ថានីយស្ទឹងត្រែង	២៣០/២២	១ x ៥០	៥០	២០១៨
៣២	អនុស្ថានីយទី១០	១១៥/២២	១ x ៣០	៣០	២០១៨

ខ្សែបណ្តាញចែកចាយអគ្គិសនី

ខ្សែបណ្តាញចែកចាយ និងបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ជាទូទៅ គឺមានតង់ស្យុង ២២ គីឡូវ៉ុល និងតង់ស្យុង ទាប ០,៤/០,២៣ គីឡូវ៉ុល ។ អំឡុងឆ្នាំ២០០៩ និង ២០១០ បណ្តាញចែកចាយនៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ស្រុកបានលុង (ខេត្តរតនគិរី) ខេត្តស្វាយរៀង និងខេត្តព្រះសីហនុ ត្រូវបានសាងសង់បន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្គត់ផ្គង់ ។ ចំពោះទិន្នន័យលម្អិតរបស់ខ្សែបណ្តាញប្រភេទតង់ស្យុងខុសៗគ្នា ដូចមានបង្ហាញក្នុងតារាងបន្ទាប់។

គម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ដែលស្ថិតក្រោមប្រាក់កម្ចីរបស់ធនាគារចិនអាហារ៍ណានីហារ៍ណា (China Exim Bank) កំពុងដំណើរការសាងសង់ប្រព័ន្ធចែកចាយតង់ស្យុងមធ្យម ដែលគ្របដណ្តប់ខេត្តចំនួន ០៤រួមមាន ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដែលមានប្រវែងសរុប ២.០០០ គីឡូម៉ែត្រ។ បន្ថែមពីនេះ គម្រោងអគ្គិសនីភាវូបនីយកម្មជនបទដំណាក់កាលទី២ ស្ថិតក្រោមមូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគ្របដណ្តប់ ខេត្តចំនួន ៦រួមមាន ខេត្តក្រចេះ ខេត្តស្វាយរៀង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប ដែលមានប្រវែងសរុបប្រមាណ ១.២០០ គីឡូម៉ែត្រ ត្រូវបានសាងសង់រួចរាល់ជាស្ថាពរ និងដាក់ឲ្យដំណើរការនៅឆ្នាំ ២០១៦។

គម្រោងពង្រីកខ្សែបញ្ជូនរងអគ្គិសនីតង់ស្យុងមធ្យម ក្រោមគម្រោងហិរញ្ញប្បទានឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលកំពុងធ្វើការសាងសង់ក្នុងខេត្តចំនួន ៥រួមមាន ៖ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តបន្ទាយមានជ័យ ដែលមានប្រវែងសរុបប្រមាណ ២.១៥៨ គីឡូម៉ែត្រ ។ បន្ទាប់មកគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ខេត្តស្វាយរៀង ដែលប្រើប្រាស់ថវិកាហិរញ្ញប្បទានឥតសំណងរបស់ទីភ្នាក់ងារអន្តរជាតិ (AusAid) តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ជាមួយថវិកាក្នុងស្រុក ដែលមានប្រវែងខ្សែបណ្តាញ MV និង LV ប្រមាណ៦២០ គីឡូម៉ែត្រ។ គម្រោងពង្រីកខ្សែបណ្តាញចែកចាយក្នុង ខេត្តកោះកុង កំពង់ចាម និងក្រចេះ ដែលផ្តល់ហិរញ្ញប្បទានឥណទាន

ខ្សែបណ្តាញ ចែកចាយអគ្គសនី

១- ខ្សែបញ្ជូនតង់ស្យុង ១១៥ គីឡូវ៉ុល

២- ខ្សែបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល

៣- អនុស្ថានីយតង់ស្យុង ១១៥ គីឡូវ៉ុល

៤- អនុស្ថានីយតង់ស្យុង ២៣០ គីឡូវ៉ុល

ដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍បៅកាត់ថា AFD ត្រូវបានធ្វើការសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំដៀញថ្លៃ។

គម្រោងពង្រីកបណ្តាញអគ្គិសនីភាវូបនីយកម្មជនបទ ជំហានទី៥ និងទី៦ បានចាប់ផ្តើម សិក្សា និងធ្វើការចរចាដើម្បីពង្រីកបន្ថែមនូវបណ្តាញអគ្គិសនីភាវូបនីយកម្មជនបទក្នុងខេត្តចំនួន ១៣ ដែលមានប្រវែងសរុបប្រមាណ ២.៥២៥ គីឡូម៉ែត្រ ។

គម្រោងពង្រីកបណ្តាញអគ្គិសនីភាវូបនីយកម្មជនបទ ជំហានទី៧ ស្ថិតក្រោមប្រាក់កម្ចីរបស់រដ្ឋាភិបាលចិនអាហារ័ណានីហារ័ណ (China Exim Bank) ដែលបានចុះកិច្ចសន្យានៅអំឡុងខែមិថុនា ឆ្នាំ២០១៨ ក្នុងទំហំទឹកប្រាក់ហិរញ្ញប្បទានឥណទានប្រមាណ ៨២ លានដុល្លារអាមេរិក ។ គម្រោងនេះ នឹងត្រូវសាងសង់ប្រព័ន្ធចែកចាយតង់ស្យុងមធ្យម នៅទូទាំងប្រទេសកម្ពុជា ដែលគ្របដណ្តប់លើខេត្តចំនួន ១៤ រួមមាន ៖ ខត្តរមានជ័យ សៀមរាប បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ ក្រចេះ ព្រៃវែង តាកែវ និងកំពត ដែលមានប្រវែងសរុប ប្រមាណ ២.៩៧០ គីឡូម៉ែត្រ។

គម្រោងពង្រីកខ្សែបណ្តាញបញ្ជូនរងអគ្គិសនី និងធ្វើឲ្យប្រសើឡើងនូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបណ្តាញចែកចាយអគ្គិសនីនៅតំបន់ជនបទ ក្រោមគម្រោងហិរញ្ញប្បទានឥណទានរបស់ធនាគាររអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) ដែលគ្របដណ្តប់លើខេត្តចំនួន ០៤ រួមមាន ៖ ខេត្តកំពង់ធំ សៀមរាប ខត្តរមានជ័យ និងខេត្តព្រះវិហារ ដែលមានប្រវែងសរុបប្រមាណ ៣២០ គីឡូម៉ែត្រ។

តារាងទី ១១ : ទិន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង

ទីតាំង	ប្រភេទ	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
ភ្នំពេញ និង កណ្តាល	ប្រវែងខ្សែ,cct-km	៣.៥៨៦	៣.៧៧៩	៤.១៨៧	៤.៤២១	៤.៦៤៧	៥.០៤៥
	តង់ស្យុងមធ្យម	២.២០៤	២.៣២៥	២.៦៤១	២.៧៥៩	២.៨៩៧	៣.១២៦
	តង់ស្យុងទាប	១.៣៨២	១.៤៥៣	១.៥៤៦	១.៦៦២	១.៧៥០	១.៩១៩
	បន្ទប់ភ្លើងសរុប	២.៣៨៥	២.៦៦៥	២.៩៩៤	៣.៣៦៧	៣.៨៧៩	៤.៣៤៦
	បន្ទប់ភ្លើង	-	១.០៧៦	១.២១៨	១.៣៥៦	១.៥៤៩	១.៧៥៣
	ប៉ុស្តិ៍លើបង្គោល	-	១.៥៨៩	១.៧៧៦	២.០១១	២.៣៣០	២.៥៩៣
កំពង់ស្ពឺ	ប្រវែងខ្សែ,cct-km	៨០៦	៨២៥	៩០១	៦១៩	៧៧៥	៨០២
	តង់ស្យុងមធ្យម	៦៧៣	៦៨៣	២៩២	៤០៩	៥៤០	៥៩៣
	តង់ស្យុងទាប	១៣២	១៩២	១៦០	២០៥	២៣៥	២៥៩
	បន្ទប់ភ្លើងសរុប	៨៧	៩៥	១០២	២៣១	២៦៣	៣០៧
	បន្ទប់ភ្លើង	-	-	៣	៣	៣	៣
	ប៉ុស្តិ៍លើបង្គោល	-	៩៥	៩៩	២២៨	២៦០	៣០៩
សៀមរាប	ប្រវែងខ្សែ,cct-km	៧៣៦	៨០៨	១.១២៩	១.៣០៩	២.៣៥៦	២.៦៦១
	តង់ស្យុងមធ្យម	៨១៩	៩៦២	៧៩៩	៨៦១	១.២៧៩	១.៣៥៩
	តង់ស្យុងទាប	៣២២	៣៩៦	៣៨០	៤៩៨	១.០៧៧	១.៣០២
	បន្ទប់ភ្លើងសរុប	១៩៦	២៣០	៣០៨	៣៨០	៣៨៣	៦១០
	បន្ទប់ភ្លើង	-	១៣២	១៩១	១៩៧	៩៩	១០៥
	ប៉ុស្តិ៍លើបង្គោល	-	៩៨	១៦៧	២៣៣	២៨៩	៥០៥
ព្រះសីហនុ	ប្រវែងខ្សែ,cct-km	៣០៩	៣៦២	៥០៣	៨៨៩	៩៨៩	១.០១១
	តង់ស្យុងមធ្យម	២០៨	២៦៦	៩០១	៧៧៣	៨៦៩	៨៦៩
	តង់ស្យុងទាប	៩៦	៩៦	១០៣	១១៦	១២០	១៩២
	បន្ទប់ភ្លើងសរុប	១៨៧	២៨១	៣១២	៣៥៥	៨៧៩	៧១២
	បន្ទប់ភ្លើង	-	៥១	៥៩	៦២	៨៧	១២៣
	ប៉ុស្តិ៍លើបង្គោល	-	២៣០	២៥៨	២៩៣	៣៩២	៥៨៩
កំពង់ចាម	ប្រវែងខ្សែ,cct-km	១៥០	៦៦៧	៧៣២	៨៩៥	១.០២៩	៨៧២
	តង់ស្យុងមធ្យម	៥២	៥៩៨	៦០៧	៦៧៩	៨២៣	៦៩១
	តង់ស្យុងទាប	៩៨	១១៩	១២៥	១៦៥	២០១	២៣១
	បន្ទប់ភ្លើងសរុប	៦៩	១៩១	២០១	២២១	២៩៥	២៩៣
	បន្ទប់ភ្លើង	-	៦	៦	៦	៨	៦
	ប៉ុស្តិ៍លើបង្គោល	-	១៣៥	១៩៥	២១៥	២៣៧	២៣៧
ពញាវឿក	ប្រវែងខ្សែ,cct-km	៤៥	៦៩	៧៥	១២២	១៣៧	១៥៥
	តង់ស្យុងមធ្យម	២៧	៤៦	៥០	៧១	៦៩	៧១
	តង់ស្យុងទាប	១៨	១៨	២៥	៥១	៦៨	៨៤
	បន្ទប់ភ្លើងសរុប	២១	៣៣	៤៣	៤៧	៤៣	៤៨
	បន្ទប់ភ្លើង	-	-	-	-	-	-
	ប៉ុស្តិ៍លើបង្គោល	-	៣៣	៤៣	៤៧	៤៣	៤៨

តារាងទី ១១ : ទិន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង(ត)

ទីតាំង	ប្រភេទ	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
មេមត់	ប្រវែងខ្សែ,cct-km	៤៨	២១៦	២៤៦	២៨១	២៨៣	៤១០
	តង់ស្យុងមធ្យម	២៣	១៨៩	១៨៩	២០៦	២០៦	៣០៥
	តង់ស្យុងទាប	២៥	២៦	៥៦	៧៥	៧៧	១០៥
	បន្ទប់ភ្លើងសរុប	២៨	២៥	៧៧	៨៧	៩៣	១៣៥
	បន្ទប់ភ្លើង	-	-	-	-	-	០
	ប៉ុស្តិ៍លើបង្គោល	-	២៥	៧៧	៨៧	៩៣	១៣៥
តាកែវ	ប្រវែងខ្សែ,cct-km	៣៦៨	៥៦៧	៧៤៦	៧៨៦	៧៨៣	៩០៩
	តង់ស្យុងមធ្យម	១៥៨	៣១៦	៣៥៣	៣៥៦	៣៤៥	៣៧២
	តង់ស្យុងទាប	២១០	២៥១	៣៩៤	៤៣១	៤៣៧	៥៣៧
	បន្ទប់ភ្លើងសរុប	១១៣	១៦៧	១៨៨	១៨៨	១៦៩	១៨១
	បន្ទប់ភ្លើង	-	១៧	២៥	២៦	៦	៦
	ប៉ុស្តិ៍លើបង្គោល	-	១៥០	១៦៣	១៦២	១៦៣	១៧៥
បាត់ដំបង	ប្រវែងខ្សែ,cct-km	៦៩២	៦៩១	៦៩៦	២.២៧៦	២.៤៦៥	២៥៣៤
	តង់ស្យុងមធ្យម	៤៤៤	៤៤៤	៤៤៧	១.៩៧៧	២.១១០	២១៣២
	តង់ស្យុងទាប	២៤៧	២៤៧	២៤៩	២៩៩	៣៥៥	៤០៣
	បន្ទប់ភ្លើងសរុប	២៤០	២៤០	២៥២	៦៩៦	៧៤៣	៧៨២
	បន្ទប់ភ្លើង	-	-	១	៧	៨	៨
	ប៉ុស្តិ៍លើបង្គោល	-	២៤០	២៥១	៦៨៩	៧៣៥	៧៧៤
កំពត	ប្រវែងខ្សែ,cct-km	៣៣៩	៣៣៩	៤៣៦	៦៥៨	៦៧៣	៦៧៣
	តង់ស្យុងមធ្យម	២២៧	២២៧	៣១១	៥៣៤	៥៤៥	៥៤៦
	តង់ស្យុងទាប	១១២	១១២	១២៥	១២៥	១២៧	១២៧
	បន្ទប់ភ្លើងសរុប	១០៥	១០៥	១៨៧	២២៩	២៤៥	២៦២
	បន្ទប់ភ្លើង	-	-	-	៧	៧	៧
	ប៉ុស្តិ៍លើបង្គោល	-	១០៥	១៨៧	២២២	២៣៨	២៥៥
កំពង់ស្ពាច	ប្រវែងខ្សែ,cct-km	៧៦	៧៦	១០០	១២១	១៤៤	១៥៦
	តង់ស្យុងមធ្យម	៨៧	៨៧	៨៨	៥៦	៦៥	៦៩
	តង់ស្យុងទាប	២៩	២៩	៥២	៦៥	៧៨	៨៧
	បន្ទប់ភ្លើងសរុប	៨៨	៨៨	៨៧	៥៣	៦៣	៦៨
	បន្ទប់ភ្លើង	-	១	១	២	២	១
	ប៉ុស្តិ៍លើបង្គោល	-	៨៣	៨៦	៥១	៦១	៦៧
ព្រៃវែង	ប្រវែងខ្សែ,cct-km	៨៧៨	៧៩០	៧៩៨	៨២៨	៨៦៧	៨៦៩
	តង់ស្យុងមធ្យម	៨១៧	៧៣១	៧៣១	៧៦០	៨០៤	៨០៤
	តង់ស្យុងទាប	៥៧	៥៩	៦៣	៦៥	៦៣	៦៥
	បន្ទប់ភ្លើងសរុប	២១	១៩៤	២០២	២៤៧	២៩០	៣៣៣
	បន្ទប់ភ្លើង	-	-	៨	៨	៨	៨
	ប៉ុស្តិ៍លើបង្គោល	-	១៩៤	១៩៨	២៣៩	២៨២	៣២៥

តារាងទី ១១ : ទិន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង(ត)

ទីតាំង	ប្រភេទ	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
បន្ទាយ មានជ័យ	ប្រវែងខ្សែ,cct-km	១៧៤	១៨១	២២៩	២២៩	២៤៧	៥២០
	តង់ស្យុងមធ្យម	៤៩	៥១	៦៥	៦៥	៦៥	៣៣៨
	តង់ស្យុងទាប	១២៥	១៣០	១៦៤	១៦៤	១៨២	១៨២
	បន្ទប់ភ្លើងសរុប	៥៥	៦០	៨៦	៥៦	៦៦	២៧៨
	បន្ទប់ភ្លើង	-	-	៨	៨	៨	៨
	ប៉ុស្តិ៍លើបង្គោល	-	៦០	៧៨	៤៨	៥៨	២៧០
មន្ទលបូរី	ប្រវែងខ្សែ,cct-km	៨២	៨២	៨៩	៨៩	៩៣	៩៤
	តង់ស្យុងមធ្យម	៤៥	៤៥	៤៦	៤៦	៤៧	៤៧
	តង់ស្យុងទាប	៣៧	៣៧	៤៤	៤៤	៤៦	៤៧
	បន្ទប់ភ្លើងសរុប	៣៥	៣៩	៤២	២២	២៣	៣០
	បន្ទប់ភ្លើង	-	-	-	-	-	-
	ប៉ុស្តិ៍លើបង្គោល	-	៣៩	៤២	២២	២៣	៣០
ស្ទឹងត្រែង	ប្រវែងខ្សែ,cct-km	២០២	២៤០	២៤០	៣២៧	៧៦៩	៧៩៩
	តង់ស្យុងមធ្យម	១៣២	១៥១	១៥១	២២៧	៦០០	៦៣០
	តង់ស្យុងទាប	៧០	៨៩	៨៩	១០០	១៦៩	១៦៩
	បន្ទប់ភ្លើងសរុប	៣៧	៤៨	៥៣	៦៣	៧៩	១៣០
	បន្ទប់ភ្លើង	-	-	៤	៩	៥	១៣
	ប៉ុស្តិ៍លើបង្គោល	-	៤៨	៤៩	៥៤	៧៤	១១៧
រតនគិរី	ប្រវែងខ្សែ,cct-km	១៣៩	១៤១	១៦៧	៥៩២	៧៣០	៨០៣
	តង់ស្យុងមធ្យម	៩២	៩២	១០៣	៤៩២	៥៨៦	៦០៣
	តង់ស្យុងទាប	៤៧	៤៩	៦៣	១០០	១៤៥	២០១
	បន្ទប់ភ្លើងសរុប	៧២	៨៥	១០៣	៧២	១៤៥	១៦៧
	បន្ទប់ភ្លើង	-	១	៥	៤	៤	៤
	ប៉ុស្តិ៍លើបង្គោល	-	៨៤	៩៨	៦៨	១៤១	១៦៣
ស្វាយរៀង	ប្រវែងខ្សែ,cct-km	៤១៩	៦០៥	៣៦៩	៨៨៧	៩៩៩	១.០៥៨
	តង់ស្យុងមធ្យម	៣២៥	៤៦៦	១៥៤	៦៧០	៦៦៤	៦៧៤
	តង់ស្យុងទាប	៩៤	១៣៩	២១៥	២១៧	៣៣៤	៣៨៤
	បន្ទប់ភ្លើងសរុប	៥៤	៧៦	១១៤	២៨៤	២៥២	៣១៧
	បន្ទប់ភ្លើង	-	-	៥	៥	៥	៥
	ប៉ុស្តិ៍លើបង្គោល	-	៧៦	១០៩	២៧៩	២៤៧	៣១២
បាទិត	ប្រវែងខ្សែ,cct-km	១៨៦	-	-	-	១២០	១៥៦
	តង់ស្យុងមធ្យម	១៤១	-	-	-	៧៧	៨៣
	តង់ស្យុងទាប	៤៤	-	-	-	៤៣	៧៣
	បន្ទប់ភ្លើងសរុប	២១	-	-	-	៤១	៤៥
	បន្ទប់ភ្លើង	-	-	-	-	-	-
	ប៉ុស្តិ៍លើបង្គោល	-	-	-	-	៤១	៤៥

តារាងទី ១១ : និន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង(ត)

ទីតាំង	ប្រភេទ	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨
មណ្ឌលគីរី	ប្រវែងខ្សែ,cct-km	១២០	១២៥	១៣៣	៣០០	៥៣៧	៦២៦
	តង់ស្យុងមធ្យម	៧៣	៧៧	៨៥	២៤៣	៣៩៨	៤៨៧
	តង់ស្យុងទាប	៨៧	៨៧	៨៨	៥៦	១៣៩	១៣៩
	បន្ទប់ភ្លើងសរុប	៥៨	៥៥	៧៦	១០៧	១២៦	១៥៥
	បន្ទប់ភ្លើង	-	-	-	-	-	-
	ប៉ុស្តិ៍លើបង្គោល	-	៥៥	៧៦	១០៧	១២៦	១៥៥
កែវសីមា	ប្រវែងខ្សែ,cct-km	៧៨	៨៩	៩០	៩០	១៣១	១៣១
	តង់ស្យុងមធ្យម	៨៦	៨៨	៨៨	៨៨	៨៣	៨៣
	តង់ស្យុងទាប	៣២	៤១	៤២	៤៣	៤៨	៤៨
	បន្ទប់ភ្លើងសរុប	២២	២៦	៣០	៣០	៣០	២៩
	បន្ទប់ភ្លើង	-	-	-	-	-	-
	ប៉ុស្តិ៍លើបង្គោល	-	២៦	៣០	៣០	៣០	២៩
ក្រចេះ	ប្រវែងខ្សែ,cct-km	១៦០	១៦០	២២៥	៣៨០	៥៥២	៨២៣
	តង់ស្យុងមធ្យម	១២៣	១២៣	១៣៩	២៧៩	៨៣៤	៦២៥
	តង់ស្យុងទាប	៣៨	៣៨	៨៥	១០១	១១៨	១៩៨
	បន្ទប់ភ្លើងសរុប	៨៩	៥៣	៧១	១០១	១២៣	១៧៨
	បន្ទប់ភ្លើង	-	-	-	-	-	-
	ប៉ុស្តិ៍លើបង្គោល	-	៥៣	៧១	១០១	១២៣	១៧៨
ស្ទឹងត្រែង	ប្រវែងខ្សែ,cct-km	៣៣	៣៣	៣៧	៨៤	១០១	២១៨
	តង់ស្យុងមធ្យម	១៩	២០	២៨	២៥	៤០	១០៨
	តង់ស្យុងទាប	១៨	១៨	១៨	៦០	៦១	១១០
	បន្ទប់ភ្លើងសរុប	២៨	៣២	៤០	៥១	៣៣	៥៣
	បន្ទប់ភ្លើង	-	-	-	-	-	-
	ប៉ុស្តិ៍លើបង្គោល	-	៣២	៤០	៥១	៣៣	៥៣
ត្បូងឃ្មុំ	ប្រវែងខ្សែ,cct-km	-	-	-	-	១៣៥	១៣៧
	តង់ស្យុងមធ្យម	-	-	-	-	៨២	៨២
	តង់ស្យុងទាប	-	-	-	-	៥២	៥៨
	បន្ទប់ភ្លើងសរុប	-	-	-	-	៣៦	៣៥
	បន្ទប់ភ្លើង	-	-	-	-	-	-
	ប៉ុស្តិ៍លើបង្គោល	-	-	-	-	៣៦	៣៥
សរុប	**ប្រវែងខ្សែ,cct-km**	**៥.២១៦**	**១០.៨៣៨**	**១១.៦២២**	**១៦.១២៧**	**១៩.៥៥០**	**២២.៤៦០**
	តង់ស្យុងមធ្យម	**៥.៤៣៥**	**៧.៣៥៦**	**៧.៥៨៣**	**១១.៥៣៦**	**១៣.៦២៤**	**១៥.៦២៦**
	តង់ស្យុងទាប	**៣.២៧៧**	**៣.៤៨២**	**៤.០៤០**	**៤.៥៩១**	**៥.៩២៦**	**៦.៨៦៤**
	បន្ទប់ភ្លើងសរុប	**៣.៩១៤**	**៤.៦៩៤**	**៥.៥២៨**	**៦.៨៨៧**	**៧.៨៤៩**	**៩.៥២៨**
	បន្ទប់ភ្លើង	-	**១.២៨៤**	**១.៤៧៥**	**១.៦៥០**	**១.៧៩៤**	**២០៥០**
	ប៉ុស្តិ៍លើបង្គោល	-	**៣.៤១០**	**៤.០៥៣**	**៥.២៣៧**	**៦.០៥៥**	**៧.៤៧៨**

មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

១- ការបង្កើតអគ្គិសនីភាវូបនីយកម្មជនបទ

២- សកម្មភាពការងារ ដែល ម.អ.ជ សម្រេចបានក្នុងឆ្នាំ២០១៨

១- ការបង្កើតអគ្គិសនីភាវូបនីយកម្មជនបទ

រាជរដ្ឋាភិបាលបានចេញព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបង្កើតស្ថាប័នមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ។ បន្ទាប់មកនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ រាជរដ្ឋាភិបាលកម្ពុជា បានចេញព្រះរាជក្រឹត្យថ្មីមួយទៀតលេខ នស/រកត/០៨១២/៧៣៤ ដោយធ្វើវិសោធនកម្មមាត្រាខ្លះនៃព្រះរាជក្រឹត្យចាស់ ដោយផ្ទេរស្ថាប័នមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជាវិញ ដើម្បីឲ្យកម្ពុជាអាចម្ចាស់ការក្នុងការបន្តប្រតិបត្តិការការងាររបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទផង និងក៏នៅតែអាចទទួលនូវអំណោយ និងជំនួយនានាពីខាងក្រៅ មកជួយអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទកម្ពុជាបានផង។

២- សកម្មភាពការងារ ដែលម.អ.ជ សម្រេចបានក្នុងឆ្នាំ២០១៨

ក្នុងឆ្នាំ២០១៨ ម.អ.ជ ទទួលបានថវិកាពីអគ្គិសនីកម្ពុជា ចំនួន ៧៤ លានដុល្លារអាមេរិក ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ចំនួន ២,៦ លានដុល្លារអាមេរិក និងទទួលបានពីធនាគារអភិវឌ្ឍន៍អាស៊ីចំនួន ១ លាន ដុល្លារអាមេរិក ដែលថវិកាសរុបទាំងអស់មានចំនួន ៧៧,៦ លានដុល្លារអាមេរិក សម្រាប់យកទៅអនុវត្តកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍន៍អគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ។ ថវិកាទាំងនេះសម្រាប់ចំណាយប្រតិបត្តិការរបស់ ម.អ.ជ ដែលកម្មវិធីទាំង ៧នេះ រួមមាន៖

I - កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្រស់នៅតំបន់ជនបទ ដើម្បីឲ្យពួកគាត់អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ឲ្យពួកគាត់ខ្ចីយកទៅ ៖ ១-បង់ថ្លៃភ្ជាប់ចរន្តឲ្យអ្នកផ្គត់ផ្គង់ ២-បង់ថ្លៃប្រាក់កក់ឲ្យអ្នកផ្គត់ផ្គង់ ៣-ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន ៤-ចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ក្នុងឆ្នាំ២០១៨ នេះ មានគ្រួសារជនបទចំនួន ២៥៧ គ្រួសារ ស្មើនឹង ១.១៨២ នាក់ ដែលបានទទួលផលដោយផ្អាល់ក្រោមកម្មវិធីនេះ។

II - កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់ តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ។ ម.អ.ជ.ជួយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ១០០ ដុល្លារអាមេរិកក្នុង ១ ប្រព័ន្ធ ដល់គ្រួសារជនបទ ដើម្បីជួយកាត់បន្ថយការទូទាត់ថ្លៃទិញប្រព័ន្ធហើយអ្នកទិញត្រូវបង់ថ្លៃសល់ពីការឧបត្ថម្ភធននេះរំលស់ប្រចាំខែដោយគ្មានការប្រាក់មក ម.អ.ជ.វិញក្នុងរយៈពេល ៤ឆ្នាំ។ ក្រោយពេលបង់រំលស់អស់ជាស្ថាពរ ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ។ ក្នុងឆ្នាំ ២០១៨ មានគ្រួសារជនបទចំនួន ១៩.៧៥០ គ្រួសារ ស្មើនឹង ៩០.៨៥០ នាក់ បានទទួលផលដោយផ្អាល់ក្រោមកម្មវិធីនេះ។

III - កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ជនបទ

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យអ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដែលមានអាជ្ញាបណ្ណស្របច្បាប់ អាចមានទុនសម្រាប់វិនិយោគពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនី ឲ្យពេញដែនអាជ្ញាប័ណ្ណចែកចាយរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន ។ ក្នុងឆ្នាំ២០១៨ ម.អ.ជ បានផ្តល់ថវិកាជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីដល់សេវាការផ្គត់ផ្គង់អគ្គិសនីសាងសង់ខ្សែបណ្តាញ MV និង LV សរុបចំនួន ១.៦៩៦ គីឡូម៉ែត្រ។

IV - កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញជាតិ ដើម្បីបន្តយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្តយអត្រាថ្លៃលក់អគ្គិសនី ក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្ត និងរាជធានី

គោលបំណងនៃកម្មវិធីនេះ គឺផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្តយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្តយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្ត និងរាជធានី។ នៅឆ្នាំ ២០១៨ ម.អ.ជ បានផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណចំនួន ៣១៤ អាជ្ញាបណ្ណ ដែលក្នុងនោះ ៣១២ អាជ្ញាបណ្ណ បានទទួលថវិកាឧបត្ថម្ភធន និង ០២ អាជ្ញាបណ្ណពុំទាន់ស្នើសុំថវិកានៅឡើយ។

V - កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានបណ្ណសមធម៌ (P2P for ID Poor HH) ក្រោមដំណើរការលើមូលនិធិឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់គ្រួសារក្រីក្រមានបណ្ណសមធម៌នៅតំបន់ជនបទ ដោយជួយគ្រួសារមានចំណូលទាប និងងាយរងផលប៉ះពាល់អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ថវិកាឧបត្ថម្ភធនចំនួន ១០០ ដុល្លារអាមេរិក ក្នុងមួយគ្រួសារក្រីក្រ តាមរយៈអ្នកកាន់អាជ្ញាបណ្ណសម្រាប់ ១-ចំណាយលើសម្ភារ និងពលកម្មរាយខ្សែបណ្តាញសេវាកម្មក្នុងប្រវែង ១៥០ ម៉ែត្រ ពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះគ្រួសារមានបណ្ណក្រីក្រ និង ២-ចំណាយលើសម្ភារ និងពលកម្មតម្លើងសម្ភារអគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

កម្មវិធីនេះទទួលបានថវិកាជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចំនួន ១លានដុល្លារ សម្រាប់អនុវត្តក្នុងខេត្តគោលដៅចំនួន៦ រួមមាន៖ ខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ធំ កណ្តាល សៀមរាប និងខេត្តត្បូងឃ្មុំ ហើយចំនួនគោលដៅគ្រួសារក្រីក្រមានបណ្ណសមធម៌ គ្រោងទទួលផលក្រោមកម្មវិធីនេះមានចំនួន ១០.០០០ គ្រួសារ។ ក្នុងឆ្នាំ២០១៨ នេះ មានគ្រួសារជនបទចំនួន ៧.២០៩ គ្រួសារ ស្មើនឹង ៣៣.១៦១ នាក់ ដែលបានទទួលផលដោយផ្ទាល់តាមរយៈកម្មវិធីនេះ។

VI - កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានបណ្តាសមធម៌ (P2P for ID Poor HH) ក្រោមជំនួយផ្អែកលើទិន្នផល កម្មវិធីរបស់អគ្គិសនីកម្ពុជា (EDC)

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់គ្រួសារក្រីក្រមានបណ្តាសមធម៌នៅតំបន់ជនបទ ដោយជួយគ្រួសារមានចំណូលទាប និងងាយរងផលប៉ះពាល់អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីដោយការផ្តល់ថវិកាឧបត្ថម្ភធនចំនួន ១០០ ដុល្លារអាមេរិក ក្នុងមួយគ្រួសារក្រីក្រ តាមរយៈអ្នកកាន់អាជ្ញាបណ្ណសម្រាប់ ១-ចំណាយលើសម្ភារ និងពលកម្មរាយខ្សែបណ្តាញសេវាកម្មក្នុងប្រវែង ១៥០ ម៉ែត្រ ពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះគ្រួសារមានបណ្តាក្រីក្រ និង ២-ចំណាយលើសម្ភារ និងពលកម្មតម្លើងសម្ភារអគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

កម្មវិធីនេះទទួលបានថវិកាជំនួយពីអគ្គិសនីកម្ពុជា (EDC) ចំនួន ៨៥២.០០០ ដុល្លារអាមេរិក សម្រាប់អនុវត្តក្នុងខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងបណ្តាខេត្តដទៃទៀត។ ក្នុងឆ្នាំ២០១៨ នេះ មានគ្រួសារជនបទចំនួន ១.៩៦៦ គ្រួសារ ស្មើនឹង ៩.០៨៣ នាក់ ដែលបានទទួលផលដោយផ្ទាល់តាមរយៈកម្មវិធីនេះ។

VII - កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់គ្រួសារក្រីក្រ រស់នៅតំបន់ជនបទទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិផ្ទាល់ សម្រាប់ការបូមទឹកធ្វើកសិកម្មនៅតម្លៃអនុគ្រោះសម្រាប់ការប្រើប្រាស់អគ្គិសនីនៅពេលយប់ចាប់ពីម៉ោង ៩:០០ យប់ ដល់ម៉ោង ៧:០០ ព្រឹក និងនៅតម្លៃធម្មតាសម្រាប់ការប្រើប្រាស់អគ្គិសនីនៅពេលថ្ងៃចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ម៉ោង ៩:០០ យប់។ ក្នុងឆ្នាំ២០១៨ អគ្គិសនីកម្ពុជាបាន ៖ ១)-ចុះកិច្ចសន្យាជាមួយក្រុមហ៊ុន EM Construction ដើម្បីផ្គត់ផ្គង់ និងតម្លើងនាឡិកាស្វង់ Prepaid TOU និង ២)-កំពុងដំណើការលទ្ធកម្មក្រុមហ៊ុនផ្គត់ផ្គង់ និងសាងសង់បោដ្ឋារចនាសម្ព័នផ្គត់ផ្គង់អគ្គិសនី ក្រោមកម្មវិធីការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម។

ផែនការអភិវឌ្ឍន៍ វិស័យថាមពលអគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា

១- គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល
២- ការព្យាករណ៍តម្រូវការថាមពល
៣- ផែនការមេនៃការផលិតថាមពល

១- គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីនៅ ខែតុលា ឆ្នាំ១៩៩៤ ដែលមានទិសដៅដូចខាងក្រោម៖

- ផ្តល់នូវការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យបានគ្រប់គ្រាន់ទូទាំងប្រទេសកម្ពុជា ក្នុងតម្លៃសមរម្យ។
- ធានានូវការផ្គត់ផ្គង់ថាមពលអគ្គិសនី ឲ្យមាននិរន្តភាព និងសុវត្ថិភាព ដែលធ្វើឲ្យមានភាពងាយស្រួលដល់ការវិនិយោគក្នុងប្រទេសកម្ពុជា និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។
- ជួយជំរុញនូវបេកគំហើញថ្មីៗ និងការអភិវឌ្ឍន៍នៃប្រភពផលិតថាមពលដែលមិនប៉ះពាល់ដល់បរិស្ថាន និងសង្គម ដែលជាតម្រូវការចាំបាច់សម្រាប់ផ្គត់ផ្គង់ថាមពលដល់គ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ចជាតិ។
- លើកទឹកចិត្តនូវការប្រើប្រាស់ថាមពលអគ្គិសនីឲ្យមានប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់បរិស្ថាននូវកម្រិតអប្បបរមាពីប្រភពផ្គត់ផ្គង់ និងការប្រើប្រាស់ ។

២- ការព្យាករណ៍តម្រូវការថាមពល

ដោយផ្អែកទៅលើឯកសារស្តីពីផែនការមេនៃការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា ដែលបានរៀបចំឡើងនៅឆ្នាំ២០១៥ បានកត់សម្គាល់ថា តម្រូវការថាមពលអគ្គិសនី នឹងមានកំណើនគួរឲ្យកត់សម្គាល់មួយក្នុងរយៈពេល ១៥ ឆ្នាំខាងមុខនេះ។ តម្រូវការសម្រាប់ផលិតថាមពលនៅព្រះរាជាណាចក្រកម្ពុជា នឹងមានកំណើនពី ២.២៤២ ជីហ្គាវ៉ាត់ម៉ោង និង ៤០៩ មេហ្គាវ៉ាត់ នៅឆ្នាំ ២០១០ ទៅ ២៨.៤៦៥ ជីហ្គាវ៉ាត់ម៉ោង និង ៤.៨២៨ មេហ្គាវ៉ាត់ នៅឆ្នាំ ២០២៥។ ដើម្បីបំពេញតម្រូវការនាពេលអនាគត រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតផែនការអភិវឌ្ឍន៍ថាមពលរហូតដល់ឆ្នាំ ២០៣០។

មួយភាគធំនៃកំណើនតម្រូវការប្រើប្រាស់ថាមពលស្ថិតនៅភាគខាងត្បូងនៃប្រទេស ដែលរួមបញ្ចូលទាំងរាជធានីភ្នំពេញផងដែរ ។ តារាងខាងក្រោមពណ៌នាពីការព្យាករណ៍អានុភាពអតិបរមា និងថាមពលបញ្ចេញ សម្រាប់ព្រះរាជាណាចក្រកម្ពុជា។

តារាងទី ១២ : ការព្យាករណ៍តម្រូវការថាមពលអគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា

ករណីមូលដ្ឋាន	ខ្នាត	២០១៨	២០២៥	២០៣០
អានុភាពអតិបរមាក្នុងបណ្តាញជាតិ (MW)	MW	១.៥៣៧*	៨.៨២៨	១០.៧៤៩
អានុភាពអតិបរមាក្នុងប្រទេស (MW)	MW	១.៦៩០		
ថាមពលក្នុងបណ្តាញជាតិ (GWh)	GWh	៩.៨២៧*	២៨.៤៦៥	៦១.២០៧
ថាមពលក្នុងប្រទេស (GWh)	GWh	១០.៣៦៩**		

** ថាមពល និងអានុភាពអតិបរមាក្នុងបណ្តាញជាតិ គឺជាទិន្នន័យជាក់ស្តែងក្នុងឆ្នាំ ២០១៨។*
** * ថាមពលក្នុងប្រទេស គឺជាទិន្នន័យរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។*

៣- ផែនការមេនៃការផលិតថាមពល

ផែនការមេនៃការផលិតថាមពល ត្រូវបានអភិវឌ្ឍដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖

- ការផលិតថាមពលដើរដោយរោងចក្រអគ្គិសនីដែលមានស្រាប់ សម្រាប់ប្រព័ន្ធភ្នំពេញនៅពេលបន្ទុក អតិបរមា។

- ប្រើប្រាស់ម៉ាស៊ីនឌីយ៉ែស្បៃលធុនតូច និងមធ្យម ដើម្បីជួយក្នុងការផលិតថាមពល សម្រាប់ចែករំលែកក្នុងបន្ទុកធម្មតា និងមានបន្ទុកអតិបរមានៅតាមបណ្តាខេត្ត-ក្រុង (សម្រាប់រយៈពេលខ្លី)។

- ពង្រីកការអភិវឌ្ឍន៍ផ្នែកវារីអគ្គិសនី ដោយមូលដ្ឋាននៃការអភិវឌ្ឍន៍លើរោងចក្រវារីអគ្គិសនីធុនតូច ដែលមានភាពងាយស្រួលក្នុងការចូលអភិវឌ្ឍដូចជា: រោងចក្រវារីអគ្គិសនីគីរីម្យ១ និង ៣ និងគម្រោងរោងចក្រវារីអគ្គិសនីធុនមធ្យម និងធំជាបន្តបន្ទាប់ដូចជា: រោងចក្រវារីអគ្គិសនីសេសានក្រោម២ រោងចក្រវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ រោងចក្រវារីអគ្គិសនីស្រែពក3A, 3B និង ៤ រោងចក្រវារីអគ្គិសនីសេសានក្រោម៣ រោងចក្រវារីអគ្គិសនីស្ទឹងមេទឹក រោងចក្រវារីអគ្គិសនីព្រែកល្អាង រោងចក្រវារីអគ្គិសនីស្ទឹងវាលថ្មកំបុត។

តារាងទី ១៣ : ផែនការអភិវឌ្ឍន៍ផ្នែកផលិតកម្មសម្រាប់ឆ្នាំ ២០១៩ - ២០៣០

ល.រ	ឈ្មោះគម្រោង	ប្រភេទ	អានុភាព (MW)	ឆ្នាំដំណើរការ
១	រោងចក្រអគ្គិសនីដុតធ្យូងថ្ម CEL II	ធ្យូងថ្ម	១៣៥	២០១៩
២	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ (កំពង់ស្ពឺ)	ពន្លឺព្រះអាទិត្យ	៨០	២០១៩
៣	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ (បាវិត)	ពន្លឺព្រះអាទិត្យ	២០	២០២០
៤	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ (បាត់ដំបង)	ពន្លឺព្រះអាទិត្យ	៦០	២០២០
៥	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ (បន្ទាយមានជ័យ)	ពន្លឺព្រះអាទិត្យ	៦០	២០២០
៦	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ (ពោធិ៍សាត់)	ពន្លឺព្រះអាទិត្យ	៣០	២០២០
៧	រោងចក្រអគ្គិសនីប្រេងខ្មៅ	ប្រេងឥន្ធនៈ	៨០០	២០២០
៨	រោងចក្រអគ្គិសនីដុតធ្យូងថ្ម (បាងសេង)	ធ្យូងថ្ម	២០០	២០២១
៩	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ (កំពង់ឆ្នាំង)	ពន្លឺព្រះអាទិត្យ	៦០	២០២០
១០	រោងចក្រអគ្គិសនីដុតធ្យូងថ្ម CIIDG(PH-1)	ធ្យូងថ្ម	៣៥០	២០២២
១១	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ (កំពង់ឆ្នាំង-ADB)	ពន្លឺព្រះអាទិត្យ	៦០	២០២២
១២	រោងចក្រអគ្គិសនីដើរដោយថាមពលដុតសំរាម	ជីវម៉ាស	១០០	២០២២

តារាងទី ១៣ : ផែនការអភិវឌ្ឍន៍ផ្នែកផលិតកម្មសម្រាប់ឆ្នាំ ២០១៩ - ២០៣០(ត)

ល.រ	ឈ្មោះគម្រោង	ប្រភេទ	អានុភាព (MW)	ឆ្នាំដំណើរការ
១៣	រោងចក្រវារីអគ្គិសនីស្ទឹងពោធិ៍សាត់១	វារីអគ្គិសនី	៨០	២០២៣
១៤	រោងចក្រអគ្គិសនីដុតធ្យូងថ្ម CIIDG(PH-2)	ធ្យូងថ្ម	៣៥០	២០២៣
១៥	រោងចក្រអគ្គិសនីដុតធ្យូងថ្ម ROYAL GROUP(PH-1)	ធ្យូងថ្ម	៧០០	២០២៤
១៦	រោងចក្រអគ្គិសនីដើរដោយថាមពលខ្យល់	ខ្យល់	៨០	២០២៤
១៧	រោងចក្រវារីអគ្គិសនីស្ទឹងតាតៃលើ	វារីអគ្គិសនី	១៥០	២០២៦
១៨	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ	ពន្លឺព្រះអាទិត្យ	១០០	២០២៦
១៩	រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំកណ្តាល+វាលថ្នក់បុត	វារីអគ្គិសនី	១៧០	២០២៦
២០	រោងចក្រអគ្គិសនីដើរដោយឧស្ម័នធម្មជាតិ	ឧស្ម័នធម្មជាតិ	១.២០០	២០២៧
២១	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ	ពន្លឺព្រះអាទិត្យ	១០០	២០២៧
២២	រោងចក្រវារីអគ្គិសនីទន្លេស្រែពក3A	វារីអគ្គិសនី	៦៨	២០២៨
២៣	រោងចក្រវារីអគ្គិសនីទន្លេស្រែពក3B	វារីអគ្គិសនី	១៧០	២០២៨
២៤	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ	ពន្លឺព្រះអាទិត្យ	១០០	២០២៨
២៥	រោងចក្រវារីអគ្គិសនីសេសានក្រោមពា	វារីអគ្គិសនី	២៦០	២០២៨
២៦	រោងចក្រវារីអគ្គិសនីស្ទឹងមេទឹក	វារីអគ្គិសនី	១០០	២០២៩
២៧	រោងចក្រវារីអគ្គិសនីស្ទឹងព្រែកល្អាង១+២	វារីអគ្គិសនី	១២៨	២០២៩
២៨	រោងចក្រអគ្គិសនីដើរដោយឧស្ម័នធម្មជាតិ(គម្រោងថ្មី)	ឧស្ម័នធម្មជាតិ	២.៤០០	២០២៩
២៩	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ	ពន្លឺព្រះអាទិត្យ	១០០	២០២៩
៣០	រោងចក្រវារីអគ្គិសនីស្ទឹងត្រែង	វារីអគ្គិសនី	១.៤០០	២០២៩
៣១	រោងចក្រអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ	ពន្លឺព្រះអាទិត្យ	២០០	២០៣០
សរុប			**៧.០១៣ MW**	

តារាងទី ១៤ : ផែនការមេតែប្រព័ន្ធខ្សែបញ្ជូន ១១៥ គីឡូវ៉ុល

ល.រ	ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ១១៥ KV	ប្រវែងខ្សែ (km)	ឆ្នាំដំណើរការ	ដៃគូអភិវឌ្ឍន៍
១	អនុស្ថានីយទី២ - អនុស្ថានីយ សួនច្បារសម្តេច ហ៊ុន សែន	៥	២០១៩	សាងសង់ ផ្ទេរ (BT)
២	អនុស្ថានីយរតនៈមណ្ឌល - អនុស្ថានីយប៉ៃលិន	៨៥		អគ្គិសនីកម្ពុជា
៣	អនុស្ថានីយទី៣ - អនុស្ថានីយទួលគោក	៥		អគ្គិសនីកម្ពុជា
៤	អនុស្ថានីយទី៥ - អនុស្ថានីយជ្រោយចង្វារ	១៨		សល់ពីគម្រោងជុំវិញរាជធានីភ្នំពេញ(ធនាគារចិន)
៥	អនុស្ថានីយកំពង់ចាម - អនុស្ថានីយព្រែកប្រសព្វ(ក្រចេះ)	៩១		ទីភ្នាក់ងារ អភិវឌ្ឍន៍បារាំង
៦	អនុស្ថានីយស្វាយអន្ទរ - អនុស្ថានីយកំពង់សីហ្គ	៨៦		ធនាគារចិនអាហារ៍ណានីហារ៍ណា
៧	អនុស្ថានីយខេត្តព្រះសីហនុ - អនុស្ថានីយវាម	១២		ធនាគារចិនអាហារ៍ណានីហារ៍ណា
៨	អនុស្ថានីយវាម - អនុស្ថានីយចំការលួង	៦០		ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង
៩	អនុស្ថានីយកំពង់ធំ - អនុស្ថានីយព្រះវិហារ	១៨០		ធនាគារចិនអាហារ៍ណានីហារ៍ណា
១០	អនុស្ថានីយព្រែកប្រសប់ - អនុស្ថានីយក្រចេះ	៣០	២០២១	ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង

តារាងទី ១៤ : ផែនការមេនៃប្រព័ន្ធខ្សែបញ្ជូន ១១៥ គីឡូវ៉ុល(ត)

ល.រ	ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ១១៥ KV	ប្រវែងខ្សែ (km)	ឆ្នាំដំណើរការ	ដៃគូរអភិវឌ្ឍន៍
១១	ខ្សែបញ្ជូនកប៉ដីពីអនុស្ថានីយទី១ - អគ្គិសនីកម្ពុជា(វត្តភ្នំ) - សួនច្បារ សម្តេច ហ៊ុន សែន - អនុស្ថានីយអូឡាំពិក - អង្គភាពមជ្ឈមណ្ឌលជាតិបញ្ជូន - អនុស្ថានីយទី៣	១៤	២០២១	JICA ជំហានទី១
១២	អនុស្ថានីយក្រឡាញ់ - អនុស្ថានីយឧត្តរមានជ័យ	៨០	២០២២	BOT
១៣	អនុស្ថានីយចំការលួង - រោងចក្រវារីអគ្គិសនីគីរីរម្យ	៣០	២០២៤	ធនាគារចិនអាហារ័ណានីហារ័ណ
១៤	អនុស្ថានីយកំពត - អនុស្ថានីយជីបម៉ុង	៤៦		ធនាគារចិនអាហារ័ណានីហារ័ណ
១៥	អនុស្ថានីយច្រកមៀស - អនុស្ថានីយពញាក្រែក	៧៥	២០២៥	ធនាគារចិនអាហារ័ណានីហារ័ណ
១៦	អនុស្ថានីយសួង - អនុស្ថានីយពញាក្រែក	៤៥		ធនាគារឥណ្ឌា អាហារ័ណានីហារ័ណ
១៧	អនុស្ថានីយទី៧ - អនុស្ថានីយកោះធំ	៤០		ធនាគារចិនអាហារ័ណានីហារ័ណ
១៨	អនុស្ថានីយតាកែវ - អនុស្ថានីយកោះធំ	៤៥		ធនាគារចិនអាហារ័ណានីហារ័ណ
ប្រវែងខ្សែសរុប		**៨២៧ km**		

តារាងទី ១៥ : ផែនការមេនៃប្រព័ន្ធខ្សែបញ្ជូន ២៣០ គីឡូវ៉ុល

ល.រ	ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣0KV	ប្រវែងខ្សែ (km)	ឆ្នាំដំណើរការ	ដៃគូអភិវឌ្ឍន៍
១	អនុស្ថានីយបាត់ដំបង - សៀមរាប - កំពង់ធំ - កំពង់ចាម	៣៥0	២០១៩	ធនាគារចិនអាហារ័ណានីហារ័ណ
២	ជុំវិញរាជធានីភ្នំពេញជំហានទី២ (ខាងជើង - ជ្រោយចង្វារ - ខាងកើត - ខាងជើង)	៩៦		ធនាគារចិនអាហារ័ណានីហារ័ណ
៣	រោងចក្រវារីអគ្គិសនីតាតៃ - ភ្នំពេញ	១៨២		BOT
៤	អនុស្ថានីយកោះកុង - អនុស្ថានីយក្រុងកោះកុង	២0		ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង
៥	អនុស្ថានីយចំការលួង - អនុស្ថានីយបុទុមសាគរ	៥៤		
៦	អនុស្ថានីយបុទុមសាគរ - រោងចក្រវារីអគ្គិសនីតាតៃ	៧0		BOT
៧	អនុស្ថានីយក្រចេះ - អនុស្ថានីមណ្ឌលគិរី	១៧0		ធនាគារចិនអាហារ័ណានីហារ័ណ
៨	អនុស្ថានីយរតនគិរី - អនុស្ថានីយស្ទឹងត្រែង	១២0		ធនាគារចិនអាហារ័ណានីហារ័ណ
៩	អនុស្ថានីយបែកចាន - អនុស្ថានីយទី៥ - អង្គភាពមជ្ឈមណ្ឌល ជាតិបញ្ជូន	២0	២0២១	JICA ជំហានទី២
១0	អនុស្ថានីយទី៤ - អនុស្ថានីយកំពង់ស្ពឺថ្មី - អនុស្ថានីយកំពង់ស្ពឺ	៤៨		ធនាគារចិនអាហារ័ណានីហារ័ណ
១១	អនុស្ថានីយស្ទឹងហាវ - អនុស្ថានីយអូរត្រែះ	១៦		អគ្គិសនីកម្ពុជា
១២	អនុស្ថានីយសួង - អនុស្ថានីយស្វាយអន្ទរ	៤៥		ធនាគារចិនអាហារ័ណានីហារ័ណ
១៣	អនុស្ថានីយទំនើបទី២ - អនុស្ថានីយព្រែកហូរ	១៥		ធនាគារចិនអាហារ័ណានីហារ័ណ
១៤	អនុស្ថានីយទំនើបទី៥ - អនុស្ថានីយសែនសុខ	៦	២0២២	អគ្គិសនីកម្ពុជា
១៥	អនុស្ថានីយស្ទឹងត្រែង - អនុស្ថានីយខាងជើងសៀមរាប	២00	២0២៥	ធនាគារចិនអាហារ័ណានីហារ័ណ
១៦	អនុស្ថានីយខាងជើងសៀមរាប - អនុស្ថានីយខាងកើតសៀមរាប	៤៤	២0២៥	ធនាគារចិនអាហារ័ណានីហារ័ណ
ប្រវែងខ្សែសរុប		**១.៤៥៦** km		

តារាងទី ១៦ : ផែនការមេនៃប្រព័ន្ធខ្សែបញ្ជូន ៥00 គីឡូវ៉ុល

ល.រ	ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ៥00KV	ប្រវែងខ្សែ (km)	ឆ្នាំដំណើរការ	ដៃគូអភិវឌ្ឍន៍
១	អនុស្ថានីយចំការលួង - អនុស្ថានីយបែកចាន	១៩៨	២0២0	BOT
២	អនុស្ថានីយស្ទឹងត្រែង - ព្រំប្រទល់ឡាវ	៥៥	២0២១	ធនាគារចិនអាហារ័ណានីហារ័ណ
៣	អនុស្ថានីយបែកចាន - អនុស្ថានីយខាងកើតភ្នំពេញ	៤៥		ធនាគារចិនអាហារ័ណានីហារ័ណ
៤	អនុស្ថានីយខាងកើតភ្នំពេញ - អនុស្ថានីយសួង	៩0	២0២៣	ធនាគារចិនអាហារ័ណានីហារ័ណ
ប្រវែងខ្សែសរុប		**៣៨៨** km		


200000
300000
400000
500000
1600000
1500000
1400000
1300000
1200000
GS_ODMC
GS_IE Border S/S
GS BTC
GS SRP
E-SRP S/S
BTB
BTB(CPTL) S/S
Ratanak Mudol S/S
Palm S/S
Krokor 80MW
GS_Krokor
KCN S/S
ADB 60MW
O Som S/S
GS_Chamkar Loung
GS_Chrey Thom
Kampong Soeng
GS_CMIC
GS_KCC
KPT S/S
Chhuk S/S
Preah Vih





1:2,000,000

Legend

- រោងចក្រវារីអគ្គិសនីដំណើរការ
- រោងចក្រវារីអគ្គិសនីផែនការ
- រោងចក្រឈ្លូងថ្ម
- រោងចក្រឧស្ម័នផែនការ
- ស្ថានីយដើរដោយពន្លឺព្រះអាទិត្យ
- អនុស្ថានីយ ៥០០ គ.វ
- អនុស្ថានីយ ២៣០ គ.វ
- អនុស្ថានីយ ១១៥ គ.វ

ខ្សែបញ្ជូនតង់ស្យុង ១១៥ គ.វ

ប្រភេទ

- កំពុងដំណើរការ
- កំពុងដំណើរការ
- កំពុងសាងសង់
- កំពុងសាងសង់
- កំពុងសិក្សា
- កំពុងសិក្សា
- កំពុងដំណើរការ និងកំពុងសិក្សា

ខ្សែបញ្ជូនតង់ស្យុង ២៣០ គ.វ

ប្រភេទ

- កំពុងដំណើរការ
- កំពុងសាងសង់
- កំពុងសិក្សា

ខ្សែបញ្ជូនតង់ស្យុង ៥០០ គ.វ

ប្រភេទ

- កំពុងសាងសង
- កំពុងសិក្សា
- ក្រុង/ទីរួមខេត្ត
- ផ្លូវជាតិ
- ផ្លូវជាតិមេ
- ព្រំប្រទល់ខេត្ត
- ទន្លេសាប
- សមុទ្រ
- ផ្លូវទន្លេមេ

ការតភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសជិតខាង

១- ការតភ្ជាប់បណ្តាញអគ្គសនីជាមួយប្រទេសថៃឡង់ដ៍

២- ការតភ្ជាប់បណ្តាញអគ្គសនីជាមួយប្រទេសឡាវ

៣- ការតភ្ជាប់បណ្តាញអគ្គសនីជាមួយប្រទេសវៀតណាម

៤- ការតភ្ជាប់បណ្តាញអនុតំបន់

១- ការតភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសថៃឡង់ដ៍

កិច្ចព្រមព្រៀងសហប្រតិបត្តិការថាមពលជាមួយប្រទេសថៃឡង់ដ៍ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០០០។ កិច្ចព្រមព្រៀងនេះ បានផ្តល់នូវក្របខណ្ឌការងារសម្រាប់ការធ្វើពាណិជ្ជកម្មថាមពល និងជំនួយបច្ចេកទេសរវាងប្រទេសទាំងពីរនេះ និងបើកឲ្យថាមពលអគ្គិសនីចូលទៅប្រទេសទីបី។ កិច្ចព្រមព្រៀងទិញ-លក់ថាមពល បានចុះហត្ថលេខានៅឆ្នាំ ២០០២ និងបានកែសម្រួលនៅឆ្នាំ២០០៧ ។ កិច្ចព្រមព្រៀងនេះ បានជំរុញឲ្យប្រើប្រាស់រួមគ្នានូវធនធានធម្មជាតិដែលមានស្រាប់របស់ប្រទេសទាំងពីរ។ នៅពេលដែលប្រភពបញ្ចូលគ្នា នឹងត្រូវបង្កើតឡើងប្រទេសទាំងពីរអាចចូលរួមដោយទូលាយលើការផ្គត់ផ្គង់ថាមពល និងការទទួលថាមពល ។

ខ្សែបញ្ជូន ១១៥ គីឡូវ៉ុល ចេញពីអនុស្ថានីយអារញ្ញប្រាថេត ប្រទេសថៃឡង់ដ៍ ភ្ជាប់ទៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប បានដាក់ឲ្យដំណើរការក្នុងឆ្នាំ ២០០៧។ ថាមពលអគ្គិសនីរវាងប្រទេសកម្ពុជា និងប្រទេសថៃឡង់ដ៍ ត្រូវបានបញ្ជូនដោយតង់ស្យុង ២២ គីឡូវ៉ុល និង ១១៥ គីឡូវ៉ុល។ កិច្ចព្រមព្រៀងមួយ បានចុះហត្ថលេខាជាមួយខេត្តត្រាត នៃប្រទេសថៃឡង់ដ៍ ដើម្បីផ្គត់ផ្គង់ថាមពលឲ្យខេត្តកោះកុង និងក្រុងប៉ោយប៉ែត នៃប្រទេសកម្ពុជាដោយប្រើបណ្តាញ២២គីឡូវ៉ុល ។ តំបន់ខាងលើបានភ្ជាប់ថាមពលតាំងពីឆ្នាំ ២០០១ ។

២- ការតភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសឡាវ

កិច្ចសហប្រតិបត្តិការថាមពល ជាមួយប្រទេសឡាវ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៩ ។ កិច្ចព្រមព្រៀងនេះ មានគោលបំណងសហប្រតិបត្តិការ ក្នុងវិស័យថាមពលរវាងប្រទេសទាំងពីរ។ ការផ្គត់ផ្គង់ថាមពលដល់តំបន់តាមបណ្តោយព្រំដែន ដោយបណ្តាញតង់ស្យុងមធ្យម ២២គីឡូវ៉ុល និងការតភ្ជាប់បណ្តាញជាមួយបណ្តាញតង់ស្យុងខ្ពស់ ត្រូវបានជំរុញ ។ ការតភ្ជាប់បណ្តាញតង់ស្យុង ២២ គីឡូវ៉ុល ពីខេត្តចម្ប៉ាសាក់ ប្រទេសឡាវ មកខេត្តស្ទឹងត្រែង ត្រូវបានដាក់ឲ្យដំណើរការនៅឆ្នាំ២០១០។ នៅឆ្នាំ២០១៥ ខ្សែបញ្ជូនតភ្ជាប់ថ្មីពីអនុស្ថានីយបានហាត ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ ទៅស្រុកកំពង់ស្រឡៅ ខេត្តព្រះវិហារ ប្រទេសកម្ពុជា ត្រូវបានសាងសង់រួចរាល់ និងដាក់ឲ្យដំណើរការនៅចុងឆ្នាំ ២០១៧ កន្លងទៅ។

៣- ការតភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសវៀតណាម

កិច្ចសហប្រតិបត្តិការថាមពលជាមួយប្រទេសវៀតណាម បានចុះហត្ថលេខានៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩។ កិច្ចព្រមព្រៀងនេះ មានចំណងសហប្រតិបត្តិការក្នុងវិស័យថាមពលរវាងប្រទេសទាំងពីរ។ការផ្គត់ផ្គង់ថាមពលឲ្យតំបន់តាមបណ្តោយព្រំដែន ដោយខ្សែបណ្តាញតង់ស្យុងមធ្យម និងការតភ្ជាប់ទៅវិញទៅមក រវាងខ្សែបញ្ជូនតង់ស្យុងខ្ពស់ត្រូវបានជំរុញ។

អគ្គិសនីកម្ពុជាបាននាំចូលថាមពលពីប្រទេសវៀតណាមតាមខ្សែបញ្ជូន ២៣០ គីឡូវ៉ុល ផ្គត់ផ្គង់នៅភ្នំដិន ក្នុងខេត្តតាកែវ ក្នុងឆ្នាំ២០០៩។ អគ្គិសនីកម្ពុជាបានភ្ជាប់ខ្សែបញ្ជូន ២៣០ គីឡូវ៉ុល សម្រាប់នាំចូលថាមពលពីប្រទេសវៀតណាម មកភ្នំពេញ និងបានដាក់ឲ្យដំណើរការនៅខែមីនា ឆ្នាំ២០០៩ ។ អគ្គិសនីកម្ពុជា បាននាំថាមពលពី PC2 ដើម្បីផ្គត់ផ្គង់នៅស្រុកមេមត់ និងស្រុកពញាក្រែក ខេត្តកំពង់ចាម បាវិត នៅខេត្តស្វាយរៀង កំពង់ត្រាច នៅខេត្តកំពត កោះធំ និងជ្រៃធំ នៅខេត្តកណ្តាល ស្រុកស្នួលនៅខេត្តក្រចេះ ស្រុកកែវសីមា នៅខេត្តមណ្ឌលគិរី ស្រុកកំពង់រោទិ៍នៅខេត្តស្វាយ-រៀងនៅឆ្នាំ២០០២។

៤- ការតភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសឡាវ

ការសិក្សាតភ្ជាប់រវាងបណ្តាញ ដែលនៅជាប់ដោយឡែកពីប្រទេសមួយទៅប្រទេសមួយនៅក្នុងអនុតំបន់អាងទន្លេមេគង្គ (កម្ពុជា ឡាវ ថៃឡង់ដ៏ វៀតណាម យូណានប្រទេសចិន និងប្រទេសភូមា) និងសូម្បីតែបណ្តាញប្រទេសម៉ាឡេស៊ី និងសឹង្ហបុរី ក៏ត្រូវបានយកមកធ្វើការសិក្សាផងដែរ ដោយមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវការប្រើប្រាស់ប្រភពថាមពល។ របាយការណ៍ស្តីពី ផែនការមេនៃការតភ្ជាប់បណ្តាញរបស់អាស៊ាន ត្រូវបានសិក្សាបញ្ចប់នៅឆ្នាំ ២០០២ ដែលបង្ហាញពីការសិក្សាមួយយ៉ាងច្បាស់ ស្តីពីការតភ្ជាប់បណ្តាញរបស់អាស៊ាន។ បច្ចុប្បន្នមានការពិនិត្យឡើងវិញ អំពីផែនការមេនៃការតភ្ជាប់បណ្តាញរបស់អាស៊ាននេះ ដោយក្រុមសិក្សានៃបណ្តាប្រទេសអាស៊ាន។

ការសិក្សាផ្តល់ភាគច្រើន លើការវាយតម្លៃលើអាទិភាព និងលទ្ធភាពជោគជ័យនៃការតភ្ជាប់ខ្សែបណ្តាញទៅវិញទៅមកនៅក្នុងតំបន់ ដោយផ្អែកលើការសិក្សាបុរេសមិទ្ធិលទ្ធភាព។ ការសិក្សាបានស្នើឲ្យមានការអភិវឌ្ឍន៍បណ្តាញថាមពលអាស៊ាន (APG) ដោយបានបង្កើតគណៈកម្មាធិការទីប្រឹក្សាបណ្តាញថាមពលអាស៊ាន ។ យ៉ាងណាក៏ដោយ ក្នុងចំណោមការសិក្សាតភ្ជាប់បណ្តាញចំនួន ១០ របស់អាស៊ាន ការតភ្ជាប់បណ្តាញរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ជាប់លំដាប់ទី៨ និងបានចាត់ថ្នាក់ថាជាគម្រោងដែលមានសក្តានុពលពីរយៈពេលខ្លីទៅរយៈពេលមធ្យម ដែលគួរបញ្ចប់គម្រោងនេះមុនឆ្នាំ២០១០ ។

“ ចំណុលខុសត្រូវរបស់អគ្គិសនីកម្ពុជាចំពោះសង្គម

១- ការចុះជួយឧបត្ថម្ភកងទ័ព

២- ការថែរមនុស្សធម៌

៣- ការចូលរួមលើកកម្ពស់ទស្សវិស័យអប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស

ក្រៅពីការប្រកបសកម្មភាពអាជីវកម្មស្នូល អគ្គិសនីកម្ពុជា បានចូលរួមចំណែកក្នុងការងារសង្គម មនុស្សធម៌ បណ្តុះបណ្តាលធនធានមនុស្ស និងការការពារបរិស្ថានជាច្រើនតាមរយៈការផ្តល់ជាសម្ភារ ថវិកា និងការចូលរួមជាសកម្មភាពផ្សេងៗដូចខាងក្រោម៖

១- ការចុះជួយឧបត្ថម្ភកងទ័ព

អគ្គិសនីកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់ក្នុងការចូលរួមចំណែកកិច្ចការងារសង្គមរួមមាន ការចុះជួយឧបត្ថម្ភកងទ័ព ដូចជា កងពលតូចថ្មើរជើងលេខ៥២ និងនគរបាលរង:សេនាតូចលេខ៧០២ កងទ័ពនៃកងពលតូចអន្តរាគមន៍លេខ១៤ និងរង:សេនាតូចលេខ១ ដោយជារៀងរាល់២ខែម្តងថ្នាក់ដឹកនាំអគ្គិសនីកម្ពុជា រួមជាមួយសហការីតែងតែចុះសួរសុខទុក្ខកងទ័ពនៅច្រកព្រំដែន និងភ្ជាប់ជាមួយនូវសម្ភារប្រើប្រាស់ផ្សេងៗ រួមទាំងសាងសង់លេណដ្ឋាន និងផ្ទះជូនកងទ័ពផងដែរ។

២- ការចារមនុស្សធម៌

ក្រៅពីនេះ អគ្គិសនីកម្ពុជា បានចូលរួមឧបត្ថម្ភជាថវិកាដល់កាកបាទក្រហមកម្ពុជាស្ទាក់ការកណ្តាល និងតាមបណ្តាខេត្ត ជារៀងរាល់ឆ្នាំ ដើម្បីជួយប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ និងគ្រោះរាំងស្ងួត។ ក្នុងឆ្នាំ២០១៨ អគ្គិសនីកម្ពុជា បាននាំយកថវិកាឧបត្ថម្ភដល់មន្ទីរពេទ្យគន្ធបុប្ផា ដែលជាទឹកចិត្តបរិសុទ្ធរបស់និយោជិតអគ្គិសនីកម្ពុជា ដើម្បីសង្គ្រោះកុមារកម្ពុជា និងថវិកាមួយចំណែកតូចជាថវិការបស់អតិថិជនអគ្គិសនីកម្ពុជាផងដែរ។ ក្នុងឆ្នាំ២០១៨ អគ្គិសនីកម្ពុជា បានឧបត្ថម្ភថវិកាសរុបចំនួន ៣០,០០០ ដុល្លារអាមេរិក។ លើសពីនេះ អគ្គិសនីកម្ពុជាបានឧបត្ថម្ភការកសាងផ្លូវដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុងខេត្តពោធិ៍សាត់។